# សង្កេតការណ៍ ១៦

## ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម




ខែតុលា ឆ្នាំ២០១២

## មាតិកា

សវនាការសួរដេញដោល
សាក្សី គឹម វុន ២
ដើមបណ្ដឹង ឯម អឿន ១៧
សាក្សី នង សុផង់ ២៧
សាក្សី ជា សាយ ៤០
សាក្សី នឹម សែម ៤៤
សាក្សី ខៀវ អេន ៥១

ក្រុមសង្កេតការណ៍ :
ឆាយ ឈុនលី, លឹម ជ័យទត្ត,
ឌី សុជាតា និង ចាន ប្រាថ្នា

*ខៀវ សំផន ពេលចាប់ខ្លួនបញ្ជូនទៅ*
*អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងឆ្នាំ២០០៧*

មជ្ឈមណ្ឌលឯកសារកម្ពុជា◆ស្វែងរកការពិតដើម្បីការចងចាំនិងយុត្តិធម៌◆www.dccam.org



អៀង សារី និង អៀង ធីរិទ្ធ អមដំណើរគណៈប្រតិភូចិន ដឹកនាំដោយ វ៉ាង ដុងស៊ីង (ស្តាំបង្អស់) ក្នុងអំឡុងពេលនៃដំណើរទស្សនកិច្ចមកកាន់ប្រទេសកម្ពុជាកាលពីថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ។ រូបស្ត្រីឈរបែរខ្នង (ស្តាំ) សមមិត្ត សៀ អ្នកបកប្រែភាសាចិន-ខ្មែរ (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

# សវនាការលើសំណុំរឿង០០២
## រចនាសម្ព័ន្ធរដ្ឋបាល ប្រព័ន្ធទំនាក់ទំនង និងតួនាទីរបស់ជនជាប់ចោទ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ
## *ថ្ងៃទី២១ ខែសីហា ដល់ថ្ងៃទី២ ខែតុលា ឆ្នាំ២០១២*

*ឆាយ ឈុនលី, ចាន ប្រាថ្នា, ឌី សុជាតា និង លីម ជ័យទ័ត្ត*

### *សេចក្តីផ្តើម*

ចាប់ពីថ្ងៃទី២១ ខែសីហា ដល់ថ្ងៃទី២ ខែតុលា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបើកសវនាការសួរដេញដោលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន៦រូប ដោយផ្តោតសំខាន់លើប្រព័ន្ធទំនាក់ទំនងការងារនៃរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្នាក់ក្រោមរហូតដល់ថ្នាក់កំពូល និងការបាត់ខ្លួនកម្មាភិបាលដែលធ្វើការនៅក្នុងក្រសួងឃោសនាការក្រោមការគ្រប់គ្រងរបស់ ហ៊ូ នឹម ដែលក្រោយមកត្រូវបានចាប់ខ្លួន ។ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំង៦រូបរួមមាន ទី១) សាក្សី គីម វុន ជាអតីតបុគ្គលិកនៅក្រសួងឃោសនាការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទី២) ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន ជាអតីតគ្រូពេទ្យមូលដ្ឋាននៅតំបន់២០ ។ ទី៣) សាក្សី នង សុផង់ ជាអតីតប្រធានមន្ទីរបកប្រែឯកសារទូរលេខ និងជាបុគ្គលិកនៅក្រសួងឃោសនាការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទី៤) សាក្សី ជា សាយ ជាអតីតជាងជួសជុលរថយន្តនៅមន្ទីរក-១២ ដែលជាផ្នែកមួយនៃមន្ទីរ៨៧០ និងជាអ្នកដឹកជញ្ជូនកងទ័ព និងបុគ្គលិកពេទ្យនៅទីក្រុងភ្នំពេញ ។ ទី៥) សាក្សី នឹម សែម ជាអតីតអ្នកចម្រៀង និងអ្នកអានព័ត៌មាននៅក្នុងក្រសួងឃោសនាការនៃរបបកម្ពុជាប្រជាធិបតេយ្យ និងទី៦) សាក្សី ខៀវ អេន ជាអតីតបុគ្គលិកក្រសួងព័ត៌មាន និងឃោសនាការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

នៅអំឡុងពេលនៃសវនាការសួរដេញដោលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីទាំង៦រូប ក្នុងរយៈពេលចំនួន១៥ថ្ងៃ គឺមានការចូលរួមតាមដានពីសំណាក់ប្រជាជនកម្ពុជាប្រហែល៥.០០០នាក់ ដែលមកពីតាមបណ្តាខេត្តមួយចំនួនដូចជា កណ្តាល កំពង់ស្ពឺ សៀមរាប តាកែវ ព្រៃវែង និងកំពង់ចាម និងរួមទាំងអ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិដែលឃ្លាំមើលកិច្ចដំណើរការនីតិវិធីសវនាការមួយចំនួនដែរ ។



ការសម្តែងសិល្បៈក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

# សវនាការសួរដេញដោលសាក្សី គីម វុន

## ថ្ងៃទី២១-២៣ ខែសីហា ឆ្នាំ២០១២

ចាប់ពីថ្ងៃទី២១-២៣ ខែសីហា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបន្តសួរដេញដោលសាក្សី គីម វុន ដែលជាអតីតបុគ្គលិកនៅក្រសួងឃោសនាការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការផ្តល់សក្ខីកម្មរបស់សាក្សី គីម វុន បានផ្តោតជាសំខាន់លើប្រតិបត្តិការការងារនៅក្នុងក្រសួងឃោសនាការ តួនាទីរបស់មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ និងការបាត់ខ្លួនបុគ្គលិកនៅក្នុងក្រសួង ។ សវនាការនេះ មានការចូលរួមតាមដានដោយផ្ទាល់ពីសំណាក់ប្រជាជនកម្ពុជាប្រមាណជិតពីរពាន់នាក់ ដែលមកពីតាមបណ្តាខេត្តផ្សេងៗ ។

ជនជាប់ចោទ អៀង សារី មិនមានវត្តមាននៅអំឡុងពេលនៃសវនាការសួរដេញដោលសាក្សី គីម វុន ទេ ក៏ប៉ុន្តែបានស្នើសុំអង្គជំនុំជម្រះចូលរួមសវនាការពីចម្ងាយតាមប្រព័ន្ធសោធទស្សន៍នៅក្នុងបន្ទប់រង់ចាំ ដោយលះបង់សិទ្ធិក្នុងការចូលរួមសវនាការដោយផ្ទាល់ដោយសារតែបញ្ហាសុខភាព ។

ការសួរដេញដោលសាក្សី គីម វុន បានចាប់ផ្តើមដោយចៅក្រមអង្គជំនុំជម្រះ ដោយចោទសួរទាក់ទងនឹងប្រវត្តិសាវតាររបស់សាក្សី ។ បន្ទាប់មកវេទិកាសួរដេញដោលត្រូវបានប្រគល់ជូនសហព្រះរាជអាជ្ញា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនិងមេធាវីការពារក្តីទាំងបីក្រុមជាបន្តបន្ទាប់ ។

### ១) ប្រវត្តិសាវតាររបស់សាក្សី

ប្រធានអង្គជំនុំជម្រះ លោកចៅក្រម និល ណុន បានសាកសួរដេញដោលសាក្សី គីម វុន ទាក់ទងនឹងប្រវត្តិសាវតាររបស់លោក មុនពេលប្រគល់វេទិកាសួរដេញដោលជូនតំណាងសហព្រះរាជអាជ្ញា ។ ឆ្លើយតបនឹងសំណួររបស់អង្គជំនុំជម្រះ សាក្សី គីម វុន បានជម្រាបជូនលោកប្រធានអង្គជំនុំជម្រះថា លោកមានឈ្មោះ គីម វុន ហៅ ឆោម អាយុ៥៣ឆ្នាំ រស់នៅភូមិប៉ាហ៊ីត្បូង សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន ។ បច្ចុប្បន្នមានតួនាទីជាអនុប្រធានមន្ទីរប្រៃសណីយ៍ខេត្តប៉ៃលិន ។ ឪពុកឈ្មោះ គីម ពេជ្រ និងម្តាយ ទូច ស្តើង និងមានប្រពន្ធឈ្មោះ មាស សំនៀង និងមានកូនស្រីម្នាក់ ។ លោកបានបន្តទៀតថា លោកធ្លាប់បានផ្តល់បទសម្ភាសន៍ចំនួនបីលើកនៅមន្ទីរប្រៃសណីយ៍ខេត្តប៉ៃលិន ប៉ុន្តែនៅលើកទីបីនោះលោកពុំបានចុះហត្ថលេខាឡើយ ។



សាក្សី គីម វុន

### ២) ការសួរដេញដោលសាក្សីដោយសហព្រះរាជអាជ្ញា

នៅអំឡុងពេលនៃការសួរដេញដោលសាក្សី គីម វុន សហព្រះរាជអាជ្ញាបានចំណាយពេលមួយថ្ងៃកន្លះ គឺរសៀលថ្ងៃទី២១ និងទី២២ ខែសីហា ឆ្នាំ២០១២ ដោយផ្តោតសំខាន់លើការប្រជុំនៅថ្នាក់មូលដ្ឋាន ទំនាក់ទំនងរវាងថ្នាក់លើ និងថ្នាក់ក្រោម ការរៀនសូត្រជាមូលដ្ឋាន មន្ទីរផ្សេងៗ ការបោះពុម្ពផ្សាយ និងបែងចែកឯកសារ ការកំណត់ថ្ងៃកំណើតបក្ស និងការសម្អាតខ្មាំងអង្គការ និងបក្សកុម្មុយនីស្តកម្ពុជា និងតួនាទីរបស់ ខៀវ សំផន ។

## ២.ក) តំណាងសហព្រះរាជអាជ្ញាជាតិ

លោកតំណាងសហព្រះរាជអាជ្ញា វើង ហ៊ត់ បានចាប់ផ្តើមសំណួរដោយលើកឡើងនូវកំណត់ហេតុ ដែលសាក្សីបានធ្វើនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងមូលហេតុដែលសាក្សីទៅធ្វើការនៅក្នុងរោងពុម្ពរណសិរ្សនៅក្នុងស្រុកសន្ទុក ។ សាក្សីបានបញ្ជាក់ថា នៅពេលនោះខ្លួនធ្វើការនៅក្នុងភូមិ ប៉ុន្តែក្រោយមកមានការអូសទាញពីខាងភូមិភាគ ម្យ៉ាងទៀតលោកយល់ថា ការធ្វើការនៅមជ្ឈមជាកន្លែងជាក់លាក់មួយ ហើយខ្លួននឹងអាចត្រលប់មកលេងផ្ទះបានហើយនៅក្នុងស្រុកគឺស្ថិតនៅក្នុងកងកម្លាំងប្រដាប់អាវុធ ។ នៅពេលនោះខ្លួនមានអាយុជាងដប់ឆ្នាំ ។ លោកអាចសរសេរអក្សរបានស្អាត ប៉ុន្តែពុំមានជំនាញខាងរោងពុម្ពនៅឡើយ ។ លោកបានបន្ថែមថា នៅទីនោះ ប៉ង់ ជាអ្នកទទួលខុសត្រូវ ហើយការងាររបស់ខ្លួនគឺសរសេរអក្សរនៅលើក្រដាសរាល់ថ្ងៃដើម្បីហ្វឹកហាត់ឲ្យសរសេរអក្សរឲ្យបានស្អាតសម្រាប់សរសេរកូនសៀវភៅដែលនិយាយពីរឿងរ៉ាវ កែវ ញ៉ិល ដែលនៅក្នុងនោះមានរៀបរាប់ពីអ្នកតស៊ូនៅខេត្តកំពង់ចាម ដែលជាអ្នកធ្វើពលកម្ម ។



តំណាងសហព្រះរាជអាជ្ញាជាតិ វើង ហ៊ត់

លោកបានរៀបរាប់បន្តថា នៅរោងពុម្ពរណៈសិរ្សមានបុគ្គលិកក្មេងៗពីរនាក់គឺ អុល និងខ្លួន ហើយពីរនាក់ទៀតគឺជាគ្រូបង្រៀន ។ សាក្សី គឹម វ៉ុន បានបន្តថា ការបោះពុម្ពនៅពេលនោះ គឺមានឯកសារជាច្រើនទាក់ទងនឹងរណសិរ្ស ដែលមានដូចជាដំណឹងសមរភូមិ សេចក្តីថ្លែងការណ៍ផ្សេងៗរបស់ថ្នាក់ដឹកនាំជាភាសាបារាំង និងឡាតាំង ។ ឯកសារទាំងនោះគឺត្រូវសរសេរដោយដៃចម្លងដាក់កាបោន និងសរសេរលើស្ពង់ស៊ីលដើម្បីយកទៅបោះពុម្ព ។ សាក្សីបានបន្ថែមថា ជាទូទៅខ្លួនបានអានឯកសារទាំងនោះឲ្យយល់ ទើបសរសេរជាក្រោយ ។ ឆ្លើយតបនឹងសំណួរបន្ទាប់របស់សហព្រះរាជអាជ្ញាទាក់ទងនឹងខ្លឹមសារដែលសរសេរពាក្យថា “ជ័យយោ” នោះសាក្សីបានបញ្ជាក់ថា ពាក្យនេះក៏មានប្រើនៅក្នុងឯកសាររណសិរ្សដែរ ។ ចំពោះសៀវភៅដែលបោះពុម្ពរួចហើយនោះត្រូវបានយកទៅចែកឲ្យកម្មាភិបាលនៅតាមមូលដ្ឋាន ។ សាក្សីបានបន្តថា ពេលធ្វើការនៅទីនោះមិនមានបុគ្គលិកណាហ៊ានចេញទៅក្រៅឡើយ ហើយត្រូវតែរក្សាការសម្ងាត់ បើមិនដូច្នោះទេយន្តហោះនឹងមកទម្លាក់គ្រាប់បែកមិនខាន ហើយអ្នកដែលទទួលខុសត្រូវមានតែបួននាក់ប៉ុណ្ណោះ ដែលជាអ្នកណែនាំនៅខាងបោះពុម្ព ។ សាក្សីបានរៀបរាប់បន្ថែមថា នៅរោងពុម្ពមិនថាកុមារ ឬមនុស្សធំទេ គឺត្រូវធ្វើការផ្លាស់វេនគ្នាដូចជា ដាំបាយ និងសម្អាតអនាម័យជាដើម ហើយនៅទីនោះខ្លួនបានជួបជនជាប់ចោទ ខៀវ សំផន ដែលចេញចូលនៅកន្លែងនោះម្តងម្កាលដោយសារតែពេលនោះ ខៀវ សំផន បានយកនំចំណីមកឲ្យក្មេងៗ និងមកលើកទឹកចិត្តដល់អ្នកដែលធ្វើការនៅរោងពុម្ព ។ បន្ទាប់ពីបញ្ចប់ការសាកសួររបស់ខ្លួនលោក វើង ហ៊ត់ បានផ្ទេរវេទិកាជូនសហការីខ្លួនគឺលោក ឃីត វ៉េន័រ ដើម្បីបន្តការសាកសួរ ។

## ២.ខ) តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ

លោកតំណាងសហព្រះរាជអាជ្ញា ឃីត វ៉េន័រ បានបន្តសួរទាក់ទងនឹងឯកសាររណសិរ្ស ដែលយកមកបោះពុម្ព ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា ឯកសាររណសិរ្សមានចំនួនច្រើន ហើយជាទូទៅនីរសារជាអ្នកយកមកផ្ទាល់ ដោយមិនមានមេដឹកនាំណាម្នាក់យកមកឡើយ ។ សាក្សីបានបន្តថា នៅពេលនោះរោងពុម្ពមានការផ្លាស់ប្តូរទីកន្លែងជាច្រើនដង ។ ដំបូងគឺមានទីតាំងនៅជិតភ្នំគោលក្បែរស្ទឹងជីនិត ហើយក្រោយមកត្រូវបាន

ផ្លាស់មកនៅប-២៨,ប-២០ និងក្រោយឆ្នាំ១៩៧៥ ផ្លាស់មកនៅជិតស្ពានអូរឬស្សីពិចវិញ ។ លោកតំណាងសហព្រះរាជអាជ្ញាបានបន្តសួរទាក់ទងនឹងទីតាំងស្ថានីយវិទ្យុផ្សាយសំឡេង សាក្សី គីម វុន បានបញ្ជាក់ថា ស្ថានីយវិទ្យុរបស់រណសិរ្សរួបរួមជាតិកម្ពុជាមានទីតាំងនៅប្រទេសចិន ហើយមកដល់ឆ្នាំ១៩៧៥ ស្ថានីយវិទ្យុនោះត្រូវបានប្តូរទីតាំងមកនៅមន្ទីរប-២០ ស្ថិតនៅស្រុកស៊ឹងត្រង់ នៅជិតរោងពុម្ពដែរ ។ អ្នកគ្រប់គ្រងរួមនៅតំបន់ប-២០គឺ ប៉ង់ ។ សាក្សីបានបញ្ជាក់ថា ចាប់តាំងពីមានការផ្លាស់ទីកន្លែងមកខ្លួនបានជួយធ្វើការនៅក្នុងរោងពុម្ពខ្លះដូចជាបោះពុម្ពជាអក្សរទីប៉ូ និង



តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ឃីត វែនន័រ

ធ្វើការ នៅក្នុងក្រុមនិពន្ធដូចជា សរសេរចំណងជើង និងធ្វើឃ្លីស្សេសម្រាប់ដាក់កាសែត និងទស្សនាវដ្តី ។

### ២.១.១) ការប្រជុំនៅថ្នាក់មូលដ្ឋាន

តំណាងសហព្រះរាជអាជ្ញា បានលើកឡើងនូវកំណត់ហេតុរបស់សាក្សីទាក់ទងនឹងកិច្ចប្រជុំនៅថ្នាក់មូលដ្ឋាន ដោយសាក្សីបានបញ្ជាក់ថា នៅពេលនោះមានការប្រជុំប្រមូលកម្លាំងរំដោះជាតិដែលនិយាយពីការធ្វើសង្គ្រាម ការលះបង់តស៊ូ សាមគ្គីភាព និងរក្សាការសម្ងាត់ ដោយផ្តោតលើការប្រុងប្រយ័ត្នក្នុងការធ្វើការងារ ។ អ្នកដែលធ្វើបទខុទ្ទេសនាមនៅពេលប្រជុំនោះ គឺ យុន យ៉ាត ។ សាក្សីបានបញ្ជាក់ថា នៅពេលនោះ ហែម និងបង១ផ្សេងទៀត តែងតែលើកទឹកចិត្តដើម្បីឲ្យប្រជាជនធ្វើការងារបានល្អ ។ នៅពេលនោះមានការប្រុងប្រយ័ត្នពីបញ្ហាខ្មៅរស ដែលតែងតែមានការបាញ់បោះអាវុធជាដើម ។ ចំណែកព័ត៌មានចុងក្រោយដែលប្រកាសនោះ គឺទាក់ទងនឹងការវាយផ្ដាច់ព្រាត់នៅសមរភូមិជុំវិញភ្នំពេញ ។ ទាក់ទងនឹងបញ្ហានេះសាក្សីបានបញ្ជាក់ថា នៅពេលខ្លួនចេញពីស៊ឹងត្រង់ប្រធានមន្ទីរបានប្រាប់ឲ្យអ្នកទាំងអស់គ្នាត្រៀមពីព្រោះជ័យជម្នះជិតបានហើយព្រមទាំងមានការផ្សាយតាមវិទ្យុរណសិរ្ស ដែលនៅពេលនោះមាន ដៃ មិត្តស៊ុន មិត្តយេត និងក្រោយមកមានមិត្តមុល ។ វិទ្យុរណសិរ្សនៅភ្នំពេញកម្រមានការប្រកាសសំឡេងរបស់មេដឹកនាំណាស់ ប៉ុន្តែមានការចាក់ផ្សាយពីសេចក្តីថ្លែងការណ៍ផ្សេង១ជាដើម ។ ទាក់ទងក្រុមការងាររបស់ខ្លួននៅមន្ទីរប-២០វិញ សាក្សី គីម វុន បានបញ្ជាក់ថា នៅទីនោះមានបុគ្គលិកប្រាំនាក់ប្រុសបីនាក់ និងស្រីពីរនាក់ ហើយអត្ថបទដែលខ្លួនសរសេរចុងក្រោយនោះគឺទាក់ទងនឹងសមរភូមិ និងសេចក្តីថ្លែងការណ៍របស់មេដឹកនាំដែលអំពាវនាវឲ្យកម្មាភិបាល យុទ្ធជន យុទ្ធនារី និងប្រជាជនឲ្យរួបរួមគ្នាធ្វើការតស៊ូឲ្យបានជ័យជម្នះ ។ សេចក្តីថ្លែងការណ៍ភាគច្រើន គឺជាសេចក្តីថ្លែងការណ៍របស់ ខៀវ សំផន ។ សាក្សីបានបញ្ជាក់ថា នៅពេលខ្លួនធ្វើការនៅប-២០នោះការសរសេរអត្ថបទ គឺត្រូវសរសេរដោយដៃនៅឡើយ ។

### ២.១.២) ទំនាក់ទំនងរវាងថ្នាក់លើ និងថ្នាក់ក្រោម

លោកតំណាងសហព្រះរាជអាជ្ញាបានបន្តសំណួរទាក់ទងនឹងការផ្ញើលិខិតពីថ្នាក់លើមកថ្នាក់កណ្តាល និងថ្នាក់ក្រោម ។ សាក្សីបានបញ្ជាក់ថា ទំនាក់ទំនងត្រូវធ្វើឡើងតាមរយៈនីរសារ ដែលជាមនុស្សស្មោះត្រង់ហ៊ានឆ្លងកាត់គ្រប់ឧបសគ្គ ហើយរាល់ការរត់សំបុត្រនេះទៀតសោតត្រូវធ្វើឡើងដោយសម្ងាត់បំផុត ។

### ២.១.៣) ការរៀនសូត្រជាមូលដ្ឋាន

តំណាងសហព្រះរាជអាជ្ញាបានបន្តសួរទាក់ទងនឹងការកោះហៅកម្មាភិបាលទៅប្រជុំរៀនសូត្រ មុនពេលដាក់ផែនការឲ្យ

អនុវត្ត ។ សាក្សី គឹម វ៉ុន បានបញ្ជាក់ថា ការរៀនសូត្រនោះគឺផ្តោតសំខាន់លើការរៀនសូត្រនយោបាយ ដោយដាក់ចេញជាផែនការ ហើយក្រោយមកទើបដាក់ចេញឲ្យធ្វើ ហើយអ្នកដែលដាក់ផែនការនោះគឺមានតែថ្នាក់លើតែប៉ុណ្ណោះ ។ សហព្រះរាជអាជ្ញាបានបន្តសួរទាក់ទងនឹងការរៀនសូត្រនៅថ្នាក់មូលដ្ឋាននៅក្រោយឆ្នាំ១៩៧៥ ។ សាក្សីបានបញ្ជាក់ថា ក្រោយពេលរំដោះទីក្រុងភ្នំពេញ ការរៀនសូត្រត្រូវធ្វើឡើងនៅបុរីកីឡា មានរយៈពេល



អៀង សារី និងបុគ្គលិកក្រសួងការបរទេសជូនដំណើរគណៈប្រតិភូបរទេសចេញពីក្រសួង (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពីរសប្តាហ៍ ដែលមាន យុន យ៉ាត ជារដ្ឋមន្ត្រីក្រសួងឃោសនាការ និងអប់រំ ជាអ្នកបង្រៀន ។ សាក្សីបានបន្តថា ក្រោយឆ្នាំ១៩៧៥ ខ្លួនបានបន្តសរសេរសៀវភៅមួយក្បាលទៀត ដែលផ្សព្វផ្សាយអំពីផែនការការពារប្រទេស ការកសាងប្រទេស ប៉ុន្តែក្រោយមកខ្លួនបានដឹកនាំក្រុមថតរូប ដើម្បីត្រៀមធ្វើកាសែត និងទស្សនាវដ្តីវិញ ។

## ២.១.៤) មន្ទីរផ្សេងៗ

លោកតំណាងសហព្រះរាជអាជ្ញា ឃីត វែនន័រ បានបន្តសួរទាក់ទងនឹងមន្ទីរផ្សេងៗទៀត ដូចជា មន្ទីរក-២៥ រហូតដល់មន្ទីរក-៣១ ។ សាក្សី គឹម វ៉ុន បានបញ្ជាក់ថា មន្ទីរទាំងនោះគឺជាមន្ទីររបស់ក្រសួងឃោសនាអប់រំ ។ ដោយឡែកមន្ទីរក-២៥ គឺជាកន្លែងសម្រាប់រដ្ឋមន្ត្រីធ្វើការងារ ។ សាក្សីបានបន្ថែមថា កន្លែងដែលខ្លួនធ្វើការគឺនៅជាប់ជាមួយកាសែតសង្គ្រោះជាតិនៅជិតនាន់ លន់ នៅមុខស្ពានអូឡាំពិច ។ សាក្សីបានរៀបរាប់ថា មន្ទីរក-២៥ ជាកន្លែងបោះពុម្ពទង់បដិវត្ត និងទង់យុវជនយុវនារីបដិវត្ត ។ ក-២៦ ធំជាងមន្ទីរក-២៥ ជាកន្លែងបោះពុម្ពក្រប ហើយមន្ទីរក-២៧ ជាកន្លែងរោងពុម្ព ដែលមានបោះពុម្ពអ៊ុបសិត ហើយបោះពុម្ពឯកសារដែលមានជាភាសាអង់គ្លេស និងបារាំង ។ ឆ្លើយតបនឹងសំណួរបន្ទាប់ សាក្សីបានបញ្ជាក់ថា ខ្លួនធ្វើការនៅមន្ទីរក-២៥ ដូចជាការធ្វើចំណងជើងនៅលើក្បាលកាសែត ហើយក្រោយមកខ្លួនមកសរសេរកាសែតបដិវត្តន៍វិញដែលមានឆយ ជាប្រធាន ។ សាក្សីបានបន្តថា ទង់រណសិរ្សត្រូវបានបោះពុម្ព

យូរណាស់មកហើយ ប៉ុន្តែទស្សនាវដ្តីវិញ ខ្លួនមិនច្បាស់ថាទស្សនាវដ្តីនោះត្រូវបានបោះពុម្ពដំបូងនៅឆ្នាំណាទេ ។ លោកតំណាងសហ



សកម្មភាពក្នុងរោងពុម្ពនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

ព្រះរាជអាជ្ញាបានសាកសួរបន្តទាក់ទងនឹងអត្ថបទដែលសរសេរចេញពីគណៈមជ្ឈិម ។ ឆ្លើយតបនឹងសំណួរនេះសាក្សី គីម វុន បានបញ្ជាក់ថា ខ្លួនមិនដឹងថាអ្នកណាជាអ្នកសរសេរទេ ប៉ុន្តែបានស្គាល់អក្សរដែលកែនៅលើអត្ថបទនោះថាពិតជាអក្សររបស់ ប៉ុល ពត ។

## (២.១.៥) ការបោះពុម្ពផ្សាយ និងបែងចែកឯកសារ

ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាទាក់ទងនឹងខ្លឹមសារដែលមាននៅក្នុងទស្សនាវដ្តីនោះ សាក្សីបានបញ្ជាក់ថា នៅក្នុងទស្សនាវដ្តីនោះមាននិយាយទាក់ទងនឹងការធ្វើស្រែ ការកសាងប្រទេស ការវាយសម្រុកកសាងប្រទេសតាមសន្ទុះមហាលោតផ្លោះ មហាអស្ចារ្យជាដើម ។ ក្រៅពីនោះទៀតសាក្សីបានបញ្ជាក់ថា នៅពេលនោះមានការបោះពុម្ពផ្សាយទាក់ទងនឹងការធ្វើពិធីគម្រប់ខួបថ្ងៃជ័យជម្នះ១៧មេសាដែរ ។ សាក្សីបានបន្តថា បន្ទាប់ពីបោះពុម្ពហើយ ដូចជាទស្សនាវដ្តីត្រូវបានគេយកឡានមកដឹកយកទៅចែកឲ្យកម្មាភិបាលនៅតាមភូមិភាគ តំបន់ និងនៅស្រុក ដើម្បីអានឲ្យយល់ខ្លឹមសារ និងយកទៅបង្រៀនដល់កម្មាភិបាលថ្នាក់ក្រោមចៀសវាងការអនុវត្តខុស ។ លោកបានបន្តថា ដូចជានៅកន្លែងរបស់លោក គឺ ឆយ ជាអ្នកមានទស្សនាវដ្តីនោះ ដូច្នេះបើបុគ្គលិកដែលនៅកន្លែងរបស់លោកចង់មើល គឺអាចខ្ចីយកមកអានបាន ។ សាក្សីបានបញ្ជាក់ថា ខ្លួនមិនបានអានឲ្យយល់ពីខ្លឹមសារនៅក្នុងទស្សនាវដ្តីនោះច្រើនទេ ដោយសារខ្លួនជាប់រវល់ការងារបោះពុម្ព ។ លោកតំណាងសហព្រះរាជអាជ្ញាបានស្នើឲ្យសាក្សីបញ្ជាក់ពីគោលនយោបាយដែលមាននៅក្នុងទស្សនាវដ្តីន៍ ។ សាក្សីបានបញ្ជាក់ថា ខ្លួនមិនបានដឹងរឿងច្រើន ទាក់ទងនឹងគោលនយោបាយនោះឡើយ ដោយសារតែលោកជាអ្នកកាសែត ហើយការសរសេរនោះទៀតសោត គឺទាមទារឲ្យមានការសរសេរទូលំទូលាយ ដែលខុសគ្នាស្រឡះនឹងការសរសេរនៅក្នុងទស្សនាវដ្តី ។ បន្ទាប់មកលោក វែន័រ បានបន្តសំណួរទាក់ទងនឹងខ្មាំង ខាងក្នុង និងខ្មាំងខាងក្រៅ ។ សាក្សី គីម វុន បានបញ្ជាក់ថា ខ្លួនមិនសូវដឹង

ច្រើនទាក់ទងនឹងពាក្យនេះទេ ប៉ុន្តែនៅជំនាន់នោះមានតែការនិយាយទាក់ទងនឹងខ្មាំងយួន សេ.អ៊ី.អា. និង កា.ហ្សេ.បេ. តែប៉ុណ្ណោះ ។ លោកតំណាងសហព្រះរាជអាជ្ញាបានបង្ហាញឯកសារកំណត់ហេតុមួយទៀតរបស់សាក្សី ដែលនិយាយទាក់ទងនឹងសម្តេចសីហនុក្នុងការផ្ទេរតំណែងទៅ ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ ហើយលោកបានបង្ហាញឯកសារមួយទៀតដែលនិយាយពីសេចក្តីប្រកាសព័ត៌មានដែលចេញនៅថ្ងៃទី១៤ ខែមេសា ឆ្នាំ១៩៧៦ ដែលនិយាយពីការចូលនិវត្តន៍របស់សម្តេចសីហនុ ។ ត្រង់ចំណុចនេះ សាក្សីបានបញ្ជាក់ថា ខ្លួនបានស្គាល់ឯកសារនោះ ដែលសរសេរជាភាសាខ្មែរ ហើយបោះពុម្ពនៅមន្ទីរ២៧ ដែលមានខ្លឹមសារនិយាយពីការលាលែងពីតំណែងរបស់សម្តេច សីហនុ តែប៉ុណ្ណោះ ដោយសារខ្លួនមិនបានចាប់អារម្មណ៍ច្រើនទៅលើឯកសារនោះ ។ តំណាងសហព្រះរាជអាជ្ញាបានបន្តការសួរដោយយោងទៅលើឯកសារទាក់ទងនឹងសេចក្តីប្រកាសព័ត៌មានដែលមានឈ្មោះបុគ្គល១០រូបមាន នួន ជា, ងួន កង ជាដើម ដែល និយាយថា ជា ស៊ីម ជាអនុប្រធានរបស់ នួន ជា ។ ទាក់ទងនឹងបញ្ហានេះសាក្សីបានបញ្ជាក់ថា កាលនោះខ្លួនផ្តោតលើការងារខ្លាំង ដោយសារខ្លួនជាអ្នកកាសែត ហើយនៅពេលនោះអ្នកកាសែត មិនមានសិទ្ធិដើរចេញក្រៅទៅថតរូបភាពអ្នកដឹកនាំបានទេដោយសារតែនៅពេលនោះមានការលាក់ការសម្ងាត់ជាខ្លាំង ។ សាក្សីបានបន្ថែមថា កាលនោះ នួន ជា គឺជាប្រធានសភា ហើយក្រោយពីនោះ លោកបានស្គាល់ យុន យ៉ាត និងមេដឹកនាំមួយចំនួនទៀត ។

## ២.១.៦) ការកំណត់ថ្ងៃកំណើតបក្ស និងការសម្អាតខ្មាំង

ទាក់ទងនឹងការរំឭកខួបលើកទី១៦នៃកំណើតបក្សកុម្មុយនីស្តកម្ពុជា សាក្សីបានបញ្ជាក់ថា ការពិតទៅខួបកំណើតរបស់បក្សគឺនៅឆ្នាំហាជាង ប៉ុន្តែ ប៉ុល ពត បានកំណត់យកទសវត្សរ៍៦០វិញ ដោយសារនេះជាយុទ្ធសាស្ត្រដែលគេចង់ឲ្យបក្សនោះមានភាពឯករាជ្យពីអតីតភាព ដែលមានទំនាក់ទំនងជាមួយវៀតណាម និងឡាវ ។ តំណាងសហព្រះរាជអាជ្ញាបានបន្តដោយលើកឡើង



អៀង សារី ខៀវ សំផន នួន ជា (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

ពីការផ្សព្វផ្សាយនូវការបោសសម្អាតផ្ទៃក្នុង និងការកំណត់ខ្មាំង ។ ទាក់ទងនឹងបញ្ហានេះ សាក្សីបានបញ្ជាក់ថា ការបោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុង នោះមានភាពពាក់ព័ន្ធនឹងចលនាតស៊ូផ្សេងៗទៀត ដោយសារខ្លួនបានឃើញឯកសាររបស់បក្សដែលមានសរសេរពីខ្មាំងយួន ខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង សេ.អ៊ី.អា. និងខ្មាំង កា.ហ្សេ.បេ. ជាដើម ។ សាក្សីបានបន្តថា ការកំណត់ខ្មាំងសត្រូវនោះមានតាំងពីមុនជំនាន់ប្រាំឆ្នាំទៅទៀត (ជំនាន់ លន់ នល់) ការរស់នៅពេលនោះមានការលំបាកដោយសារខ្មែរគ្នាឯងបានចាត់ទុកគ្នាជាខ្មាំងសត្រូវទៅវិញទៅមក ដោយមានការប្រយុទ្ធគ្នារវាងអ្នកតស៊ូនៅក្នុងព្រៃ និងនៅក្នុងស្រុក ។ ទាក់ទងនឹងខ្មាំងបីប្រភេទវិញ សាក្សីរៀបរាប់ថា កសិករមានការយល់ច្រឡំចំពោះពាក្យថា ខ្មាំង សេ.អ៊ី.អា. យួន ប៉ុន្តែតាមពិត សេ.អ៊ី.អា គឺអាមេរិក និង កា.ហ្សេ.បេ គឺសូវៀត ប៉ុន្តែនៅពេលនោះមានការប្រើប្រាស់ពាក្យនេះច្រឡំគ្នា ដូច្នេះការអនុវត្ត គឺមិនយល់ច្បាស់នោះទេ ។ ទាក់ទងនឹងពាក្យកម្ទេចវិញសាក្សីបានពន្យល់ថា កម្ទេចគឺ ការធ្វើឲ្យខ្ទេច ប៉ុន្តែបើនៅក្នុងន័យនយោបាយវិញការកម្ទេច គឺការវាយនៅលើសមរភូមិទៅវិញទៅមកចាត់ទុកគ្នាជាខ្មាំង ។ ចំពោះការផ្សព្វផ្សាយព័ត៌មានទាក់ទងនឹងការលើកលែងដល់ខ្មាំង សាក្សីបានបញ្ជាក់ថា ខ្លួនធ្លាប់បានឮនៅពេលមានការប្រកាសក្នុងពេលផ្សព្វផ្សាយនយោបាយ ដែលជាទូទៅធ្វើឡើងនៅក្នុងពេលប្រជុំ ។ ចំពោះសំណួររបស់ តំណាងសហព្រះរាជអាជ្ញាទាក់ទងនឹងគម្របទស្សនាវដ្តីដែលមានការកែប្រែទង់ប្រាំមកទង់មួយវិញនោះ សាក្សីបានបញ្ជាក់ថា លោកមិនបានដឹងពីមូលហេតុនោះទេ ដោយសារលោកមិនបានដឹងថាឯកសារនោះបោះពុម្ពនៅពេលណា ប៉ុន្តែលោកជឿថា ឯកសារនោះគឺពិតជាឯកសារនៅសម័យនោះមែន ។

### ២.១.៧) អង្គការ និងបក្សកុម្មុយនីស្តកម្ពុជា

តំណាងសហព្រះរាជអាជ្ញាបានបន្តសួរដោយលើកឡើងពីបទខុសនាមរបស់តំណាងបក្សនៅក្នុងឱកាសអបអរខួបលើកទី១៧ និងក្នុងឱកាសដែលបក្សប្រកាសជាផ្លូវការនៅក្នុងប្រទេស និងលើឆាកអន្តរជាតិ ដោយលោកចោទជាសំណួរពីភាពខុសគ្នារវាងពាក្យថា អង្គការ និង បក្សកុម្មុយនីស្តកម្ពុជា ។ ឆ្លើយតបនឹងបញ្ហានេះសាក្សី គឹម វុន បានបញ្ជាក់ថា អង្គការ និងបក្សកុម្មុយនីស្តជាពាក្យតែមួយ គ្រាន់តែពាក្យ “អង្គការ” មានន័យជារណសិរ្សច្រើនជាង ហើយចំណែក “បក្សកុម្មុយនីស្តកម្ពុជា” មានន័យជាផ្ទៃក្នុងបក្សច្រើនជាង ។ សាក្សីបានបន្តថា ហ៊ូ នឹម ធ្លាប់បានប្រាប់បុគ្គលិកនៅរោងពុម្ពឲ្យកែពាក្យពី “បក្ស” មក “អង្គការ” វិញ ដោយសារលោកចង់កែប្រែអត្ថបទរបស់បក្ស ដែលមានន័យថា បក្សកុម្មុយនីស្តកម្ពុជាត្រូវកែសម្រួលមកជាខ្លឹមសាររណសិរ្ស ដូច្នេះការផ្លាស់ប្តូរ នេះគ្រាន់តែជាការផ្លាស់ប្តូររូបភាពប៉ុណ្ណោះ ចំណែកខ្លឹមសារគឺនៅដដែល ។

### ២.១.៨) សេចក្តីថ្លែងការណ៍របស់ ខៀវ សំផន

តំណាងសហព្រះរាជអាជ្ញាបានបន្តសួរទាក់ទងនឹងឯកសារដែលនិយាយអំពីខួប១៧មេសា ។ សាក្សីបានបញ្ជាក់ថា នៅក្នុងក្រសួងរបស់ខ្លួនគឺមានការប្រារព្ធពិធីរំឭកខួបរបស់បក្ស ហើយនៅក្នុងឯកសារនោះ ទៀតសោតមិនមែនជាអត្ថបទរបស់ ខៀវ សំផន នោះឡើយ ដោយសារអត្ថបទរបស់ ខៀវ សំផន គឺមាននិយាយ



ខៀវ សំផន នៅក្នុងបន្ទប់សវនាការ

ឃ្លាវែងៗ ហើយមិនមានខណ្ឌទេ ។ ទាក់ទងនឹងសំណួរបន្ទាប់របស់តំណាងសហព្រះរាជអាជ្ញាអំពីការជួបគ្នារវាងសាក្សី និង ខៀវ សំផន ។ សាក្សីបានបញ្ជាក់ថា ខ្លួនមិនបាននៅជាមួយ ខៀវ សំផន

ទេ ដោយសារខ្លួនបានធ្វើការនៅក្រសួងឃោសនាការនៅក្នុងជំនាន់បីឆ្នាំ ហើយធ្លាប់បានជួប ខៀវ សំផន នៅក្នុងសម័យនោះដោយចៃដន្យតែប៉ុណ្ណោះ ។ សាក្សីបានបញ្ជាក់ថា ខ្លួនមិនដែលបានជួប ខៀវ សំផន នៅក្នុងក្រសួងពាណិជ្ជកម្មទេ ហើយទាក់ទងនឹងកិច្ចប្រជុំរបស់គណៈអចិន្ត្រៃយ៍ និងគណៈមជ្ឈិមវិញនោះខ្លួនក៏មិនបានចូលរួមនោះដែរ ។

## ២.១.៩) ការបាត់ខ្លួនប្រពន្ធសាក្សី គឹម វ៉ុន

សំណួរបន្ទាប់របស់តំណាងសហព្រះរាជអាជ្ញា គឺទាក់ទងនឹងការចាប់ខ្លួនប្រពន្ធរបស់សាក្សីឈ្មោះ ឈឹម ចាន់ណារី ដោយសារអង្គការបញ្ជូនយកទៅរៀនសូត្រ ។ ឆ្លើយតបនឹងបញ្ហានេះ សាក្សីបានបញ្ជាក់ថា ខ្លួនមិនបានដឹងពីរឿងចាប់ខ្លួននោះទេ ដោយសារកាលនោះគ្រួសាររបស់លោកមានការផ្លាស់ប្តូរការងារច្រើន ហើយចំណែកលោកក៏បានផ្លាស់ទីកន្លែងធ្វើការច្រើនកន្លែងដែរ ដូចជានៅក្នុងមន្ទីរ២៥ដល់មន្ទីរ២៩ ។ សាក្សីបានបន្តរៀបរាប់ដោយខ្សឹបខ្សួលថា នៅពេលនោះប្រពន្ធលោកត្រូវបានផ្លាស់ទៅក្រសួងឃោសនាការធ្វើជាអ្នកអានវិទ្យុ ហើយក្រោយមកធ្វើជាជំនួយការ យុន យ៉ាត និងជាអ្នកកត់បញ្ជីប្រវត្តិរូបរបស់យុទ្ធជនយុទ្ធនារី និងគ្រូបង្រៀនក្មេងៗ ហើយចាប់ពីពេលនោះមកខ្លួនបែកគ្នាជាមួយគ្រួសាររហូត ។ សាក្សីបានបន្តថា នៅពេលនោះលោកបានទៅសួរអ្នកដែលធ្វើការនៅកន្លែងដែលប្រពន្ធលោកត្រូវបានបញ្ជូនឲ្យទៅរៀនសូត្រ ពេលនោះលោកត្រូវបានប្រាប់ឲ្យត្រឡប់មកវិញ ។ សាក្សីបន្តថា នៅពេលនោះខ្លួនមានកូនស្រីមួយអាយុមួយខួបតែប៉ុណ្ណោះ ហើយក្រោយមកខ្លួនមិនបានដឹងថាមានរឿងអ្វីកើតឡើងចំពោះប្រពន្ធ និងកូនខ្លួននោះទេ ប៉ុន្តែក្រោយមក យុន យ៉ាត បានប្រាប់ថា ប្រពន្ធរបស់ខ្លួន គឺជា សេ.អ៊ី.អា ។ សាក្សីបានបញ្ជាក់ថា ប្រពន្ធរបស់ខ្លួនមិនមែនជាគិញអ៊ីនោះទេ ។ សាក្សី



កម្មាភិបាលខ្មែរក្រហមនៅក្នុងបន្ទប់ផ្សាយសំឡេង (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

បានបន្តថា មានការបាត់ខ្លួនមនុស្សជាច្រើនផ្សេងៗទៀត ដូចជា ប៉ង់, កត់ និង ឆយ ។ កត់ គឺជាអនុប្រធានមន្ទីរឃោសនាការ ហើយនៅពេលនោះប្រពន្ធរបស់ខ្លួន គឺជាអនុប្រធានខាងការងារបច្ចេកទេសខាងវិទ្យុ ។ ចំពោះសំណួរទាក់ទងនឹងការចាប់ខ្លួន កុយ ធួន សាក្សីបានបញ្ជាក់ថា ខ្លួនបានដឹងរឿងនោះតាមរយៈការអានឯកសារទង់បដិវត្តតែប៉ុណ្ណោះ ។

### ២.១.១០) ការងារនៅកន្លែងផ្សាយវិទ្យុ

លោកតំណាងសហព្រះរាជអាជ្ញាបានបន្តសាកសួរទាក់ទងនឹងការងាររបស់សាក្សីជាប្រធានវិទ្យុកម្ពុជាក្រោម ។ សាក្សី គីម វុន បានបញ្ជាក់ថា ខ្លួនពិតជាបានទៅធ្វើការនៅក្នុងក្រសួងឃោសនាការ ប៉ុន្តែមានការបែងចែកជាផ្នែកៗតាមភាសាផ្សេងៗ ដែលនៅក្នុងនោះមានកម្មវិធីផ្សាយជាភាសាវៀតណាម ដែលផ្សព្វផ្សាយពីចម្លើយសារភាព ដោយមានសំឡេងផ្ទាល់របស់កងទ័ពដែលមានប្រភពចេញពីព្រំដែន និងចម្លើយសារភាពរបស់ឈ្លើយសឹកវៀតណាម ។ សាក្សីបានបន្តថា ពេលនោះខ្លួនមិនមានលទ្ធភាពចូលទៅដល់ទឹកដីវៀតណាម ឬទឹកដីកម្ពុជាក្រោមទេ ដូច្នេះចម្លើយសារភាពណាដែលជាភាសាវៀតណាមដែលខ្លួនមិនអាចយល់បាន គឺត្រូវមានការសួរនាំពីខាងបកប្រែភាសាវៀតណាម ។

តំណាងសហព្រះរាជអាជ្ញាបានបន្តសួរទាក់ទងនឹងប្រពន្ធរបស់សាក្សី ហើយសាក្សីបានបញ្ជាក់ថា រហូតមកដល់ពេលនេះ លោកនៅតែមិនទាន់បានទទួលព័ត៌មានពីប្រពន្ធរបស់លោកនៅឡើយទេ ។ ភ្លាមៗនោះ តំណាងសហព្រះរាជអាជ្ញាបានស្នើសុំបង្ហាញឯកសារព័ត៌មានដែលពាក់ព័ន្ធនឹងគ្រួសាររបស់សាក្សី ដោយតំណាងសហព្រះរាជអាជ្ញាបានបញ្ជាក់ថា ការបង្ហាញឯកសារនេះ គឺនៅក្នុងន័យមនុស្សធម៌តែប៉ុណ្ណោះ ។ នៅក្នុងករណីនេះដែរក៏មានការលើកឡើងជំទាស់ដោយមេធាវីទាំងបីក្រុម និងដើមបណ្តឹងរដ្ឋប្បវេណីចំពោះទង្វើរបស់តំណាងសហព្រះរាជអាជ្ញាដោយអះអាងថា ប្រសិនបើនៅក្នុងន័យមនុស្សធម៌នោះ ព្រះរាជអាជ្ញាគួរតែបង្ហាញឯកសារនោះនៅខាងក្រៅបន្ទប់សវនាការវិញទើបជាការសមគួរ ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ លោកប្រធានបានបង្គាប់ឲ្យតំណាងសហព្រះរាជអាជ្ញាផ្តល់ឯកសារនោះជូនសាក្សីនៅក្រៅបន្ទប់សវនាការវិញ ។

### ៣) ការសួរដេញដោលសាក្សីដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

លោកស្រីមេធាវី បេនី យេ បានចាប់ផ្តើមសួរសាក្សីទាក់ទងនឹងស្ថានភាពនៅក្នុងទីក្រុងភ្នំពេញនៅពេលសាក្សីបានចូលមកដំបូង ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា នៅពេលខ្លួនមកដល់ មិនឃើញមានមនុស្សច្រើនទេ គឺមានតែទាហានតែប៉ុណ្ណោះ ។ នៅពេលនោះខ្មែរក្រហមបានយកវិទ្យុផ្សាយសំឡេងចេញមកមុន ហើយខ្លួនមកតាមក្រោយ ។ ចំពោះសំណួរទាក់ទងនឹងការងារនិពន្ធ សាក្សីបានបញ្ជាក់ថា ផ្នែកនិពន្ធគឺជាការងារសំខាន់របស់ខ្លួនតាំងពីមុនមកម្ល៉េះ ប៉ុន្តែពេលខ្លះខ្លួនបានចូលរួមធ្វើការនិពន្ធជាមួយ ហ៊ូ នឹម ឬ ទីវ អុល ដែរ ប៉ុន្តែក្រោយមកលោកត្រូវបានចាត់តាំងឲ្យចូលរួមនៅក្នុងផ្នែកនិពន្ធនៅឆ្នាំ១៩៧៥ ។

សាក្សី គីម វុន បានបញ្ជាក់ថា ខ្លួនបានធ្វើការនៅខាងរោងពុម្ពផង និងខាងសិល្បៈផង ដូចជាចំរៀងជាដើម ។ ចំពោះការងារខាងនិពន្ធ លោកបានយកអត្ថបទជាឯកសាររបស់បក្សនោះមកសរសេរដើម្បីឲ្យចេញជាអត្ថបទរណសិរ្សវិញ ។ ចំពោះអត្ថបទដែលនិពន្ធនោះមិនមាននិយាយពីការជម្លៀសប្រជាជនចេញពី



មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី បេនី យេ

ទីក្រុងភ្នំពេញនោះទេ ប៉ុន្តែមាននិយាយអំពីការកសាងប្រទេសជាតិជាដើម ។ ចំណែកការផ្សារផ្សេងទៀត មានដូចជាការផ្សារថតរូបដើម្បីចុះនៅក្នុងការសែត ។ សាក្សីបានបញ្ជាក់ថា ខ្លួនមានចម្ងល់ចំពោះការបញ្ជូនសម្ភារៈទៅថ្នាក់មូលដ្ឋាន ដែលពេលខ្លះសម្ភារៈទាំងនោះមិនត្រូវបានទៅដល់ប្រជាជននៅថ្នាក់មូលដ្ឋាននោះទេ ។ ដូច្នេះ ព័ត៌មានទាំងនេះត្រូវបានយកទៅផ្សព្វផ្សាយដល់មហាជនថែមទៀត ។ សាក្សីបានបន្តថា ភាពខុសគ្នារវាងការសរសេរទស្សនាវដ្តីទង់បដិវត្ត និងការសរសេរកាសែត គឺថាការសរសេរទស្សនាវដ្តីទង់បដិវត្តជាការនិយាយរៀបរាប់ពីនយោបាយ ។ ចំពោះកាសែតក៏ដូចគ្នានឹងទស្សនាវដ្តីដែរ អ្នកដែលអាចមើលបានគឺមានតែកម្មាភិបាលតែប៉ុណ្ណោះ ។ ចំពោះលោកផ្ទាល់ក៏ធ្លាប់បានអានឯកសារទាំងនោះដែរ ដោយសារលោកគឺជាកម្មាភិបាលម្នាក់ក្នុងក្រុមយុវកក ។ ចំពោះឯកសារដែលមានរូបភាពវិញ គឺជាឯកសារចំហរដែលអាចឲ្យមហាជនមើលបាន ។ នៅក្នុងការសរសេរ គឺជាការត្រូវសំរាយ ដូចជាការរៀបរាប់អំពីការធ្វើស្រែ១ហិចតាឲ្យបាន៣តោនដើម្បីសម្រួលឲ្យអ្នកអានងាយយល់ ។ ទាក់ទងនឹងការប្រមូលព័ត៌មាន សាក្សីបានបញ្ជាក់ថា មុនពេលចុះទៅតាមតំបន់ម្តងៗ លោកបានពិភាក្សាជាមួយគណៈតំបន់ជាមុនពីព្រោះតំបន់ខ្លះមិនមែនសុទ្ធតែអនុញ្ញាតឲ្យចុះទៅនោះទេ ។

លោកស្រីមេធាវីបានបន្តសួរទាក់ទងនឹងតំបន់ ដែលសាក្សីផ្តោតក្នុងការសរសេរអត្ថបទនោះ ។ ឆ្លើយតបតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា ក្នុងការសរសេរអត្ថបទ គឺចាំបាច់ត្រូវតែចុះទៅតាមតំបន់នោះផ្ទាល់ ឃើញពីស្ថានភាពជាក់ស្តែង ទើបអាចសរសេរបានល្អ ។ លោកបានបញ្ជាក់ថា ចំពោះនិស្សិតដែលទើបតែរៀនចប់ មិនអាចសរសេរបានឡើយ ទាល់តែអ្នកទាំងនោះត្រូវចុះទៅប្រឡូកធ្វើការជាមួយប្រជាជន ទើបអាចដឹងពីការលំបាកហើយអាចសរសេរអត្ថបទបានល្អ ។ នៅពេលចុះតាមតំបន់នោះ សាក្សីមិនបានឃើញប្រជាជនរស់នៅក្នុងស្ថានភាពលំបាកអត់ឃ្លានគោកយ៉ាកអ្វីទេ ដោយសារខ្មែរក្រហមនាំទៅមើលតែកន្លែងដែលមានអាហារហូបចុកគ្រប់គ្រាន់តែប៉ុណ្ណោះ ។ លោកស្រីមេធាវីបានស្នើឲ្យសាក្សីធ្វើការបញ្ជាក់អំពីពាក្យ ប្រជាជនថ្មី ។ សាក្សីបានរៀបរាប់ថា ប្រជាជនថ្មី គឺសំដៅលើអ្នកដែលត្រូវបានជម្លៀសមកពីទីក្រុងភ្នំពេញ ។ សាក្សីបានរៀបរាប់បន្ថែមថា នៅក្នុងទស្សនាវដ្តីទង់បដិវត្ត មិនមានសរសេររៀបរាប់ទាក់ទងនឹងប្រជាជនថ្មី ឬប្រជាជនចាស់ទេ ដោយសារកម្ពុជាប្រជាធិបតេយ្យមានការយកចិត្តទុកដាក់ខ្លាំងលើការផ្សព្វផ្សាយ ដូច្នេះរាល់ការសរសេរមានការកែប្រែការប្រើប្រាស់ពាក្យពេជន៍ច្បាស់លាស់ធ្វើយ៉ាងណាឲ្យប្រជាជនអាចយល់បាន ។ ចំណែកការថតរូបវិញក៏ដូចគ្នាដែរ គឺមានការប្រុងប្រយ័ត្នបំផុត ដែលទាមទារឲ្យមានការរៀនសូត្រពីបច្ចេកទេស និងនយោបាយថែមទៀត ។

## ៤) ការសួរដេញដោលសាក្សីដោយចៅក្រម ហ្សង់ម៉ាក ឡាវីញ

លោកចៅក្រម ហ្សង់ម៉ាក បានសាកសួរសាក្សីទាក់ទងនឹងការផ្សាយរបស់វិទ្យុណសិរ្សអំពីសេចក្តីថ្លែងការណ៍របស់ ខៀវ សំផន ដែលចូលរួមសរសេរដោយសម្តេច សីហនុ ។ ទាក់ទងនឹងបញ្ហានេះ សាក្សីបានបញ្ជាក់ថា ខៀវ សំផន ពិតជាបានចូលរួមក្នុងការសរសេរនោះមែន ។ លោកចៅក្រមបានបន្តការសាកសួរទាក់ទងនឹងជំនួបរវាង ខៀវ សំផន និងសម្តេច សីហនុ ។ សាក្សីបានបញ្ជាក់ថា ធម្មតានៅក្នុងរណសិរ្សរួមរួមជាតិមានសម្តេច សីហនុជាប្រធាន ដូច្នេះបើមិនមានការសម្រេចពីថ្នាក់លើទេ ថ្នាក់ក្រោមក៏មិនអាចចេញសេចក្តីថ្លែងការណ៍បានដែរ ។ លោកចៅក្រមបានបន្តលើកឡើងពីការឆ្លើយរបស់សាក្សីដែលបង្ហាញថា ឯកសារ



ចៅក្រម ហ្សង់ម៉ាក ឡាវីញ

ដែលសរសេរដោយ ខៀវ សំផន គឺជាអត្ថបទដែលសរសេរវែងៗ ហើយសាក្សីបានទទួលស្គាល់ចំពោះការលើកឡើងនេះ ។ លោកចៅក្រមបានលើកឡើងអំពីសម្ដីរបស់សាក្សី ដែលបានឆ្លើយនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតអំពីស្ថានភាពរបស់ ខៀវ សំផន ដែលជាដំរីពិការជើងមិនមានអំណាចនោះ សាក្សីក៏បានទទួលស្គាល់នូវការបញ្ជាក់របស់ខ្លួនពីមុនដែរ ។ សាក្សីបានបញ្ជាក់ថា ខ្លួនបានជួប ខៀវ សំផន ដោយចៃដន្យពេលដែល ខៀវ សំផន កំពុងជិះឡានដែលមានសម្ដេចឪ និងសម្ដេច ប៉ែន នុត រួមដំណើរជាមួយក្នុងឡាននោះដែរ ។ ចំពោះសំណួរទាក់ទងនឹងតួនាទីរបស់ ខៀវ សំផន នៅមន្ទីរក-៣ និងនៅមន្ទីរ៨៧០ សាក្សីបានបញ្ជាក់ថា ខ្លួនមិនបានដឹងពីតួនាទីអ្វីទាំងអស់ ដោយសារខ្លួនធ្វើការតែក្នុងក្រសួងរបស់ខ្លួនប៉ុណ្ណោះ ។ ចំពោះការអះអាងថា ខៀវ សំផន មិនមានតួនាទីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះ សាក្សីបានបញ្ជាក់ថា តាមរយៈការវាយតម្លៃរបស់ខ្លួន ខៀវ សំផន មិនមានទ្រព្យសម្បត្តិអ្វីទេ ដូច្នេះខ្លួនធ្វើការសន្និដ្ឋានដូច្នេះ ។ បន្ទាប់មកលោកចៅក្រមបានសួរបន្តទាក់ទងនឹង នួន ជា ដែលមានតួនាទីខាងអប់រំ ។ សាក្សីបញ្ជាក់ថា នៅអំឡុងពេលនោះ នួន ជា បានយកសៀវភៅមកបង្រៀនម្ដងមួយទំព័រៗ ដើម្បីអប់រំខាងផ្នែកកសិកម្ម ។ សាក្សីបានបន្ថែមថា កម្មវិធីរបស់ នួន ជា គឺបង្រៀនផ្នែកកសិកម្ម ដោយសារនៅពេលនោះមិនមានវត្តមានរបស់ យុន យ៉ាត ។ ចំពោះទំនាក់ទំនងរវាងក្រសួងឃោសនាការ និងឃោសនាអប់រំ សាក្សីបានបញ្ជាក់ថា ក្រសួងទាំងពីរនោះមិនមានទំនាក់ទំនងនឹងគ្នាទេ ។ សាក្សីបានបន្តថា កម្មវិធីផ្សាយរបស់វិទ្យុកម្ពុជាប្រជាធិបតេយ្យ គឺមានមនុស្សយកឯកសារទៅឲ្យផ្នែកក-៣៣ ដើម្បីអាន និងធ្វើការចាក់ផ្សាយ ។ ជាងនេះទៀតមានកម្មវិធីមួយជាភាសាអង់គ្លេសក៏ត្រូវបានចាក់ផ្សាយចេញពីវិទ្យុនោះដែរ ។ លោកចៅក្រមបានបន្តសួរពីការផ្សាយសុន្ទរកថារបស់ អៀង សារី ។ ឆ្លើយតបនឹងសំណួរនេះសាក្សីបានបញ្ជាក់ថា ខ្លួនបានដឹងតែការងាររបស់ខ្លួនតែប៉ុណ្ណោះ ដោយមិនចាប់អារម្មណ៍ពីការផ្សាយផ្សេងទៀតទេ ។ ទាក់ទងនឹង ហ៊ូ នឹម វិញ សាក្សីបានបញ្ជាក់ថា ខ្លួនបានស្គាល់ ហ៊ូ នឹម នៅជំនាន់ប្រាំឆ្នាំនៅប-២០ តែប៉ុណ្ណោះ ។

បន្ទាប់មក លោកចៅក្រមបានសាកសួរសាក្សីទាក់ទងនឹងការបោះពុម្ពទស្សនាវដ្ដីទង់យុវជនយុវនារី ។ សាក្សីបានរៀបរាប់ថា នៅក្នុងរោងពុម្ពនោះមានបោះពុម្ពទស្សនាវដ្ដីបីប្រភេទ គឺទស្សនាវដ្ដីរណសិរ្ស ទស្សនាវដ្ដីទង់បដិវត្ត និងទស្សនាវដ្ដីទង់យុវជន យុវនារី ។ ទស្សនាវដ្ដីទង់យុវជនយុវនារី បោះពុម្ពនៅឆ្នាំ១៩៧២-១៩៧៣បំរើឲ្យខាងសម្ព័ន្ធយុវកក ។ សាក្សីបានបញ្ជាក់ថា ទង់នោះសរសេរដោយ យុន យ៉ាត ដែលមានប្រពន្ធរបស់ខ្លួន(សាក្សី) ជាជំនួយការ ។ ចំណែកក្រុមរបស់ខ្លួនក៏បានជួយសរសេរជាលិខិតជូនដំណឹងផ្សេងៗដែរ ។ ទស្សនាវដ្ដីនោះមានគោលបំណងអប់រំយុវជនដែលមានអាយុ១៨ឆ្នាំឡើងទៅ ដើម្បីឲ្យអ្នកទាំងនោះបានយល់ដឹងច្រើនជាងប្រជាជនសាមញ្ញ ។ លោកចៅក្រម បានធ្វើការតាំងសំណួរចុងក្រោយទាក់ទងនឹងអំណាចរបស់ ខៀវ សំផន ដែលសាក្សីបានដឹងកន្លងមក ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា លោកបានដឹងរឿង ខៀវ សំផន នៅពេលរៀននៅសាលា ហើយដោយសារលោកមានបងប្អូននៅធ្វើការជាមន្ត្រីរាជការបាននិយាយប្រាប់ថា ខៀវ សំផន ជាមន្ត្រីជាន់ខ្ពស់ ប៉ុន្តែមិនមានជីវភាពធូរធារនោះទេ ។ ទាក់ទងនឹងវត្តមានរបស់ ខៀវ សំផន នៅរោងពុម្ពនៅក្នុងព្រៃមុនឆ្នាំ១៩៧៥នោះ សាក្សីបានបញ្ជាក់ថា ខៀវ សំផន បានមកដល់រោងពុម្ពមួយរយៈ ដោយសារពេលនោះរោងពុម្ពត្រូវបានពង្រីក និងត្រូវការបុគ្គលិកច្រើន ។ ដូច្នេះមានវត្តមានកម្មាភិបាលច្រើននាក់ផ្សេងទៀតនៅទីនោះ ។

## ៥) ការសួរដេញដោលសាក្សីដោយមេធាវីការពារក្ដីទាំងបីក្រុម

អង្គជំនុំជម្រះបានបន្តប្រគល់វេទិកាជូនក្រុមមេធាវីការពារក្ដីទាំងបីក្រុមដើម្បីសាកសួរលើសាក្សី ដោយចាប់ផ្ដើមពីក្រុមមេធាវីការពារក្ដី ខៀវ សំផន និងបន្តទៅក្រុមមេធាវី នួន ជា និង អៀង សារី ។

### ៥.ក) ក្រុមមេធាវីការពារក្ដី ខៀវ សំផន

### ៥.ក.១) មេធាវីជាតិ

បន្ទាប់ពីបញ្ចប់ការសាកសួរសាក្សី ដោយលោកចៅក្រម ហ្វង់ម៉ាក្ស ឡាវែញ រួចមកលោកប្រធានបានប្រគល់វេទិកាជូនក្រុមមេធាវីការពារក្ដីជនជាប់ចោទ ខៀវ សំផន ។

មេធាវី គង់ សំអុន បានលើកឡើងនូវសំណួរមួយចំនួន

ដែលទាក់ទងនឹងការចំណាំរបស់សាក្សីលើរូបជនជាប់ចោទ ខៀវ សំផន ។ តាមរយៈការអះអាងរបស់សាក្សីដែលបានអះអាងថា



មេធាវីការពារក្តី គង់ សំអុន

ពេលខ្លួនបានជួបជនជាប់ចោទដំបូងនោះខ្លួនមិនបានស្គាល់ថា ជា ខៀវ សំផន នោះទេ ប៉ុន្តែក្រោយមកលោកបានធ្លាប់ស្តាប់រឿងរ៉ាវរបស់ ខៀវ សំផន ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា ខ្លួនពិតជាបានស្តាប់រឿងរ៉ាវរបស់ ខៀវ សំផន តាមរយៈការនិទាននោះមែន ប៉ុន្តែខ្លួនមិនបានដឹងពីគោលបំណងនៃការនិយាយនោះទេ ។ សាក្សីបានបន្តថា សាច់រឿងដែលនិយាយនោះ គឺបង្ហាញថា ខៀវ សំផន មិនមានសិទ្ធិអំណាចអ្វីឡើយ ប៉ុន្តែ ខៀវ សំផន នឹងក្លាយជាប្រធានាធិបតី ។ មេធាវីបានបន្តសួរទាក់ទងនឹងការជួបជាមួយ ខៀវ សំផន ។ សាក្សីបានបញ្ជាក់ថា នៅឆ្នាំ១៩៧១ខ្លួនមិនដែលជួប ខៀវ សំផន នៅរោងពុម្ពនៅក្នុងព្រៃទេ ។ ក្រោយមកមានការពង្រីករោងពុម្ពដោយសារនៅទីនោះមានបុគ្គលិកច្រើន មានទាំងកម្មាភិបាល និងខៀវ សំផន ដែលស្នាក់នៅទីនោះមួយរយៈផង ។ សាក្សីបានបញ្ជាក់ថា នៅពេលនោះ ខ្លួនមិនស្គាល់ ខៀវ សំផន ទេ ប៉ុន្តែគាត់ដឹងដោយសារឈ្មោះ បាន គឺជាអ្នកប្រាប់ ហើយក្រោយមកឈ្មោះ បានកត់សម្គាល់ឃើញថា ខៀវ សំផន គឺជាមនុស្សល្អចេះលើកទឹកចិត្តក្មេងៗ និងមិនប្រកាន់ខ្លួន ។ ជាងនេះទៀត ឈ្មោះ បាន គោរព ខៀវ សំផន ដោយសារនៅពេលនោះ ខៀវ សំផនគឺជាគំរូដ៏ល្អដែលធ្វើឲ្យលោកយកតម្រាប់តាម ។ ខៀវ សំផនក៏ធ្លាប់បានបង្រៀនពីសីលធម៌ទាំង ១២ប្រការដល់ខ្លួនដែរ ។

មេធាវីបានបន្តលើកឡើងទាក់ទងនឹងសំណេររបស់ ខៀវ សំផន ដែលសាក្សីបានបញ្ជាក់ថា រាល់ការសរសេររបស់អ្នកដឹកនាំទាំងអស់ គឺសុទ្ធតែខុសៗគ្នា ប៉ុន្តែចំពោះការសរសេររបស់ ខៀវ សំផន វិញ គឺខុសពីការសរសេររបស់អ្នកដឹកនាំផ្សេងទៀត ដោយសារតែសំណេរនោះមានប្រវែងវែង សរសេរដោយដៃ និងមិនសូវមានសញ្ញាខណ្ឌច្រើន ។ ដូច្នេះ សាក្សីបានបញ្ជាក់ថា រាល់សេចក្តីថ្លែងការណ៍ទាំងអស់មិនមែនធ្វើឡើងដោយ ខៀវ សំផន តែម្នាក់នោះទេ ពីព្រោះនៅក្នុងសេចក្តីថ្លែងការណ៍នោះមានសំណេរខ្លីៗដែរ ។

មេធាវីបានបង្វែរប្រធានបទទាក់ទងនឹងដំណើរទស្សនកិច្ចនៅជនបទរបស់ ខៀវ សំផន ជាមួយ សម្តេចសីហនុ ។ ទាក់ទងនឹងចំណុចនេះ សាក្សី គីម វ៉ុន បានបញ្ជាក់ថា នៅពេលនោះខ្លួនបានស្គាល់ ខៀវ សំផន ច្បាស់ដោយសារខ្លួនធ្លាប់បាននៅជាមួយ ខៀវ សំផន និងបានជួបជាមួយ ខៀវ សំផន ដោយសារខ្លួនចុះទៅថតរូបនៅជាយក្រុងភ្នំពេញ ។ សាក្សីបានបន្តឆ្លើយនូវសំណួររបស់មេធាវីទាក់ទងនឹងតួនាទី និងអំណាចរបស់សម្តេច សីហនុ ដោយសាក្សីបញ្ជាក់ថា ពេលនោះលោកយល់ថា ខៀវ សំផន មានអំណាចដូចព្រះអង្គដែរ គឺមានអំណាចក៏ដូចជាអត់អំណាចដែរ ។ សាក្សីបានបន្តថា ខ្លួនបានដឹងរឿងនេះ ដោយសារខ្លួនបានឃើញឯកសារបោះពុម្ពជាភាសាបរទេសនៅមន្ទីរប-២៧ ដែលនិយាយអំពីការលាលែងពីតំណែងរបស់សម្តេច ហើយនៅពេលនោះ ខៀវ សំផន ត្រូវបានតែងតាំងឲ្យឡើងកាន់តំណែងជំនួសព្រះអង្គ ។ ទោះជាយ៉ាងណាក៏ដោយសាក្សីមិនបានដឹងថា នរណាជាអ្នកតែងតាំង ខៀវ សំផន ធ្វើជាប្រមុខរដ្ឋឡើយ ។ ទាក់ទងនឹងការដកតំណែង និងដាក់ពិន័យលើរូបកម្មាភិបាល សាក្សីបានបញ្ជាក់ថា ករណីនេះខ្លួនបានដឹងតាមរយៈឈ្មោះ ធុច រិន ដែលជាបញ្ញវ័ន្តធ្វើការនៅកំពង់សោម ដែលបានរៀបរាប់ពីការដាក់ពិន័យមកលើរូបខ្លួន ហើយនៅពេលនោះបាន ខៀវ សំផន ជាអ្នកជួយ ។

### ៥.ក.២) មេធាវីអន្តរជាតិ

បន្ទាប់ពីបញ្ចប់ការសាកសួររបស់មេធាវី គង់ សំអុន មេធាវីអន្តរជាតិ អង់តា ហ្គីសេ បានបន្តការសាកសួរទាក់ទងនឹងមូលហេតុដែលសាក្សីបានចូលធ្វើការក្នុងរណសិរ្ស ។ ឆ្លើយតបនឹង



មេធាវីការពារក្តី អង់តា ហ្គីសេ

សំណួរនេះសាក្សី គឹម វុន បានបញ្ជាក់ថា ខ្លួនបានចូលរួមដោយនៅពេលនោះស្ថានភាពនៅក្នុងប្រទេសកម្ពុជាមានការលំបាកដូចជាមានការទម្លាក់គ្រាប់បែក ហើយប្រជាជនមិនចង់ឲ្យមានការទម្លាក់សម្តេច សីហនុ ដោយរបប លន់ នល់ ដូច្នេះ ដោយស្មារតីស្រឡាញ់ និងគាំទ្រសម្តេចនៅពេលដែលមានការអំពាវនាវឲ្យប្រជាជនចូលក្នុងព្រៃម៉ាគី ខ្លួនក៏បានស្ម័គ្រចិត្តចូលរួមដែរ ដើម្បីគាំទ្រសម្តេច ។ សាក្សីបានបន្តថា នៅពេលនោះលោក គឺជាកូនកំព្រាដែលមិនងាយនឹងបែកពីម្តាយទេ ។ និយាយដល់ចំណុចនេះ សាក្សីមានការរន្ធត់ចិត្ត ដោយនឹកឃើញរឿងពីអតីតកាល លោកបានសម្រក់ទឹកភ្នែកនៅក្នុងបន្ទប់សវនាការ ។ បន្ទាប់មកអង្គជំនុំជម្រះបានផ្អាកប្រហែលជាប្រាំនាទី ទើបអនុញ្ញាតឲ្យមានការសួរសំណួរបន្តទៀត ។ មេធាវី ហ្គីសេ បានបន្តសួរសាក្សីទាក់ទងនឹងការជួបជាមួយនឹង ខៀវ សំផន នៅឯមន្ទីរបោះពុម្ព ។ ឆ្លើយតបនឹងករណីនេះ សាក្សីបានបញ្ជាក់ថា លោកបានឃើញ ខៀវ សំផន យកនំចំណីទៅឲ្យក្មេងៗនៅកន្លែងរបស់ខ្លួន ។ ចំពោះសំណួរទាក់ទងនឹងតួនាទីរបស់ ខៀវ សំផន នៅក្នុងរណសិរ្ស សាក្សីបានបញ្ជាក់ថា ខៀវ សំផន មានតួនាទីបន្ទាប់ពីសម្តេច សីហនុ ។

បន្ទាប់មក មេធាវី ហ្គីសេ បានស្នើឲ្យសាក្សីបញ្ជាក់អំពីសំណេររបស់ ប៉ុល ពត ។ សាក្សីបានរៀបរាប់ថា កិច្ចការនៅរោងពុម្ពនោះមានបីផ្នែក ដោយលោកទទួលខាងឯកសាររណសិរ្ស ឯអ្នកផ្សេងទៀតទទួលខាងធ្វើទស្សនាវដ្តីទង់បដិវត្ត ។ ជាធម្មតានៅលើឯកសារនីមួយៗសុទ្ធតែមានលេខកូដ ដូចជាប្រភេទឯកសារជាសេចក្តីថ្លែងការណ៍ ឬជាដំណឹង ប៉ុន្តែចំពោះឯកសារដែលចេញពីថ្នាក់លើ អត់មានដាក់លេខកូដទេ ដោយគ្រាន់តែមានចំណារថា បោះពុម្ពជាប្រញាប់ ។ សាក្សីបានស្គាល់សំណេរនោះតាមរយៈការសួរអ្នកដែលធ្វើការជាមួយ ម្យ៉ាងទៀតសាក្សីក៏បានឃើញសំណេរនោះជាញឹកញាប់ដែរ ។

ចំពោះសំណួររបស់មេធាវីទាក់ទងនឹងការចុះថតរូបនៅតាមជនបទ សាក្សីបានបំភ្លឺថា រាល់ការចុះទៅថតរូបនៅតាមជនបទ គឺលុះត្រាតែមានការអនុញ្ញាតពីថ្នាក់លើរបស់ខ្លួនគឺ យុន យ៉ាត ។ សាក្សីបានបន្តថា នៅពេលចុះយកព័ត៌មាន គឺលោកចង់ដឹងពីស្ថានភាពរស់នៅរបស់ប្រជាជន ប៉ុន្តែកន្លែងដែលលោកទៅ គឺប្រជាជនសុទ្ធតែមានបាយហូបគ្រប់គ្រាន់ ដូច្នេះលោកសន្និមថា ប្រជាជនទាំងអស់សុទ្ធតែមានបាយហូបគ្រប់ៗគ្នា ។

### ៥.ខ) ក្រុមមេធាវីការពារក្តី នួន ជា

#### ៥.ខ.១) មេធាវីជាតិ

មេធាវីជាតិការពារក្តីជនជាប់ចោទ នួន ជា គឺលោក សុន អរុណ បានចាប់ផ្តើមសួរសំណួរទាក់ទងនឹងការចូលរួមធ្វើបដិវត្តន៍របស់សាក្សី ។ ឆ្លើយតបនឹងសំណួរនេះ សាក្សី គឹម វុន បានបញ្ជាក់ថា លោកបានចូលរួមបដិវត្តន៍ដោយសារឪពុករបស់លោកគឺជាខ្មែរឥស្សរៈ ។ សាក្សីបានពន្យល់ថា ខ្មែរឥស្សរៈមិនមែនមានតែមួយក្រុមទេ គឺមានទាំងខាងសម្តេច សីហនុ និងខាងយៀកមិញ ហើយគ្រួសាររបស់លោក គឺនៅខាងសម្តេចសីហនុទាំងអស់ ។ នៅឆ្នាំ១៩៧០ ក្នុងរបប លន់ នល់ សាក្សី គឺជាអនុប្រធានក្រុមដប់ខ្នង ដោយសារឪពុករបស់លោកគឺជាមន្ត្រីរាជការ ។ នៅឆ្នាំ១៩៧១ ដោយមានការប្រកាសឲ្យចូលព្រៃនោះ ខ្លួនបានចូលធ្វើការនៅក្នុងរណសិរ្ស តាមរយៈ វង់ ជាអ្នកនាំចូល ។

បន្ទាប់មក លោកមេធាវីបានបន្តដោយលើកឡើងពីអ្នកដែលសរសេរទស្សនាវដ្ដីទង់បដិវត្ត ។ សាក្សីបានរៀបរាប់ថា លោកមិនបានដឹងថាអ្នកណាជាអ្នកសរសេរនោះទេ ពីព្រោះពេលនោះខ្លួនធ្វើការនៅខាងថតរូប ។ ទាក់ទងនឹងការសរសេរទង់បដិវត្ត សាក្សីបានបញ្ជាក់ថា នៅពេលសរសេរគឺមានការបែងចែកដូចជាក្រុមអ្នកសរសេរចម្លងដើម្បីយកទៅបោះពុម្ព ។ រីឯអ្នកនិពន្ធទស្សនាវដ្ដីយុវជន យុវនារី គឺ យុន យ៉ាត ហើយខ្លួនក៏បានចូលរួមនៅក្នុងការសរសេរនោះខ្លះដែរ ។ ចំណែកឯទស្សនាវដ្ដីទង់បដិវត្ត សាក្សីបានបញ្ជាក់ថា មានតែថ្នាក់លើប៉ុណ្ណោះ ដែលជាអ្នកសរសេរ ពីព្រោះថាទាក់ទងនឹងរឿងនយោបាយ ។


មេធាវីការពារក្ដី ស៊ុន អរុណ

គួរកត់សម្គាល់ថា នៅត្រង់ចំណុចនេះ មេធាវីបានលើកឡើងនូវសំណួរដដែលៗទាក់ទងនឹងរបៀបនៃការបោះពុម្ព ប៉ុន្តែការសាកសួរបែបនេះធ្វើឲ្យសាក្សីមានការភាន់ច្រឡំជាច្រើន ដូច្នេះសាក្សីមានការពិបាកក្នុងការផ្ដល់ចម្លើយ ។ ម្យ៉ាងទៀត ប្រធានអង្គជំនុំជម្រះក៏បានធ្វើការរំឭកដល់មេធាវីជាច្រើនដងដើម្បីរៀបចំសំណួរឲ្យបានល្អ ជៀសវាងការធ្វើឲ្យសាក្សីមានការភាន់ច្រឡំ ។

បន្ទាប់មក លោកមេធាវីបានបន្តសួរទាក់ទងនឹងប្រភេទទស្សនាវដ្ដីទង់បដិវត្តជាអក្សរដៃ និងអក្សរបោះពុម្ព ។ ឆ្លើយតបនឹងសំណួរនេះសាក្សីបានបញ្ជាក់ថា នៅក្នុងសម័យសង្គ្រាម៥ឆ្នាំ ឯកសារនោះជាឯកសារសរសេរដៃ ប៉ុន្តែនៅឆ្នាំ១៩៧៥វិញជាឯកសារដែលបោះពុម្ព ។ សាក្សីបានបន្តថា ទង់បដិវត្តនោះមានទ្រង់ទ្រាយដូចពីមុនទាំងអស់ គ្រាន់តែខុសផ្នែកបច្ចេកទេសតែប៉ុណ្ណោះ ។ នៅឆ្នាំ១៩៧៧ទស្សនាវដ្ដីនេះត្រូវបានកែប្រែរូបភាពដោយប្ដូរពីរូបទង់ប្រាំមកទង់មួយវិញ ។ លោកមេធាវីបានបន្តសួរទាក់ទងនឹងជនជាប់ចោទ នួន ជា ថាតើសាក្សីបានស្គាល់ នួន ជា ដែរឬទេ? សាក្សីបានបញ្ជាក់ថា ខ្លួនពិតជាបានស្គាល់ នួន ជា ដែលជាមនុស្សល្អមានចរិតល្អរួសរាយរាក់ទាក់ និងណែនាំក្នុងជីវភាពរស់នៅ ។

ឆ្លើយតបនឹងសំណួរបន្ទាប់ទាក់ទងនឹងរចនាសម្ព័ន្ធរបស់បក្សនៅឆ្នាំ១៩៧០-១៩៧៥ និងពីឆ្នាំ១៩៧៥-១៩៧៩ សាក្សីបានរៀបរាប់ថា នៅខាងបក្សមាន ប៉ុល ពត ទី១, នួន ជា ទី២ ។ ចំណែកនៅខាងរដ្ឋាភិបាលវិញមាន ប៉ុល ពត នៅលំដាប់ទី១, អៀង សារី ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកខាងកិច្ចការបរទេស និង សុន សេន ជារដ្ឋមន្ត្រីក្រសួងការពារជាតិ ។ ចំណែកខាងនីតិបញ្ញត្តិមាន នួន ជា ជាប្រធានសភាប្រជាជនកម្ពុជា ។ ក្រៅពីតួនាទីជាប្រធានសភា សាក្សីបានបញ្ជាក់ថា នួន ជា មានភារកិច្ចផ្សព្វផ្សាយការអប់រំពេល យុន យ៉ាត មិនមានវត្តមាន ។ ឆ្លើយតបនឹងសំណួរចុងក្រោយរបស់មេធាវីទាក់ទងនឹងឯកសាររចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យ សាក្សីបញ្ជាក់ថា ខ្លួនមិនបានចាប់អារម្មណ៍លើឯកសារនោះទេ ពីព្រោះកាលនោះខ្លួនគ្រាន់តែជាអ្នកសរសេរកាសែតតែប៉ុណ្ណោះ ។

### ៥.១.២) មេធាវីអន្តរជាតិ

បន្ទាប់ពីបញ្ចប់ការសាកសួររបស់មេធាវីជាតិ មេធាវីអន្តរជាតិ ហ្សាស្តេ ប៉ៅ បានបន្តការសាកសួរទាក់ទងនឹងការគ្រប់គ្រងក្រសួងទាំងពីរ គឺក្រសួងឃោសនាការ និងអប់រំ ដោយ យុន យ៉ាត ។ ទាក់ទងនឹងសំណួរនេះសាក្សី គឹម វ៉ុន បានបញ្ជាក់ថា ក្រសួងទាំងពីរបានរួមគ្នានៅចន្លោះឆ្នាំ១៩៧៧-១៩៧៨ ហើយការងារនៅពេលនោះមានការទាក់ទងគ្នារហូតដល់ឆ្នាំ១៩៧៩ ។ សាក្សីបានបន្តថា លោកត្រូវបានផ្លាស់ទៅធ្វើការជាប្រធានផ្នែកវិទ្យុកម្ពុជាក្រោមនៅឆ្នាំ១៩៧៨ បន្ទាប់ពីលោកធ្វើការនៅខាងផ្នែកកាសែតនៅក្នុងក្រសួងជាមួយគ្នា ប៉ុន្តែមានការបែងចែកជាការិយាល័យផ្សេងៗគ្នា ។



មេធាវីការពារក្តី ហ្សាស្ទី ជ៉ោ

បន្ទាប់មក មេធាវីបានបន្តការសាកសួររបស់ខ្លួនទាក់ទងនឹងតួនាទីរបស់ នួន ជា ។ សាក្សីបានរៀបរាប់ថា នៅក្រសួងឃោសនាការ នួន ជា គឺជាអ្នកណែនាំអប់រំនៅពេលដែល យុន យ៉ាត មិននៅតែប៉ុណ្ណោះ ។ សាក្សីបានបញ្ជាក់ថា ចំពោះសៀវភៅដែលនិយាយពីកសិកម្មដែល នួន ជា យកមកបង្រៀននោះ មានកំរាស់ក្រាស់ដូច្នេះហើយពេលបង្រៀនម្តងៗ នួន ជា បានដកស្រង់យកតែផ្នែកខ្លះៗប៉ុណ្ណោះមកបង្រៀន ។

### ៩.ត) ក្រុមមេធាវីការពារក្តី អៀង សារី

មេធាវី ម៉ៃឃើល កាណាវ៉ាស បានបន្តការសាកសួរបន្ទាប់ពីក្រុមមេធាវីការពារក្តី ខៀវ សំផន ដោយផ្តើការដកស្រង់នូវកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីដែលធ្វើជាមួយចៅក្រមស៊ើបអង្កេតទាក់ទងនឹងការបោះពុម្ពត្រាក់មុនពេលមានការចាប់ខ្លួន សោ ភីម ។ សាក្សី គឹម វុន បានបញ្ជាក់ថា ខ្លួនមិនបានចាំថ្ងៃខែដែលនិយាយពីការបោះពុម្ពត្រាក់នោះទេ ។ បន្ទាប់មក មេធាវីបានបន្តសួរទាក់ទងនឹងដំណើរការនៃការថតចម្លងខ្សែអាត់បទសម្ភាសន៍រវាងសាក្សីជាមួយសហចៅក្រមស៊ើបអង្កេត ក្នុងគោលបំណងរកឲ្យឃើញថា តើការសាកសួរនោះធ្វើឡើងក្នុងពេលថតសម្លេងជាខ្សែអាត់ ឬមុនពេលមានការថតសម្លេង? សាក្សីបានរៀបរាប់ថា លោកមិនចាំពីបច្ចេកទេសនៃការថតនោះទេ ហើយនៅពេលបញ្ចប់ការសម្ភាសន៍នោះ ចៅក្រមស៊ើបអង្កេតបានផ្តល់ឯកសារដល់ខ្លួនដើម្បីពិនិត្យ ។ លោកមិនបានពិនិត្យឯកសារទាំងអស់នោះទេ ដោយសារអស់កម្លាំងខ្លាំងបន្ទាប់ពីសម្ភាសន៍អស់រយៈពេលយូរ ប៉ុន្តែលោកបានអានឯកសារនោះ ហើយឃើញថានៅក្នុងឯកសារនោះមានសរសេរឈ្មោះកម្មាភិបាលខុស ។ បន្ទាប់មក មេធាវីបានបន្តសួរទាក់ទងនឹងចំនួននៃការសម្ភាសន៍ ។ សាក្សីបានបញ្ជាក់ថា លោកបានផ្តល់បទសម្ភាសន៍ចំនួនបីដង ប៉ុន្តែបទសម្ភាសន៍ដែលមានឯកសារនោះ គឺមានតែពីរលើកប៉ុណ្ណោះ ដោយសារនៅលើកទីបី ធ្វើឡើងក្នុងពេលលោកជាប់រវល់ប្រជុំ ។



មេធាវីការពារក្តី ម៉ៃឃើល កាណាវ៉ាស

ដូច្នេះលោកមិនទាន់បានផ្តល់បទសម្ភាសន៍នៅឡើយទេ ។ មុនពេលបញ្ចប់ការសាកសួររបស់ខ្លួន មេធាវី កាណាវ៉ាស បានបន្តសួរសំណួរមួយចំនួនទៀត ដែលទាក់ទងនឹងនីតិវិធីស្តាប់ចម្លើយសាក្សីដោយសហចៅក្រមស៊ើបអង្កេត ។ ប៉ុន្តែករណីនេះ ត្រូវបានប្រធានអង្គជំនុំជម្រះរំឭកថា ករណីនេះជានីតិវិធីនៅក្នុងដំណាក់កាលស៊ើបអង្កេតតែប៉ុណ្ណោះ ដូច្នេះបញ្ហាទាំងនេះមិនអាចជះឥទ្ធិពលមកលើកិច្ចដំណើរការសវនាការ ឡើយ ។

# សវនាការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន

## ថ្ងៃទី២៣-២៩ ខែសីហា ឆ្នាំ២០១២

នៅថ្ងៃទី២៣-២៩ ខែសីហា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបន្តបើកសវនាការស្ដាប់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន ។ ការស្ដាប់សក្ខីកម្មនេះបានចាប់ផ្ដើម បន្ទាប់ពីអង្គជំនុំជម្រះបានបញ្ចប់ការស្ដាប់សក្ខីកម្មរបស់សាក្សី គឹម វុន ។ ការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ បានប្រើពេលវេលាចំនួន៣ថ្ងៃ ដោយភាគីនីមួយៗបានផ្ដោតជាសំខាន់លើ ការចូលរួមក្នុងបដិវត្តន៍ ការបម្រើការងារជាគ្រូពេទ្យ និងការចូលរួមសិក្សានយោបាយនៅបុរីកីឡា ។ ការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន បានចាប់ផ្ដើមដោយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បន្ទាប់មកអង្គជំនុំជម្រះប្រគល់វេទិកាសួរដេញដោលជូនសហព្រះរាជអាជ្ញា និងមេធាវីការពារក្ដីជនជាប់ចោទទាំងបីក្រុម ។ ក្នុងអំឡុងពេលនៃការផ្ដល់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន ចៅក្រមអន្តរជាតិគឺលោកស្រីចៅក្រម ស៊ីលវៀ ខាតវ្រ៉ាយត៍ បានអវត្តមាន និងជំនួសដោយលោកស្រីចៅក្រម ក្លោឌៀ ហ្វិន ។ ចំណែកឯជនជាប់ចោទ អៀង សារី មានបញ្ហាសុខភាព និងមិនបានចូលរួមក្នុងសវនាការដោយផ្ទាល់ឡើយ គឺត្រូវចូលរួមស្ដាប់សវនាការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណីពីបន្ទប់រង់ចាំ ដែលស្ថិតនៅខាងក្រោមសាលសវនាការ ដោយមានបំពាក់ប្រព័ន្ធសោតទស្សន៍ ។



ដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន (ទី៦រាប់ពីឆ្វេង) ចូលរួមសវនាការថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ (រូបថតៈមជ្ឈមណ្ឌលឯកសារកម្ពុជា)

### ១) ប្រវត្តិសាវតាររបស់ដើមបណ្ដឹងរដ្ឋប្បវេណី

មុនពេលចាប់ផ្ដើម ប្រធានអង្គជំនុំជម្រះ គឺលោកចៅក្រម និល ណុន បានសាកសួរអំពីប្រវត្តិសាវតារ របស់ដើមបណ្ដឹងរដ្ឋប្បវេណី ។ ជាការឆ្លើយតប ដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន បានបញ្ជាក់ជូនអង្គជំនុំជម្រះថា នៅអំឡុងពេលនៃការចូលធ្វើបដិវត្តន៍ខ្លួនមានឈ្មោះ អៀប ឡុន បច្ចុប្បន្នមានអាយុ៦១ឆ្នាំ មានស្រុកកំណើតនៅភូមិត្រពាំងផ្លុង ឃុំជាច ស្រុកកំចាយមារ ខេត្តព្រៃវែង ។ សព្វថ្ងៃរស់នៅភូមិឈូកស ឃុំដូនតី ស្រុកពញាក្រែក ខេត្តកំពង់ចាម ប្រកបមុខរបរធ្វើស្រែចម្ការ ។ ឪពុកឈ្មោះ អ៊ូច សាអែម និងម្ដាយឈ្មោះ អៀប ស្រែម ។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន ធ្លាប់មានប្រពន្ធម្នាក់ឈ្មោះ អ៊ុង ណោង ប៉ុន្តែបានបាត់បង់ជីវិតក្នុងរបប

នោះ ។ ចំណែកឯពេលបច្ចុប្បន្ន លោកមានប្រពន្ធម្នាក់ទៀត ឈ្មោះ ស៊ឹម អ៊ី និងមានកូនសរុបទាំងអស់បីនាក់ ។ នៅក្នុងរបប កម្ពុជាប្រជាធិបតេយ្យ អែម អឿន បានបម្រើការងារជាគ្រូពេទ្យ មូលដ្ឋាននៅតំបន់២០ ។

បន្ទាប់មក ប្រធានអង្គជំនុំជម្រះ និល ណុល បានផ្ទេរវេទិកា ជូនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដើម្បីបន្តការសាកសួរ ។

### ២) ការសួរដេញដោលដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី



មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គីម ម៉េងឃី

មេធាវីជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន គឺមេធាវី គីម ម៉េងឃី ដែលបម្រើការនៅក្នុងក្រុមមេធាវីគ្មានព្រំដែន របស់ប្រទេសបារាំង បានចាប់ផ្តើមសំណួរដំបូងដោយផ្តោតលើ មូលហេតុដែលនាំឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានការយឺតយ៉ាវក្នុង ការដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះ មុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដើមបណ្តឹងរដ្ឋប្ប វេណី អែម អឿន បានបញ្ជាក់ថា ខ្លួនដាក់ពាក្យបណ្តឹងចំនួនពីរលើក លើកទី១គឺ ដាក់ពាក្យបណ្តឹងទាមទារភាពពិតនៃការអនុវត្តរបស់ តុលាការ និងលើកទី២ គឺដាក់ពាក្យបណ្តឹងតាមរយៈមជ្ឈមណ្ឌល ឯកសារកម្ពុជា ដោយសារខ្លួនមិនសូវចេះអក្សរទើបស្នើឲ្យបុគ្គលិក មជ្ឈមណ្ឌលឯកសារកម្ពុជាជួយសរសេរជូន។ អែម អឿន បាន បន្តអះអាងថា ខ្លួនមានការទទួលខុសត្រូវនូវអ្វីដែលបានលើកឡើង នៅក្នុងពាក្យបណ្តឹងនោះថាជាការពិត ដោយសារការរំពឹកឡើង វិញនូវការពិតនេះហើយ ជាហេតុនាំឲ្យមានការយឺតយ៉ាវក្នុងការ ដាក់ពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។

ឆ្លើយតបនឹងសំណួរដែលសួរទាក់ទងនឹងប្រវត្តិរូបរបស់ខ្លួន អែម អឿន បានបញ្ជាក់ថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្លួនមិនធ្លាប់បានសិក្សាទេ និងបានធ្វើជាគូលីរបស់ឪពុកមារនៅ ទីក្រុងភ្នំពេញកាលពីអាយុជាង១០ឆ្នាំ ។ ដោយសារខ្លួនចេះក្បួន ពេទ្យ និងមានឪពុកជាខ្មែរឥស្សរៈផងនោះ ខ្មែរក្រហមក៏បានសុំខ្លួន ឲ្យទៅធ្វើជាពេទ្យខ្មែរក្រហម ប៉ុន្តែដោយសារមិនទាន់ចេះក្បួន ពេទ្យច្រើន សោ ភឹម ប្រធានភូមិភាគបូព៌ាបានបញ្ជូនលោកឲ្យ ទៅរៀនវិជ្ជាពេទ្យជាមួយវៀតណាម ។ បន្ទាប់មកដើមបណ្តឹង រដ្ឋប្បវេណីរូបនេះបានធ្វើជាគ្រូពេទ្យបដិវត្តប្រចាំនៅតំបន់២០ ក្នុងភូមិភាគបូព៌ា និងបានបង្ហាត់បង្រៀនគ្រូពេទ្យនៅតំបន់នោះ ទៀតផង ។

ទាក់ទងនឹងការសិក្សារៀនសូត្រនៅបុរីកីឡាក្នុងអំឡុងពេល នៃរបបកម្ពុជាប្រជាធិបតេយ្យ ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន បានបញ្ជាក់ជូនអង្គជំនុំជម្រះថា ប្រធានបទដែលខ្លួនបានសិក្សា នៅពេលនោះគឺផ្តោតសំខាន់លើ «មហាជ័យជម្នះរបស់បក្ស បដិវត្តន៍កម្ពុជា» ។ ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងទៀតថា ខ្លួនបានឮអ្នកដឹកនាំអប់រំអំពីពាក្យថា «មហាលោតផ្លោះ» មានន័យ ថា លោតពីប្រជាជាតិឡើងទៅកុម្មុយនីស្ត ។ វគ្គសិក្សានយោបាយ ជាន់ខ្ពស់នោះស្ថិតក្រោមការរៀបចំរបស់ យ៉ុន យ៉ាត និងមាន សមមិត្ត ប៉ុល ពត, នួន ជា, ខៀវ សំផន និង ហ៊ូ នឹម ។ ចំណែក ឯ អៀង សារី លោកមិនដឹងថាបានចូលរួមឬយ៉ាងណានោះទេ ដោយសារលោកមិនបានពិនិត្យឲ្យបានច្បាស់ ។ អែម អឿន បាន អះអាងបន្ថែមថា ពាក្យ "មហាលោតផ្លោះ មហាអស្ចារ្យ" គឺជាការ លោតចេញពីរបត់បក្សប្រជាជាតិប្រជាធិបតេយ្យឆ្លងទៅដល់ កុម្មុយនីស្ត ។ លោកបានលើកយកសម្តីរបស់ ខៀវ សំផន នៅក្នុង វគ្គរៀនសូត្រនៅបុរីកីឡាមករំឭកនៅក្នុងសវនាការថា "មិត្ត! នេះឯង ហៅថាផ្លូវបត់ទី៣ ។ អ៊ីចឹងបើសិនជាមិត្តណាបត់មិនទាន់ មានន័យថា ទោះបីជាអ្នកនោះ ជាមិត្តក៏ដោយ ជាបងក៏ដោយ

ជាប្អូនក៏ដោយ ឲ្យតែអ្នកឯងបត់មិនទាន់មានន័យថា មានឈ្មោះក្បត់ ។ បើសិនជាក្បត់ត្រូវតែកម្ទេច» ។ ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា មេដឹកនាំទាំងបីគឺ ប៉ុល ពត, នួន ជា និងខៀវ សំផន បានលើកឡើង ក្នុងន័យស្រដៀងគ្នាដូចខាងលើ ។

អែម អឿន បានរៀបរាប់ថា ចំពោះការប្រើប្រាស់ថ្នាំសម្រាប់កម្មាភិបាលមិនសូវមានការខ្វះខាតនោះទេ ដោយផ្អែកតាមការយល់ដឹងរបស់លោក គឺថ្នាំទាំងអស់នោះសេសសល់ពីរបបលន់ នល់ ។ អែម អឿន បានបន្តថា ចំណែកការពិសោធផ្នែកវះកាត់វិញ គឺពិសោធន៍លើអ្នកទោសដែលត្រូវប្រហារជីវិត ។ អ្នកទោសទាំងនោះត្រូវបានយកទៅវះកាត់ដោយស្រស់ៗតែម្តង ។ អែម អឿន បានលើកយកបទពិសោធផ្ទាល់របស់ខ្លួនមកជម្រាបជូនអង្គជំនុំជម្រះថា ខ្លួនបានចូលរួមមើលការពិសោធផ្នែកវះកាត់លើមនុស្សមានជីវិត ដែលបានប្រគល់ឲ្យដោយសន្តិសុខពេទ្យតំបន់ ។ លោកបានឃើញបុគ្គលដែលទទួលការវះកាត់ត្រូវបានដាក់ព្យួរសេរ៉ូម និងចាក់ថ្នាំសន្លប់ព្រមទាំង មានរៀបចំតុវះកាត់ជាស្រេច ។ ដំបូងបុគ្គលនោះត្រូវបានកាត់សន្ទាក់ដៃ និងសន្ទាក់ជើង ដោយចាប់ផ្តើមពីម្រាមដៃរហូតអស់ដៃទាំងស្រុង រួចប្រែកចូលក្នុងបាវប្រហែលកន្លះបាវ បន្ទាប់មកក៏យកទៅបោះចោល ។ លោកបានឃើញខ្មែរក្រហមធ្វើការវះកាត់បែបនេះលើមនុស្ស៣ទៅ៤នាក់នៅមន្ទីរយោធាតំបន់២០ ។ អែម អឿន បានបន្តជម្រាបជូនអង្គជំនុំជម្រះថា នៅពេលដែលលោកបានទទួលការបណ្តុះបណ្តាលនៅទីក្រុងភ្នំពេញ គឺបង្រៀនដោយជនបរទេសជាច្រើននាក់មកពីប្រទេសចិន និងប្រទេសកូរ៉េ ជាដើម ដែលមកហ្វឹកហ្វឺនវិជ្ជាពេទ្យ ។ អ្នកដែលលោកនៅចងចាំនោះមានឈ្មោះ ដួន ជឿន ចំណែកជនជាតិចិនបង្រៀនផ្នែកមូលវិទ្យាសាស្ត្រ និងជនជាតិកូរ៉េបង្រៀនខាងឯកទេសវះកាត់ ។ អែម អឿន បានលើកឡើងអំពីការមើលឃើញកម្មាភិបាលខ្មែរក្រហមចាប់ខ្លួនលោកស្រី ឡេង សី (ប្រពន្ធរបស់ ទីវ អុល) ដែលជាអ្នកអប់រំផ្នែកនយោបាយនៅសាលារបស់លោក និងជាប្រធានមន្ទីរពេទ្យដាក់លើឡានរួចសម្រាតខោអាវ ។

### ៣) ការសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញា

សហព្រះរាជអាជ្ញាបានផ្តោតជាសំខាន់លើការចូលរួមនៅក្នុងវគ្គសិក្សារៀនសូត្រផ្នែកនយោបាយនៅបុរីកីឡា និងគោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

#### ៣.ក) សហព្រះរាជអាជ្ញារងជាតិ

សហព្រះរាជអាជ្ញារងជាតិ ចាន់ តារាស្មី បានចាប់ផ្តើមសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងរយៈពេលចូលបដិវត្តមុនឆ្នាំ១៩៧៥ ដោយលើកនូវកាលបរិច្ឆេទមួយជាក់លាក់ដើម្បីរំឭកដល់ដើមបណ្តឹងរដ្ឋប្បវេណី ។ ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណី



សហព្រះរាជអាជ្ញារងជាតិ ចាន់ តារាស្មី

មិនបានចាំពីពេលវេលាណាមួយច្បាស់លាស់នោះទេ ។ សហព្រះរាជអាជ្ញារងបានធ្វើការរំឭកម្តងទៀត ទើប អែម អឿន មានការចងចាំថា ខ្លួនបានចូលបដិវត្តនៅឆ្នាំ១៩៦៩ ។ ភ្លាមៗនោះ មេធាវីអន្តរជាតិការពារក្តីឲ្យជនជាប់ចោទ ខៀវ សំផន គឺមេធាវី អង់តា ហ្គីសសេ បានស្នើសុំឲ្យសហព្រះរាជអាជ្ញាបញ្ជាក់ពីឯកសារដែលខ្លួនប្រើប្រាស់ដើម្បីយោងក្នុងការសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី ដោយសារដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានតម្រូវឲ្យផ្តល់សក្ខីកម្មនៅចំពោះមុខចៅក្រមស៊ើបអង្កេត ។ សហព្រះរាជអាជ្ញារង បានបញ្ជាក់អត្តសញ្ញាណនៃឯកសារនោះថាជាបែបបទប្រវត្តិរូបរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន បានជម្រាបជូនអង្គជំនុំជម្រះថា បក្សកុម្មុយនីស្តកម្ពុជាមានគោល ការណ៍ត្រូវការអ្នកស្រលាញ់បដិវត្តន៍

បន្ទាប់មកបក្សបញ្ចូលជនទាំងនោះទៅជាជនចម្រើន រួចហើយទៅជាសម្ព័ន្ធយុកក ។ បុគ្គលដែលដើមបណ្តឹងរដ្ឋប្បវេណីខស្សាហ៍ជួបនិងស្គាល់នោះគឺ សោ ភឹម (ជាប្រធានផ្នែក) ដោយសារកាលនោះខ្លួនជានីរសារ ។ ពេលនោះ សោ ភឹម បានប្រាប់ឲ្យខ្លួនតស៊ូវណ្ណៈដ្នុយទៅវិញសូម្បីតែអត្ថន័យនៃពាក្យនេះក៏ខ្លួនមិនបានយល់ដែរ ។ ក្រោយមក លោកបានក្លាយជាសមាជិកបក្សកុម្មុនីស្តនៅ



បុគ្គលិកពេទ្យសម័យខ្មែរក្រហម (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

ក្រោយឆ្នាំ១៩៧៥ ក្នុងរូបភាពជាជនស្ម័គ្រចិត្ត ។

ទាក់ទងនឹងសាសនា ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន បានលើកដៃសំពះ និងរៀបរាប់ថា បក្សមានគោលការណ៍របស់ខ្លួននៅឆ្នាំ១៩៧២ ប៉ុន្តែខ្លួនលោកផ្ទាល់មិនបានឃើញបក្សដាក់ផែនការណាមួយដើម្បីប្រឆាំងនឹងសាសនាទេ ។ លុះដល់ឆ្នាំ ១៩៧២-៧៥ ទើបលោកឃើញមានការហាមឃាត់ផ្នែកសាសនា ដោយមិនមានជាឯកសារហាមឃាត់ជាលាយលក្ខណ៍អក្សរនោះទេ គឺបក្សគ្រាន់តែនិយាយថាសាសនានាំឲ្យខាតបង់ គឺខាតទាំងសំលៀកបំពាក់ ពេលវេលា និងបាយជាដើម ។ នៅឆ្នាំ១៩៧២ បក្សមានបំណង ប្រឆាំងសាសនាតែម្តង ។ ការសាកសួររបស់សហព្រះរាជអាជ្ញារងជាតិនៅត្រង់ចំណុចនេះ ត្រូវបានលោកប្រធានអង្គជំនុំជម្រះកត់សម្គាល់ និងរំពុកដល់លោកសហព្រះរាជអាជ្ញាថា ការធ្វើទុកបុកម្នេញខាងសាសនា មិនទាក់ទងនឹងអង្គហេតុនៅដំណាក់ទីមួយនេះទេ ។

សហព្រះរាជអាជ្ញារងជាតិ បានបន្តសួរទាក់ទងនឹងការចូលរួមក្នុងវគ្គអប់រំផ្នែកវេជ្ជសាស្ត្រ ដែលមានរយៈពេលកន្លះខែ ។

ក្រោយមកសហព្រះរាជអាជ្ញា បានសួរអំពីការងារជាពេទ្យនៅតំបន់២០ និងយុវភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ុន្តែសំណួរនេះ ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតបដោយភាពស្រពិចស្រពិល ដោយសារតែរយៈពេលកន្លងផុតទៅយូរពេក ។ លោក អែម អឿន បានរំឭកថា អ្នកចូលរួមរៀនវិជ្ជាពេទ្យនៅមន្ទីរពេទ្យបច្ចេកទេសមិត្តភាពខ្មែរ-សូវៀត នៅពេលនោះមិនតិចជាង



១ពាន់នាក់នោះទេ បើយោងតាមគោលការណ៍ដែលបក្សអញ្ជើញពីមជ្ឈិម គឺចាប់ពីអ្នកនៅថ្នាក់តំបន់ដែលមានតួនាទីជាប្រធាន និងអនុប្រធានអ្នកទាំងនោះសុទ្ធតែចេះស្រាប់ហើយ គឺមកសិក្សាដើម្បីបំពេញវិជ្ជាបន្ថែមតែប៉ុណ្ណោះ ។ អ្នកទាំងនោះជាកូនកម្មាភិបាលភាគច្រើនចាប់ពីអាយុ២០ឆ្នាំឡើងទៅ ដែលអាចវះកាត់បានខ្លះហើយ ។ អែម អឿន ចាំបានថា នៅពេលនោះ អ្នកដឹកនាំមន្ទីរពេទ្យមានឈ្មោះ ឡេង សី និង យុន យ៉ាត រីឯអ្នកគ្រប់គ្រង គឺឈ្មោះ ដួន ជឿន ។ មន្ទីរពេទ្យខ្មែរ-សូវៀត មានបែងចែកដូចជា ជំងឺស្ត្រី ជំងឺទូទៅ ពេទ្យធ្មេញ ហើយមានអគារសម្រាប់កម្មាភិបាលផ្សេងៗទៀត ។ អែម អឿន បានផ្តល់ចម្លើយជូនអង្គជំនុំជម្រះថា ខ្លួនមិនបានចូលរួមក្នុងកិច្ចប្រជុំដែលរៀបចំឡើងដោយមន្ទីរពេទ្យខ្មែរ-សូវៀត ឬក្រសួងសង្គមកិច្ចនោះទេ ដោយសារលោកជាប់រវល់ក្នុងឋានៈជាសិស្ស និងជាប្រធានសិស្ស ។ ដូច្នេះខ្លួនក៏ខិតខំប្រឹងប្រែងទទួលខុសត្រូវតែលើការងាររបស់ខ្លួនតែប៉ុណ្ណោះ និងខិតខំពង្រឹងសមាជិករបស់ខ្លួន ដើម្បីឲ្យគេចផុតពីការស្ដីបន្ទោសរបស់បក្សដែលនៅពេលនោះ ការងាររបស់ខ្លួនគឺអប់រំសិស្សអំពីការងារបក្ស និងការងារនយោបាយ ។ ចំណែកការចាប់ខ្លួននៅមន្ទីរពេទ្យខ្មែរ-សូវៀត អែម អឿនបានដឹងត្រឹមតែការមើលឃើញ ឬការយល់របស់ខ្លួនប៉ុណ្ណោះ មិនហ៊ានសួរដេញដោលលើសពីនេះទេ ។

បន្ទាប់មក សហព្រះរាជអាជ្ញារងជាតិបានបន្តសួរទាក់ទងនឹងការជួបជាមួយអ្នកដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហម ។ អែម អឿន បានឆ្លើយថា ខ្លួនបានជួបមេដឹកនាំមួយចំនួនដូចជា ប៉ុល ពត, នួន ជា, អៀង សារី និង ខៀវ សំផន នៅពេលរៀនសូត្រក្នុងវគ្គសិក្សានយោបាយ ប៉ុន្តែលោកមិនបានឃើញនៅពេលចូលធ្វើការនៅក្នុងមន្ទីរពេទ្យនោះទេ ។ អែម អឿន បានបញ្ជាក់ថា ខ្លួនមិនធ្លាប់ឃើញមានការចាប់មនុស្សដាក់ឡានពេទ្យនោះទេ ព្រោះឡាននោះបិទជិត ។ ចំពោះវិន័យនៅក្នុងមន្ទីរពេទ្យវិញ បក្សបានបង្រៀនឲ្យមានចិត្តមនុស្សធម៌ មិនត្រូវធ្វើបាបអ្នកជំងឺនៅក្នុងមន្ទីរពេទ្យទេ ។ ទ្រឹស្ដីរបស់បក្ស គឺ «បើអ្នកណាប្រឆាំងនឹងបក្ស គឺមានន័យថាក្បត់» ។ អែម អឿន បន្តទៀតថា កាងាររបស់បក្សនៅពេលនោះ គឺមិនគិតពីអាយុជីវិតមនុស្សនោះទេ គឺគិតលើវិន័យបក្សជាធំ ។ ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញារងជាតិ ចាន់ តារាស្មី អែម អឿន បានជម្រាបថា នៅពេលចូលរួមវគ្គសិក្សាសម្រាប់ពេទ្យមធ្យមឆ្នាំទី៣ សិស្សមកពីតាមភូមិភាគមិនហ៊ាននិយាយគ្នាលេងសើចទេ ព្រោះខ្លាចបក្សចោទថាក្បត់ ។ អ្នកទាំងនោះខ្លះត្រូវបានចាប់បញ្ជូនទៅភូមិភាគវិញ ។

### ៣.៦) តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វ៉ាំងសង់ ដឺវ៉ាល់ ដេស្វាឯល បានបន្តសំណួរពីសហភាគីរបស់ខ្លួន ដោយសួរទាក់ទងនឹងការចូលរួមនៅក្នុងវគ្គសិក្សានយោបាយ ។ អែម អឿន បានរៀបរាប់ថា វគ្គសិក្សាអំពីនយោបាយដែលបានធ្វើនៅបុរីកីឡានោះ ខ្លួនបានចូលរៀនតែមួយលើកប៉ុណ្ណោះ ដោយសារតែជាការតម្រូវពីបក្ស ។ នៅពេលនោះខ្លួនបាន ឃើញ ប៉ុល ពត, ហ៊ូ យន់ និង ហ៊ូ នឹម តាមរយៈការឡើងនិយាយនៅក្នុងវគ្គបណ្តុះបណ្តាល ។ អែម អឿន បានដឹងជាមុនថា ប៉ុល ពត ជាលេខាបក្សបដិវត្តន៍កម្ពុជា នួន ជា គឺជាប្រធានសភា ខៀវ សំផន ជាប្រធានគណៈប្រធានរដ្ឋ តាំងពីមុនពេលចូលរៀនទៅទៀត ។ ការដឹងនេះ គឺតាមរយៈ



សហព្រះរាជអាជ្ញាអន្តរជាតិ វ៉ាំងសង់ ដឺវ៉ាល់ ដេស្វាឯល

ប្រធានតំបន់ និងភូមិភាគបានប្រាប់ខ្លួន ប៉ុន្តែទើបស្គាល់មុខអ្នកទាំងនោះ ដំបូង បង្អស់នៅបុរីកីឡាតែប៉ុណ្ណោះ ។ អ្នកបើកវគ្គដំបូងគឺ ប៉ុល ពត ដែលជាអ្នកឡើងថ្លែងសុន្ទរកថាបើក ហើយមេដឹកនាំផ្សេងអង្គុយស្តាប់ជាគណៈអធិបតី ។ នៅពេលនោះមិនមាននរណាបញ្ចេញមតិយោបល់អ្វីទាំងអស់ គឺបានត្រឹមតែស្តាប់បក្សណែនាំប៉ុណ្ណោះ ។ អែម អឿន ធ្លាប់បានបញ្ជាក់នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីថា ប៉ុល ពត និយាយនៅក្នុងវគ្គសិក្សានយោបាយនោះថា បើអ្នកណាមិនអនុវត្តតាមមាគ៌ាមហាលោតផ្លោះ មហាអស្ចារ្យទេនោះ គឺចាត់ទុកថាជាខ្មាំង ហើយដើម្បីដឹងថាអ្នកណាជាខ្មាំង គឺត្រូវមើលតាំងពីការងារ ដូចជាឡើងមករៀនជាដើម ។ មិត្ត និងខ្មាំង គឺត្រូវបែងចែកឲ្យបានច្បាស់លាស់ ។

អែម អឿន បានជម្រាបជូនអង្គជំនុំជម្រះថា នៅក្នុងរបបនោះកម្មាភិបាលទាំងអស់ហាក់បីដូចជាគ្មានអំណាចអ្វីឡើយ ។ អ្នកទាំងអស់ស្តាប់តែសារាចរមួយគត់ គឺមន្ទីរ៨៧០ ។ តាមយោបល់លោក អំណាចហាក់ដូចជាពង្រីកខ្លាំងពេក ដោយអ្នកនៅថ្នាក់ក្រោមដូចជា កងឈ្លប ក៏មានសិទ្ធិអំណាចដែរ ។ អែម អឿន បានធ្វើការកត់សម្គាល់ផ្ទាល់ខ្លួនថា លោកបានសង្កេត ឃើញថាអ្វីដែលរបបខ្មែរក្រហមខ្លាចបំផុត គឺខ្មាំងស៊ីរូងផ្ទៃក្នុង។ លោកថាខ្មាំងពីក្រៅអាចមើលឃើញ បើខ្មាំងនៅខាងក្នុងមិនអាចមើលមិនឃើញទេ ដោយហេតុនេះហើយទើបនាំឲ្យមានការកាប់សម្លាប់គ្នាច្រើន ។ អង្គជំនុំជម្រះបានរំឭកដល់អែម អឿន មិនឲ្យបង្ហាញពីការយល់ឃើញ ឬមតិយោបល់ផ្ទាល់ខ្លួននៅក្នុងសក្ខីកម្មរបស់ខ្លួនឡើយ ។ អែម អឿន បានជម្រាបជូនអង្គជំនុំជម្រះថា មេដឹកនាំទាំងនោះ មុននឹងនិយាយអ្វី គឺតែងតែផ្អែកទៅលើគោលការណ៍បក្សជានិច្ច ។ ចំណែកឯ ប៉ុល ពត មិននិយាយដូច្នោះទេ ហើយ នួន ជា វិញមុននឹងនិយាយអ្វី គឺតែងតែរក្សាតម្លៃនៃសម្តីរបស់ ប៉ុល ពត ជានិច្ច ។ អែម អឿន បានបញ្ជាក់ទៀតថា នៅបុរីកីឡា នួន ជា បានរំឭកពីឈ្មោះជនក្បត់បក្ស ហើយថា សុំមិត្តកុំធ្វើដូចអ្នកក្បត់បក្ស ដូចជា កុយ ធួន និង កែវ មាស ឲ្យសោះ ។ ទាក់ទងនឹងបញ្ញាជន និងនិស្សិតមកពីបរទេសវិញ អែម អឿន បានបញ្ជាក់ថា នួន ជា បាននិយាយវាយប្រហារបញ្ញវន្តទាំងនោះ ដោយផ្តល់ហេតុផលថានិស្សិតទាំងនោះមិនបានធ្វើអ្វីដើម្បីជាតិទេ ព្រមទាំងទទួលមនោគមវិជ្ជាពីបរទេសមកទៀតផង ។ តំណាងសហព្រះរាជអាជ្ញាបានបន្តសួរទាក់ទងនឹងពាក្យថា "បណ្ដាញខ្មាំង" ។ អែម អឿន បានឆ្លើយតបថា ពាក្យនេះមិនមែនលើកយកមកប្រើតែ នួន ជា ម្នាក់ទេ គឺប្រើចាប់ពីថ្នាក់ដឹកនាំឃុំនៅតាមមូលដ្ឋានឡើងទៅ ។ លោកបន្តថា នួន ជា បានលើកឡើងថា ឲ្យតែនិស្សិតដែលចាកចេញទៅក្រៅប្រទេស គឺចាត់ទុកថាមិនគិតគូរពីសុខទុក្ខរបស់ជាតិនោះទេ ។ ពាក្យ "បណ្ដាញគិញ" នួន ជា បានផ្តោតសំខាន់លើភ្នាក់ងារ សេ.អ៊ី.អា កា.ហ្សេ.បេ និងយួនលេបទឹកដី ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វ៉ាំងសង់ បានផ្លាស់ប្តូរសំណួរដោយ

សួរទាក់ទងនឹងការធ្វើសុន្ទរកថារបស់ ខៀវ សំផន នៅបុរីកីឡាវិញម្តង ។ អែម អឿន បានបញ្ជាក់ថា តាមការចងចាំរបស់ខ្លួន ខៀវ សំផន បានលើកឡើងថា “ជាគោលការណ៍ ដើម្បីជួយវែកមុខជនក្បត់បដិវត្តន៍ ដែលមានឈ្មោះថា ជនស៊ីរូងផ្ទៃក្នុង ចូរមិត្តទាំងអស់ពិនិត្យមើលគោលការណ៍ដែលយើងធ្វើដាច់ខាត ដើម្បីឲ្យឆាប់ស្គាល់មិត្ត និងសត្រូវ យើងទាល់តែបង្កើតពាក្យថា បង្កើនការផលិតឲ្យបានច្រើន ហូបបាយតិច ការផលិតបង្កើនច្រើន សម្រាកតិច” ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តទៀតថា ពេលបានឮសម្តីរបស់អ្នកដឹកនាំទាំងនោះ ខ្លួនមានការភ័យខ្លាច ។ គោលនយោបាយយុទ្ធសាស្រ្តរបស់បក្ស ដែលលើកឡើងដោយ ខៀវ សំផន នៅបុរីកីឡាថា ឲ្យស្គាល់ពីភារកិច្ចរបស់ខ្លួនម្នាក់ៗឲ្យច្បាស់ ។ ត្រង់ចំណុចនេះ បើថាឮហើយត្រូវតែគោរព ។ អែម អឿន បានជម្រាបជូនអង្គជំនុំជម្រះថា នៅក្នុងកម្រិតអង្គការ ឈ្មោះថាអង្គការ គឺសំដៅលើមនុស្សច្រើននាក់ មានចាប់ពីបីនាក់ឡើងទៅ ប៉ុន្តែលោកមិនស្គាល់នរណាជាអង្គការទេ ដោយគ្រាន់តែដឹងថាអ្នកធំជាងគេនោះគឺ ប៉ុល ពត ។ នៅពេលលោកស្នាក់នៅ មូលដ្ឋាន លោកមិនដឹងថាកន្លែងរបស់លោកទទួលការផលិតពីមជ្ឈិម ឬពីណាមកទេ គឺលោកដឹងតែទទួលការផលិតពីក្រសួងរបស់លោកតែប៉ុណ្ណោះ ។

## ៤) ការសួរដេញដោលដោយមេធាវីការពារក្តីទាំងបីក្រុម

### ៤.ក) ក្រុមមេធាវីការពារក្តី នួន ជា

មេធាវីអន្តរជាតិការពារក្តី នួន ជា គឺលោក ហ្សាស្តេ ប៉ៅ បានចាប់ផ្តើមសំណួរពាក់ព័ន្ធការដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន បានឆ្លើយតបនឹងសំណួររបស់មេធាវីការពារក្តីថា លោកបានដាក់ពាក្យបណ្តឹងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលត្រូវបានណែនាំដោយបងប្អូនរបស់លោកគឺឈ្មោះ ស សារិន ។ អែម អឿន បានបន្តទៀតថា ស សារិន ជាអតីតអ្នកដឹកភ្ញៀវនៅក្រសួងការបរទេសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យបច្ចុប្បន្ន គឺជាកសិករ មិនមែនបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាទេ ។ ឈ្មោះ ស សារិន បានណែនាំខ្លួនថា បើមានទទួលរងការឈឺចាប់ដោយសាររបបកម្ពុជាប្រជាធិបតេយ្យសូមឲ្យខ្លួនទាក់ទងមជ្ឈមណ្ឌលឯកសារកម្ពុជា ។



កម្មាភិបាលខ្មែរក្រហមកំពុងចូកស្រូវពីចង្រ្កុក (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

លោកទទួលបានទម្រង់ព័ត៌មានជនរងគ្រោះពីមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងឆ្នាំ២០១០ ។ អែម អឿន បានបន្តថា ខ្លួនបានបំពេញទម្រង់ព័ត៌មានជនរងគ្រោះពីដំបូង ប៉ុន្តែក្រោយមកមជ្ឈមណ្ឌលឯកសារកម្ពុជាជាអ្នកជួយសម្របសម្រួលក្នុងការបំពេញលើទម្រង់ទាំងពីរនោះ ។ នៅពេលលោកបំពេញទម្រង់ទាំងពីរនេះមិនមានវត្តមាន លោក ស សារិន ទេ ។

មេធាវី ហ្សាស្តើ ប៉ៅ បានបន្តសួរទាក់ទងនឹងការចូលរួមកិច្ចប្រជុំនៅបុរីកីឡា ។ អែម អឿន បានអះអាងថា កិច្ចប្រជុំនៅបុរីកីឡាប្រព្រឹត្តទៅបន្ទាប់ពីលោកចូលមករៀនវិជ្ជាពេទ្យនៅភ្នំពេញបានពីរខែ គឺនៅខែកក្កដា ឆ្នាំ១៩៧៦ ។ មេធាវីបានសួរដេញដោលអំពីឈ្មោះ ស សារិន ដែលបានណែនាំលោកឲ្យរៀបចំដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខតុលាការ និងការចូលរួមវគ្គរៀនសូត្រនៅបុរីកីឡា ។ ប៉ុន្តែលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងថាការចូលរួមរៀនសូត្រនោះ គឺខុសគ្នារវាងលោក ស សារិន និងដើមបណ្តឹងរដ្ឋប្បវេណី ។ អង្គជំនុំជម្រះបានយល់ស្របចំពោះការជំទាស់របស់លោកសហព្រះរាជអាជ្ញា ហើយថាសំណួររបស់មេធាវីមានលក្ខណៈច្រំដែល និងធ្វើឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានការភាន់ច្រឡំ ។

មេធាវីបានសួរពីទំនាក់ទំនងរវាងដើមបណ្តឹងរដ្ឋប្បវេណី និងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានជួយបំពេញពាក្យបណ្តឹង ។ អែម អឿន បានពន្យល់ថា ខ្លួនបានជួបជាមួយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ពេលខ្លះចំនួនមួយម៉ោង ឬមួយម៉ោងកន្លះ ហើយបុគ្គលិកនោះបានជួយបំពេញបន្ថែមលើអក្សរដៃដែលលោកបានសរសេររួចរាល់ ។ មេធាវីបានដាក់បង្ហាញឯកសារដើម្បីបញ្ជាក់ថា ជាអក្សររបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬជាអក្សររបស់បុគ្គលិកនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ។ អែម អឿន បានឆ្លើយថាអក្សរខ្មែរ គឺជាអក្សររបស់លោកផ្ទាល់ ហើយភាសាអង់គ្លេសគឺជារបស់បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជា ។ នៅពីរខែក្រោយលោកបានបន្ថែមព័ត៌មានមួយចំនួន ដោយសារមូលហេតុលោកនៅខេត្តនៅឆ្ងាយពីគ្នា ដូច្នេះបន្ទាប់ពីសរសេរចប់ភ្លាម លោកមិនបានពិនិត្យឡើងវិញ ។ បន្ទាប់មក មេធាវី ហ្សាស្តើ ប៉ៅ ត្រឡប់មកទាក់ទងនឹងបុគ្គលមួយចំនួននៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន បានបញ្ជាក់ថា លោកមិនស្គាល់ ខៀវ សំណាប់ ទេ លោកស្គាល់តែ ខៀវ សារុន ដែលមានតួនាទីជាគណៈតំបន់២០ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ រីឯឈ្មោះ ជួន ជឿន គឺជាប្រធានបច្ចេកទេសនៃក្រសួងសុខាភិបាល ប៉ុន្តែមិនសូវបង្រៀនជាទ្រឹស្តីដល់សិស្សទេ គឺដឹកដៃសិស្សទៅពិនិត្យមើល និងសន្និដ្ឋានអំពីរោគសញ្ញានៃជំងឺដោយផ្ទាល់តែម្តង ។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា ជនជាតិកូរ៉េ និងចិនបានមកបង្រៀនផ្នែកបច្ចេកទេស ។ ជួន ជឿន រៀនមកពីបារាំងជំនាញផ្នែកបេះដូង ហើយខ្លួនក៏ធ្លាប់បានឃើញ ជួន ជឿន វះកាត់បេះដូងមួយលើកដែរ ។ មេធាវី ហ្សាស្តើ ប៉ៅ បានអានសេចក្តីសម្រង់ចេញពីទម្រង់បែបបទព័ត៌មានជនរងគ្រោះដែល អែម អឿន បានសរសេរ ដែលមានអត្ថន័យថា *«នៅឆ្នាំ១៩៧៥ គឺគេចាត់តាំងឲ្យខ្ញុំធ្វើការងារជាពេទ្យ ទោះបីជាខ្ញុំមិនមានបទពិសោធន៍ខាងពេទ្យក៏ដោយ»* ។ ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន បានបញ្ជាក់ត្រង់ចំណុចនេះថា មូលហេតុដែលខ្លួនប្រើពាក្យដូច្នេះ ដោយសារខ្លួនធ្វើការងារទាំងមិនចេះ មិនដឹងវិជ្ជាទាំងអស់នោះ និងខំប្រឹងដោយខ្លួនឯង ហើយអ្វីដែលខ្លួនចេះ គឺមិនមែនជាក្របខ័ណ្ឌដែលទទួលស្គាល់ដោយរដ្ឋនោះទេ ។ អែម អឿន បានលើកឡើងអំពីវគ្គអប់រំនយោបាយ នៅបុរីកីឡាដោយរៀបរាប់អំពីសម្តីរបស់ ខៀវ សំផន ថា នៅពេលនោះ ខៀវ សំផន បានលើកឡើងពីនារីម្នាក់ដែលធ្វើឲ្យបាក់ម្ជុលដេរ ដោយអះអាងថាបក្សមិនផ្តោតតែលើការបាក់ម្ជុលនោះទេ គឺឲ្យស្វែងរកបុគ្គលណាដែលជាសត្រូវរបស់បក្សដែលមានបំណងបំផ្លាញបក្ស មិនប្រយ័ត្នចំពោះការងារ ។

## ៤.១) ក្រុមមេធាវីការពារក្តី អៀង សារី

មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ អៀង សារី គឺលោក ម៉ៃឃើល ការណាវ៉ាស បានសាកសួរដោយផ្តោតសំខាន់លើសេចក្តីសម្រង់នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅត្រង់ផ្នែកដែលលើកឡើងថា ដើមបណ្តឹងរដ្ឋប្បវេណីមិនមានចំណេះដឹងផ្នែកវេជ្ជសាស្ត្រ ។ ប៉ុន្តែសំណួរនេះត្រូវបានតំណាងសហព្រះរាជអាជ្ញាជំទាស់ ដោយផ្តល់ហេតុផលថាជាសំណួរដែលមានលក្ខណៈច្រំដែល

ដោយសារមេធាវីការពារ ក្តី នួន ជា បានសួរនាំរួចម្តងហើយ ។ មេធាវី កាណាវ៉ាស បានឆ្លើយតបថា មេធាវីការពារជូនកូនក្តីផ្សេងៗគ្នា ដូច្នេះខ្លួនមានសិទ្ធិក្នុងការសួរសំណួរនេះ ។ ប៉ុន្តែអង្គជំនុំជម្រះបានសម្រេចថា សេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាមានលក្ខណៈសមស្រប និងបង្គាប់ឲ្យលោកមេធាវីផ្លាស់ប្តូរសំណួរ ។ មេធាវីបានសួរដេញដោលអំពីប្រវត្តិរូបសង្ខេបរបស់ដើមបណ្តឹងរដ្ឋប្បវេណីឡើងវិញ ។ ឆ្លើយតបនឹងសំណួរនេះ ដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន បានរៀបរាប់ដូចចម្លើយដែលខ្លួនធ្លាប់បានឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាពីខាងដើមទាក់ទងនឹងប្រវត្តិរូបសង្ខេបរបស់ខ្លួន ។

បន្ទាប់មកមេធាវី កាណាវ៉ាស បានបន្តសួរសំណួរទាក់ទងនឹងរូបរាងរបស់ឈ្មោះ ដួន ជឿន និងសកម្មភាពដែលធ្លាប់បានពន្យល់បង្រៀនដល់រូបលោកដើមបណ្តឹងរដ្ឋប្បវេណីអំពីក្រមសីលធម៌គ្រូពេទ្យ ។ ដើមបណ្តឹងរដ្ឋប្បវេណី បានជម្រាបជូនអង្គជំនុំជម្រះថា នៅតាមមូលដ្ឋានមិនសូវមានថ្នាំព្យាបាលច្រើនដូចនៅតាមតំបន់ទេ ភាគច្រើនគឺប្រើថ្នាំដែលស្លដោយខ្លួនឯង ដែលត្រូវបានស្គាល់ថាជា "ថ្នាំអាចម៍ទន្សាយ" ។ មេធាវី កាណាវ៉ាស បានបន្តសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងសក្ខីកម្មដែលនិយាយអំពីការវះកាត់មនុស្សថា នៅពេលដែលដាក់ពាក្យ សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តើលោកសុំដោយប្រាកដប្រជា ឬសុំដោយលេងសើច? អែម អឿន បានឆ្លើយតបនឹងសំណួរនេះថា ៖

"ខ្ញុំដាក់ពាក្យនេះមិនមែនលេងសើចទេ ការពិត គឺការឈឺចាប់បាត់ម្តាយ បាត់ឪពុក បាត់បងប្អូនអស់ ដោយសារពួកថ្នាក់ដឹកនាំនេះឯង ។ ដូច្នេះ ខ្ញុំងើបឡើងដើម្បីតាំងជាដើមបណ្តឹងដើម្បីស្វែងទាញរឿងពិតប្រាប់តុលាការថា រឿងរបស់អ្នកទាំងបីហ្នឹងយ៉ាងម៉េចខ្លះ គឺខ្ញុំសូមនិយាយតែរឿងពិតទេ ត្រង់គេធ្វើយ៉ាងម៉េចជារឿងរបស់គេ ឯខ្ញុំឃើញយ៉ាងណានោះជារឿងរបស់ខ្ញុំ" ។

បន្ទាប់មកមេធាវី កាណាវ៉ាស បានបន្តសួរម្តងហើយម្តងទៀតទាក់ទងនឹងការមើលឃើញវត្តមានរបស់ជនជាប់ចោទ អៀង សារី នៅបុរីកីឡាដោយដើមបណ្តឹងរដ្ឋប្បវេណី ។ ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណី អែម អឿន នៅតែរក្សាចម្លើយរបស់ខ្លួនថាបានឃើញ អៀង សារី នៅបុរីកីឡានាអំឡុងពេលនោះជាមួយមេដឹកនាំខ្មែរក្រហមដទៃទៀតដដែល ។

### ៤.ក) ក្រុមមេធាវីការពារក្តី ខៀវ សំផន

មេធាវីអន្តរជាតិ អង់តា ហ៊្គីហ្វេ្យ ការពារក្តីជនជាប់ចោទ ខៀវ សំផន បានតាំងសំណួរទាក់ទងនឹងការស្នាក់នៅរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅតំបន់២០ គឺនៅមុនរដ្ឋប្រហាររបស់ លន់ នល់ ។ ឆ្លើយតបនឹងសំណួរនេះ អែម អឿន មិនបានចងចាំពីកាលបរិច្ឆេទដែលខ្លួនសម្រេចចិត្តចូលបម្រើការងារជាគ្រូពេទ្យថាតើនៅមុន ឬក្រោយឆ្នាំ១៩៧៤នោះទេ ។ គួរបញ្ជាក់ថា ដើម្បីរំឭកពីកាលប្រវត្តិខ្លះៗ មេធាវីបានសួរនូវសំណួរនាំមុខមួយចំនួន ហើយការសួរនូវសំណួរនាំមុខទាំងនោះ ត្រូវបានលោកប្រធានអង្គជំនុំជម្រះធ្វើការរំឭកដល់មេធាវីឲ្យមានការប្រុងប្រយ័ត្ននូវសំណួរទាំងនេះ ព្រោះអាចនាំឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានការភាន់ច្រឡំ ។ មេធាវី ហ៊្គីហ្វេ្យ បានសួរសំណួរមួយចំនួនទាក់ទងនឹងមុខងារ និងតួនាទីរបស់មេដឹកនាំខ្មែរក្រហម រួមទាំង ខៀវ សំផន ផង ។ អែម អឿន បានជម្រាបជូនថាខ្លួនដឹងពីមុខងាររបស់ ខៀវ សំផន តាមរយៈសោ ភឹម និងបុគ្គលផ្សេងទៀតជាអ្នកនិយាយប្រាប់ខ្លួន ចំណែកឯរូបរាងរបស់ ខៀវ សំផន លោកទើបតែបានឃើញនៅបុរីកីឡាតែប៉ុណ្ណោះ ។ មេធាវីបានសួរអំពីមុខងាររបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅពេលលោកមានតួនាទីជាប្រធាននិស្សិតដែលមើលការខុសត្រូវទូទៅលើនិស្សិតពេទ្យទាំងនោះ ។ អែម អឿន បានរៀបរាប់ថា កាលនោះ ដួន ជឿន និងសហការីបានប្រគល់មុខងារនេះដល់ខ្លួន ។ តាអ៊ិត ប្រធានតំបន់ និង ខឹម លេខា តំបន់បានខទ្វេសនាមឲ្យលោកមករៀនពេទ្យ ហើយក្រោយមកក្លាយជាប្រធានសិស្សនៅមន្ទីរពេទ្យ ។ បន្ទាប់មក មេធាវីអន្តរជាតិបានសួររំឭកអំពីព្រឹត្តិការណ៍នៃការចាប់ខ្លួនលោកស្រី ឡេង សី និងព្រឹត្តិការណ៍នៅបុរីកីឡាឡើងវិញដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់នូវចំណុចខ្លះៗ ។ នៅពេលបញ្ចប់សំណួររបស់ខ្លួន មេធាវីអន្តរជាតិបានផ្ទេរវេទិកាសួរដេញដោលជូនដៃគូរបស់ខ្លួនដែលជាមេធាវីជាតិ គឺលោក គង់ សំអុន ។ ខណៈនោះលោកស្រីមេធាវីបានហៅឈ្មោះសហភាតារបស់ខ្លួនថា លោក គង់ សំអឿន ។ ភ្លាមៗលោកប្រធានអង្គជំនុំជម្រះបានកែតម្រូវថាមេធាវីជាតិការពារក្តីជនជាប់ចោទ ខៀវ សំផនគឺឈ្មោះគង់ សំអុន ។ មេធាវី គង់ សំអុន

បានចាប់ផ្ដើមសំណួរពាក់ព័ន្ធនឹងឯកសារកំណត់ហេតុពាក្យបណ្ដឹងរបស់ អែម អឿន ដែលបានផ្ញើនៅមជ្ឈមណ្ឌលឯកសារកម្ពុជាថា មានចំណុចខ្លះមានការកែប្រែនូវកាលបរិច្ឆេទ ។ ឧទាហរណ៍ កាលបរិច្ឆេទនៃការស្លាប់របស់ឪពុកលោកដែលពីមុននៅឆ្នាំ១៩៧៤ ហើយក្រោយមកប្ដូរមកឆ្នាំ១៩៧៦ ឬ១៩៧៧វិញ ។ មេធាវីមានចម្ងល់ថា តើចំណុចកែប្រែទាំងនោះដោយសារមូលហេតុ អែម អឿន មិនមានការចងចាំបានល្អ ឬក៏មានអ្នកឲ្យយោបល់លើកាលបរិច្ឆេទរបស់តុលាការនេះ ដែលមានសមត្ថកិច្ចនៅក្នុងអំឡុងឆ្នាំ១៩៧៥ដល់១៩៧៩? ដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន បានបញ្ជាក់ជូនអង្គជំនុំជម្រះថា ការសរសេរលើកទីមួយរបស់លោក គឺធ្វើដោយមិនមានការគិតគូរល្អិតល្អន់ ទើបនាំឲ្យមានការកែប្រែខ្លះ ។ មេធាវី សំអុន បានបន្តសួរទាក់ទងនឹងឋានៈរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន នៅអំឡុងពេលដែលលោកនៅធ្វើជាប្រធាននិស្សិតពេទ្យ ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានបំភ្លឺថា ខ្លួនមានតួនាទីអប់រំសិស្សពីការរស់នៅ ការហូបចុក និងការរៀនសូត្រ ចំណែកឯតួនាទីចាត់ចែង ឬលើសពីនេះ លុះត្រាតែមានការអនុញ្ញាតពីប្រធានមន្ទីរពេទ្យទើបលោកមានសិទ្ធិធ្វើ ។ ចំពោះការចូលរួមរៀនសូត្រផ្នែកនយោបាយដែលមានរយៈពេល ៧ថ្ងៃ ដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន បានចូលរួមតែ៤ថ្ងៃប៉ុណ្ណោះ ។ លោកមេធាវីបានអាននូវភាពខុសគ្នារវាងសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការ និងអត្ថន័យនៅក្នុងសំណេរដែលដើមបណ្ដឹងរដ្ឋប្បវេណីបានសរសេរពេលដាក់ពាក្យបណ្ដឹងទាក់ទងនឹងមូលហេតុនៃការស្លាប់របស់ម្ដាយលោក ។ នៅក្នុងសក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីឆ្លើយថាម្ដាយរបស់ខ្លួនស្លាប់ ដោយសារតែការភិតភ័យចំពោះការទម្លាក់គ្រាប់បែករបស់អាមេរិក រីឯនៅក្នុងសំណេររបស់លោកសរសេរថា "ឯម្ដាយ ខ្ញុំបាទត្រូវពួក ប៉ុល ពត ចាប់សម្លាប់តាំងពីឆ្នាំដែលឪពុកខ្ញុំត្រូវបានពួក ប៉ុល ពត ចាប់គាត់យកទៅសម្លាប់...." ។ ឆ្លើយតបនឹងភាពខុសគ្នានេះ អែម អឿន បានជម្រាបជូនអង្គជំនុំជម្រះថា ខ្លួនទទួលស្គាល់ចំពោះសំណេរដែលសរសេរទុករួចហើយ ប៉ុន្តែលោកសូមរំឭកថាទាំងពេលដែលខ្លួនសរសេរ និងពេលឆ្លើយនោះខ្លួនមានការភ្លេចភ្លាំងច្រើន ។

មុនពេលបញ្ចប់ការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន អង្គជំនុំជម្រះបានផ្ដល់ឱកាសដល់ដើមបណ្ដឹងរដ្ឋប្បវេណីធ្វើសេចក្ដីថ្លែងពីទុក្ខសោកដែលធ្លាប់ឆ្លងកាត់នៅក្នុងរបបខ្មែរក្រហមដោយកំហិតត្រឹមការប៉ះពាល់ដែលទាក់ទងនឹងដើមបណ្ដឹងរដ្ឋប្បវេណី កើតឡើងនៅចន្លោះថ្ងៃទី១៧ ខែមេសា


ដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន

១៩៧៥ ដល់១៩៧៩ ហើយបន្តមកដល់បច្ចុប្បន្ន ។ អែម អឿន បានសំដែងនូវអារម្មណ៍ថ្លែងអំណរគុណដល់គ្រប់ភាគីនៅក្នុងតុលាការដោយការលើកដៃសំពះ ។ លោកបានស្បថថាអ្វីដែលលោកនឹងនិយាយ គឺជាការពិត ។ បន្ទាប់មកលោកបាននិយាយរៀបរាប់អំពីទុក្ខសោករបស់ខ្លួន និងផលវិបាកដែលទទួលរងដោយសាររបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែការរៀបរាប់របស់លោកបានចេញផុតពីវិសាលភាពដែលអង្គជំនុំជម្រះបានកំណត់ ជាហេតុនាំឲ្យអង្គជំនុំជម្រះធ្វើការក្រើនរំឭក ដើម្បីគ្រប់គ្រងពេលវេលាសវនាការឲ្យមានប្រសិទ្ធិភាព និងដើម្បីជៀសវាងការអូសបន្លាយពេលវេលា ។ ភ្លាមៗនោះ ដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន បានបញ្ចប់សេចក្ដីថ្លែងទុក្ខសោករបស់ខ្លួនបន្ទាប់ពីមានការណែនាំពីអង្គជំនុំជម្រះ ។

**សូមបញ្ជាក់ថា**

សវនាការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី អែម អឿន បានបញ្ចប់នៅ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១២ ។

# សវនាការលើការសាកសួរសាក្សី នង សុផង់
## នៅថ្ងៃទី២៩ ខែសីហា និងថ្ងៃទី៣ ដល់ទី៦ ខែកញ្ញា ឆ្នាំ២០១២

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានបន្តកិច្ចដំណើរការនីតិវិធីសាកសួរដេញដោលសាក្សី នង សុផង់ ដែលជាអតីតប្រធានមន្ទីរបកប្រែឯកសារទូរលេខ និងជាបុគ្គលិកនៅក្រសួងឃោសនាការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

កិច្ចដំណើរការសាកសួរសាក្សី នង សុផង់ បានធ្វើឡើងរយៈពេល៤ថ្ងៃកន្លះ ដែលចាប់ផ្តើមដោយប្រធានអង្គជំនុំជម្រះ សហព្រះរាជអាជ្ញា មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីការពារជនជាប់ចោទទាំងបីក្រុម ។ ការសួរដេញដោលផ្តោតជាសំខាន់លើភារកិច្ចរបស់សាក្សីនៅមន្ទីរបកប្រែសារទូរលេខ និងប្រតិបត្តិការក្នុងការបញ្ជូនសារទូរលេខពីគណៈមជ្ឈិមទៅភូមិភាគ តំបន់ និងថ្នាក់ក្រោម រួមទាំងការរាយការណ៍ពីថ្នាក់ក្រោមឡើងមកថ្នាក់លើវិញ ។

### ១) ប្រវត្តិសាវតាររបស់សាក្សី

ប្រធានអង្គជំនុំជម្រះ គឺលោកចៅក្រម និល ណុន បានចាប់ផ្តើមសាកសួរដោយផ្តោតលើប្រវត្តិសាវតាររបស់សាក្សី ។ ជាការឆ្លើយតប សាក្សី នង សុផង់ បានបញ្ជាក់ជូនអង្គជំនុំជម្រះថា លោកធ្លាប់បានប្រើប្រាស់ឈ្មោះ នង សេងជីម ហើយសព្វថ្ងៃមានអាយុ៦០ឆ្នាំ មានឪពុកឈ្មោះ នង ជីម ម្តាយឈ្មោះ អ៊ុន ទឹត និងមានប្រពន្ធឈ្មោះ ញឹក ហំ រស់នៅភូមិដីក្រហម ឃុំតាសែន ស្រុកកំរៀង ខេត្តបាត់ដំបង ។


ប្រធានអង្គជំនុំជម្រះ និល ណុន

បន្ទាប់មក លោកចៅក្រម បានបន្តសួរទាក់ទងនឹងបទសម្ភាសន៍ ដែលសាក្សីបានធ្វើនៅចំពោះមុខសហ ចៅក្រមស៊ើបអង្កេត ។ ឆ្លើយតបនឹងសំណួរនេះសាក្សីបានបញ្ជាក់ថា លោកពិតជាធ្លាប់បានផ្តល់បទសម្ភាសន៍ចំនួនពីរដងជូនការិយាល័យសហចៅក្រមស៊ើបអង្កេតនៅក្នុងអំឡុងឆ្នាំ២០០៩ ។ បន្ទាប់មក ប្រធានអង្គជំនុំជម្រះ និល ណុន បានផ្ទេរវេទិកាជូនសហព្រះរាជអាជ្ញាដើម្បីបន្តការសាកសួរសាក្សី នង សុផង់ ។

### ២) ការសួរដេញដោលសាក្សីដោយសហព្រះរាជអាជ្ញា

ក្នុងអំឡុងពេលនៃការសួរដេញដោលសាក្សី នង សុផង់ សហព្រះរាជអាជ្ញាបានចំណាយពេលចំនួន ពីរថ្ងៃកន្លះ គឺចាប់ផ្តើមពីរសៀលថ្ងៃទី២៩ ខែសីហា រហូតដល់ថ្ងៃទី៣-៤ ខែកញ្ញា ឆ្នាំ២០១២ ។ ការសាកសួរនេះ គឺផ្តោតជាសំខាន់លើប្រព័ន្ធទំនាក់ទំនងការងារនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយសារតែសាក្សីរូបនេះ គឺជាអ្នកបកប្រែសារទូរលេខ និងមានការយល់ដឹងច្រើនអំពីប្រព័ន្ធទំនាក់ទំនងការងាររវាងថ្នាក់លើ និងថ្នាក់ក្រោមនៃកម្មាភិបាលខ្មែរក្រហម ។

#### ២.ក) តំណាង សហព្រះរាជអាជ្ញាជាតិ

តំណាងសហព្រះរាជអាជ្ញាជាតិ វ៉េង ហ៊ិត បានសាកសួរសាក្សី នង សុផង់ ដោយផ្តោតជាសំខាន់លើតួនាទី និងភារកិច្ចរបស់សាក្សីមុនឆ្នាំ១៩៧៥ និងក្រោយពេលខ្មែរក្រហមរំដោះបានទីក្រុងភ្នំពេញ ។

#### ២.ក.១) តួនាទី និងភារកិច្ចនៅមន្ទីរ-១៧

តំណាងសហព្រះរាជអាជ្ញាជាតិ វ៉េង ហ៊ិត បានចាប់ផ្តើមការសាកសួរទាក់ទងនឹងបទសម្ភាសន៍របស់សហចៅក្រមស៊ើបអង្កេត

អំពីការចូលបំពេញការងារនៅផ្នែកមជ្ឈិមរបស់សាក្សីនៅមន្ទីរប-១៧ដែលដឹកនាំ ដោយឈ្មោះ ហង់ ដើម្បីស្នើឲ្យសាក្សីធ្វើការបញ្ជាក់ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សី សុផង់ បានបញ្ជាក់ថា ហង់ គឺជាសមាជិកគណៈតំបន់ព្រះវិហារ ហើយសាក្សីស្គាល់ ហង់ នៅពេលចូលរួមក្នុងវគ្គប្រជុំនយោបាយ និងបំពាក់បំប៉នសតិអារម្មណ៍មុនពេលចូលធ្វើការនៅថ្នាក់មជ្ឈិម ។ សាក្សីបានបញ្ជាក់បន្ថែមថា ប-១៧ គឺជាមន្ទីរសម្រាប់លត់ដំ បង្កបង្កើនផលដំណាំសម្រាប់ខុទ្ទកាល័យ និងជាកន្លែងសាកល្បងធ្វើការងារមុនពេលបញ្ជូនឲ្យទៅថ្នាក់មជ្ឈិម ដែលមានទីតាំងនៅភូមិបិតត្បូ ខេត្តកំពង់ចាម ។ សាក្សីបានបន្តថា នៅអំឡុងពេលនោះ លោកធ្លាប់បានឃើញមេដឹកនាំមួយចំនួនដូចជា ប៉ុល ពត និង នួន ជា បានធ្វើទស្សនកិច្ចនៅមន្ទីរប-១៧ ។

ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាទាក់ទងនឹងសកម្មភាពនៅមុនឆ្នាំ១៩៧៥ សាក្សី បានអះអាងថា នៅពាក់កណ្តាលឆ្នាំ១៩៧៣ លោកត្រូវបានបញ្ជូនទៅរៀនបកប្រែសារទូរលេខដែលមាន ប៉ុន និងថេរ ជាអ្នកបណ្តុះបណ្តាល ។ ឆ្លើយតបនឹងសំណួរដែលសួរថា តើសាក្សីមានតួនាទីអ្វីខ្លះក្នុងឋានៈជាបកប្រែសារទូរលេខ? សាក្សីបានបន្តពន្យល់ថា ការងាររបស់ខ្លួនគឺរង់ចាំទទួលសារទាំងឡាយដែលផ្ញើចូល និងបញ្ជូនសារចេញ ។ ចំពោះសារផ្ញើចូលដែលមានលេខកូដសម្ងាត់ គឺត្រូវយកមកបកប្រែទៅជាឯកសារធម្មតាមុន នឹងបញ្ជូនឲ្យ ប៉ុន ។ ចំណែកឯសារទូរលេខដែលផ្ញើមកពីខាងមូលដ្ឋាន ភូមិភាគ ឬសមរភូមិ ត្រូវបញ្ជូនមកខ្លួនតាមរយៈវិទ្យុទាក់ទងទូរ លេខ ។ ចំណែកឯកសារដែលផ្ញើចេញគឺត្រូវយកមកបកប្រែជា លេខសម្ងាត់វិញ ។


សាក្សី នង សុផង់

## ២.ក.២) ការងារបកប្រែ និងបញ្ជូនឯកសារទូរលេខ នៅមន្ទីរ ប-២០

តំណាងសហព្រះរាជអាជ្ញា ជាតិ វ៉េង ហ៊ត់ បានបន្តសាកសួរសាក្សីទាក់ទងនឹងតួនាទី និងភារកិច្ចនៅមន្ទីរប-២០ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបាន រៀបរាប់ថា នៅឆ្នាំ១៩៧៤ខ្លួនត្រូវបានចាត់តាំង ឲ្យទៅព្រៃចេកដែលជាកន្លែងបង្កបង្កើនផលសម្រាប់ខុទ្ទកាល័យសមរភូមិមុខ ។ នៅទីនោះ សាក្សីមានតួនាទីជាប្រធានក្រុមបកប្រែសារទូរលេខ ។ សាក្សីបានបញ្ជាក់បន្ថែមអំពីរចនាសម្ព័ន្ធនៅមន្ទីរប-២០ថា នៅទីនោះមានអង្គភាពបី គឺអង្គភាពបកប្រែសារទូរលេខ អង្គភាពទទួល និងបញ្ជូនសារទូរលេខ, អង្គភាពផ្សាយសំឡេង និងវិទ្យុផ្សាយសំឡេង ។

ឆ្លើយតបនឹងសំណួរបន្ទាប់របស់តំណាងសហព្រះរាជអាជ្ញាទាក់ទងនឹងការបញ្ជូន និងទទួលសារ សាក្សីបានពន្យល់ថា សារចូលគឺជាប្រភេទរបាយការណ៍ពីខាងមូលដ្ឋាន និងខាងសមរភូមិមុខរាយការណ៍មកសមរភូមិក្រោយ ។ ចំណែកឯការបញ្ជូនសារចេញ

គឺជាសេចក្ដីណែនាំរបស់ថ្នាក់លើដើម្បីឲ្យថ្នាក់ក្រោមយកទៅអនុវត្ត ។ សាក្សីបានបន្ថែមថា ចំពោះការបកប្រែឯកសារទូរលេខជូនថ្នាក់លើ គឺត្រូវយកពាក្យធម្មតាមកសរសេរជាលេខកូដជាច្រើនដងទើបបញ្ជូនឲ្យ ប៉ុន តាមរយៈនីសារ ហើយ ប៉ុន គឺជាអ្នកផ្ញើ និងចម្លងជូនថ្នាក់លើ ។ ចំណែកសេចក្ដីណែនាំពីថ្នាក់លើទៅថ្នាក់ក្រោមវិញ គឺមានទាក់ទងនឹងផ្នែក នយោបាយ យោធា សង្គមកិច្ច និងសភាពការណ៍ផ្សេងៗ ។ ចំពោះបញ្ហាសេដ្ឋកិច្ច និងវប្បធម៌ គឺមានផ្នែកផ្សេងៗទៀតដែលទទួលសារពី ខៀវ សំផន និង នួន ជា ។ តំណាងសហព្រះរាជអាជ្ញាបានបន្តសំណួរ ទាក់ទងការបញ្ជូនសារទូរលេខ ដែលនិយាយអំពីការរំដោះទីក្រុងភ្នំពេញ និងការជម្លៀសប្រជាជន ។ សាក្សី នង សុផង់ បានបញ្ជាក់ថា នៅពេលនោះខ្លួនបានទទួលសារដែលនិយាយអំពីការរៀបចំផែនការ កងទ័ព និងអាវុធគ្រាប់រំសេវ ប៉ុន្តែ ខ្លួនមិនដែលទទួលបានសារទាក់ទងនឹងការជម្លៀសទេ ។

### ២.ក.៣) ការចូលមកដល់ទីក្រុងភ្នំពេញនៅឆ្នាំ១៩៧៥

បន្ទាប់ពីបញ្ចប់ការសាកសួរទាក់ទងនឹងការងាររបស់សាក្សីនៅមុនឆ្នាំ១៩៧៥ តំណាងសហព្រះរាជ អាជ្ញាជាតិ វ៉េង ហ៊ត់ បានបន្តសាកសួរទាក់ទងនឹងសភាពការណ៍ពេលចូលមកដល់ទីក្រុងភ្នំពេញ ។ សាក្សីបានរៀបរាប់ថា ខ្លួនបានចូលមកដល់ភ្នំពេញនៅចុងឆ្នាំ១៩៧៥ និងសង្កេតឃើញថានៅក្នុងទីក្រុងនាពេលនោះ មានសភាពស្ងប់ស្ងាត់មិនមានប្រជាជនរស់ឡើយ ។ ក្រោយពេលមកដល់អគ្គភាពរបស់លោកដែលមានទីតាំង នៅក្នុងវិទ្យាល័យសម្ដេចសុធារស សាក្សីត្រូវបានផ្ដល់ភារកិច្ចជាគ្រូបណ្ដុះបណ្ដាលយុវជនដែលមកពីបណ្ដាភូមិភាគដោយបង្រៀនលេខ អក្សរខ្មែរ ឡាតាំង បារាំង និងអង់គ្លេស បង្រៀនអំពីរបៀបវាយអង្គុលីលេខ និងបង្រៀនយុវជនទាំងនោះឲ្យចេះបកប្រែឯកសារសម្ងាត់ជាដើម ។ សាក្សីបានបន្តថា ក្រៅពីការងារបង្រៀន ខ្លួនបានបន្តការងារជាអ្នកបកប្រែឯកសារថែមទៀត ។ សាក្សីបានបញ្ជាក់ថា ក្នុងរយៈពេលនៃរបបកម្ពុជាប្រជាធិបតេយ្យលោកបង្រៀនក្មេងៗបានចំនួនត្រឹមតែពីរដងប៉ុណ្ណោះ ។

បន្ទាប់ពីបញ្ចប់ការសាកសួររបស់ខ្លួន តំណាងសហព្រះរាជអាជ្ញា វ៉េង ហ៊ត់ បានផ្ទេរវេទិកាជូនសហភាគីអន្តរជាតិរបស់ខ្លួន គឺលោក អាប់ឌុលហាក់ ផារីក ។

### ២.ខ) តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ

### ២.ខ.១) ការបញ្ជូនសារទូរលេខ

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ អាប់ឌុលហាក់ ផារីក បានចាប់ផ្ដើមសួរទាក់ទងនឹងការរាយការណ៍របស់ភូមិភាគទៅថ្នាក់លើមុនឆ្នាំ១៩៧៥ ។ សាក្សីបានបញ្ជាក់ថា មុនឆ្នាំ១៩៧៥ អង្គភាពដែលមានទំនាក់ទំនងជាមួយថ្នាក់លើមានដូចជា ភូមិភាគពិសេស ភូមិភាគបូព៌ា ភូមិភាគឧត្តរ ភូមិភាគឦសាន ភូមិភាគពាយ័ព្យ ភូមិភាគនិរតី ភូមិភាគបស្ចិម និងតំបន់ស្វយ័តបីផ្សេងទៀត ដូចជា ព្រះវិហារ មណ្ឌលគិរី និងសៀមរាប-ឧត្ដរមានជ័យ ។ ចំណែកខាងកងទ័ព គឺ សុន សេន ជាអ្នកទាក់ទងមកថ្នាក់លើផ្ទាល់ ។ សាក្សីបានបន្តថា រាល់ភូមិភាគទាំងអស់សុទ្ធ



សហព្រះរាជអាជ្ញាអន្តរជាតិ អាប់ឌុលហាក់ ផារីក

តែមានដាក់លេខកូដដែលខ្លួន និង ប៉ុន គឺជាអ្នកកំណត់ ។ ចំពោះការផ្ញើសារ សាក្សីបានបញ្ជាក់ថា សារដែលផ្ញើចូលមានចំនួនច្រើនជាងសារដែលផ្ញើចេញ ហើយសារដែលត្រូវបកប្រែមានចំនួនច្រើនក្នុងមួយថ្ងៃៗ ដែលពេលខ្លះបុគ្គលិកត្រូវបកប្រែទាំងយប់ទាំងថ្ងៃទៀតផង ។ ចំពោះការបញ្ជូនសារ គឺមានមកពីគ្រប់

ភូមិភាគទាំងអស់ លើកលែងភូមិភាគពិសេសតែមួយគត់ដែលមិនឆ្លងកាត់ មន្ទីរបកប្រែលេខកូដសម្ងាត់ ។ តំណាងសហព្រះរាជអាជ្ញាបានបន្តការសួរអំពីទំនាក់ទំនងរវាងសាក្សី និង ប៉ុន ដោយសាក្សីបញ្ជាក់ថា ខ្លួនធ្លាប់បានទាក់ទងជាមួយ ប៉ុន តាមរយៈសារទូរលេខសម្ងាត់ ។ សាក្សីបានបន្តថា សារទូរលេខនៅពេលនោះមានពីរប្រភេទ គឺសារទូរលេខសម្ងាត់ និងសារចំហ ។ លោកបានផ្តល់ជាឧទាហរណ៍អំពីសារចំហថា គឺជាប្រភេទសារដែលនិយាយពីជ័យជម្នះ មិនចាំបាច់មានការបកប្រែទេ គឺ ទទួលបានសារជាអក្សរខ្មែរស្រាប់តែម្តង ។

## (២.១.២) មន្ទីរបកប្រែឯកសារសារទូរលេខ

លោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ អាប់ឌុលហាក់ ថារីក បានបន្តសួរទាក់ទងនឹងអ្នកគ្រប់គ្រងមន្ទីរបកប្រែសារទូរលេខ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា នៅមន្ទីរក-១ គឺមាន ប៉ុន ជាអ្នកគ្រប់គ្រង ។ ចំណែកមន្ទីរដែលមានទីតាំងនៅក្នុងវិទ្យាល័យសម្តេចសុធារស គឺខ្លួនជាអ្នកទទួលខុសត្រូវ ហើយផ្នែកវាយ និងបញ្ជូនសារទូរលេខទៅស្ថានទូតអាមេរិកចាស់ដែលហៅថាមន្ទីរក-១៨ គឺមានឈ្មោះ យស់ ជាអ្នកគ្រប់គ្រង ។ ជារួមមន្ទីរក-១មាននាទីគ្រប់គ្រងមន្ទីរក-១៨ និងអង្គភាពវាយ និងបញ្ជូនឯកសារនៅស្ថានទូតអាមេរិកចាស់ ។ ទាក់ទងនឹងការបញ្ជូនសារទូរលេខនេះ សាក្សីបានបញ្ជាក់ថា នៅមន្ទីរនីមួយៗមានដាក់លេខកូដសម្គាល់របស់ខ្លួន ដូចជា នៅមន្ទីររបស់លោកគឺមានលេខកូដ៣៨ហើយអង្គភាពនៅស្ថានទូតអាមេរិកមានលេខកូដ៥៧ ។ សាក្សីបានបន្តថា ក្នុងករណីដែលមានសារច្រើនដែលបញ្ជូនមកពីភូមិភាគ ហើយមន្ទីររបស់ខ្លួនមិនអាចបកប្រែទាន់ពេលវេលា សារទាំងនោះនឹងត្រូវបញ្ជូនទៅមន្ទីររបស់ ប៉ុន ផ្ទាល់តែម្តង ។

បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានលើកយកការផ្តល់សក្ខីកម្មពីមុនទាក់ទងនឹងឯកសារ ម៉ស ។ ឆ្លើយតបនឹងបញ្ហានេះសាក្សីបានបញ្ជាក់ថា ការផ្ញើសារពីមជ្ឈិមទៅភូមិភាគត្រូវបានប្រើប្រាស់ជាមួយ ម៉ស ដែលជាប្រភេទឯកសារអក្សរខ្មែរដែលហៅថា សារចំហ ហើយភាគច្រើនសារនោះ គឺនិយាយអំពីជ័យជម្នះ ។ ចំពោះមន្ទីរក-១៨ នៅពេលផ្ញើឯកសារចេញគឺត្រូវផ្ញើទៅមន្ទីរក-១ជាមុន ដើម្បីបញ្ជូនទៅតាមកន្លែងផ្សេងៗទៀត ដូចជានៅភូមិភាគបូព៌ាដែលមានលេខកូដ A75 ។ ចំពោះការបញ្ជូនសារវិញ គឺប្រើតាមម៉ាស៊ីនរ៉ាកាណូ រវៃដោយដៃនិងចុចសញ្ញាទូរលេខ ។ លោកបានបន្តថា នៅពេលមន្ទីរបកប្រែឯកសារបញ្ជូនសារចេញ គឺប្រើម៉ាស៊ីនប្រេកង់ដើម្បីបញ្ជាក់ថាភាគីម្ខាងទៀតទទួលបានដែរឬយ៉ាងណា ដោយមើលលើលេខសម្ងាត់ ។ ក្នុងករណីដែលភាគីម្ខាងទៀតទទួលបានចម្លើយដូចគ្នា


ឧបករណ៍ផ្សាយសំឡេងនៅអំឡុង

ទើបផ្ញើឯកសារចេញទៅ ។ ទាក់ទងនឹងការកម្រិតវិន័យរបស់បុគ្គលិកនៅកន្លែងធ្វើការសាក្សី នង សុផន់ បានបញ្ជាក់ថា បុគ្គលិកម្នាក់ៗបានអនុវត្តតាមវិន័យយ៉ាងម៉ឺងម៉ាត់ល្អតាមការកំណត់របស់អង្គការជានិច្ច ។

## (២.១.៣) អំពីមន្ទីរផ្សេងៗទៀត

ក្រៅពីមន្ទីរបកប្រែរបស់សាក្សី តំណាងសហព្រះរាជអាជ្ញាបានបន្តសួរទាក់ទងនឹងមន្ទីរបកប្រែនៅក្រសួងការបរទេស ។

ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា សាក្សីមិនបានដឹងច្បាស់ទេថានៅក្រសួងការបរទេសមានមន្ទីរបកប្រែដែរ ឬយ៉ាងណា ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាបានបន្តការសួរទាក់ទងនឹងមន្ទីរក-៧ ដែលសាក្សីបានបញ្ជាក់នៅក្នុងសេចក្តីថ្លែងការណ៍ថា មន្ទីរនោះជាមន្ទីរនីរសារដើម្បីទទួល និងបញ្ជូនសំបុត្រទៅតាមបណ្តាភូមិខេត្តនានា ហើយក្នុងករណីដែល



ពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ

មានភ្ញៀវចង់ទាក់ទងមន្ទីរក-១ គឺត្រូវឆ្លងកាត់មន្ទីរនេះជាមុនសិន ។ សាក្សីបានបន្តថា មន្ទីរក-៧ មានឈ្មោះ ព្រាំ ជាអ្នកមើលការខុសត្រូវ ។ ភាគច្រើននៃសំបុត្រដែលត្រូវផ្ញើទៅមន្ទីរក-៧ គឺទាក់ទងនឹងសំណើសុំសម្ភារៈប្រើប្រាស់ផ្សេងៗដែលជាប្រភេទសារចំហ ។ ប្រសិនបើសារនោះជាប្រភេទសារសម្ងាត់ គឺត្រូវតែផ្ញើទៅមន្ទីរ-១៨ ។ ម្យ៉ាងទៀត ក្នុងការផ្ញើទំនាក់ទំនងដោយសម្ងាត់ គឺអ្នកផ្ញើអាចទៅជួបជាមួយគណៈមជ្ឈិមផ្ទាល់តែម្តង ។

សាក្សីបានបន្ថែមថា ពេលខ្លះការទាក់ទងដោយសម្ងាត់ក៏អាចទាក់ទងតាមសារទូរលេខដែរ ដូចជាមានការអញ្ជើញប្រធានភូមិភាគដើម្បីប្រជុំថ្នាក់ជាតិនៅបុរីកីឡាជាដើម ។ ចំពោះការបញ្ជូនសារទាំងនោះ សាក្សីបានបញ្ជាក់ថា ប៉ុន គឺជាអ្នកមានសិទ្ធិបែងចែកទិសដៅផ្ញើ និងចម្លងជូនថ្នាក់លើ ។

## ២.១.៤) ការបកប្រែសារទូរលេខ

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានសួរបន្តដោយលើកយកឯកសារជាតារាង១០០ក្រឡាសម្រាប់បំភ័ន្តអក្ខរៈដើម្បីឲ្យសាក្សីពន្យល់ ។ សាក្សីបានពន្យល់ថា ការបំភ័ន្ត គឺជាការប្រែអក្សរធម្មតាឲ្យទៅជាលេខកូដដោយសាក្សីបានលើកជាឧទាហរណ៍យ៉ាងក្បោះក្បាយ ។ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បង្ហាញឯកសារដែលសាក្សីបានផ្តល់សក្ខីកម្មនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ពាក់ព័ន្ធនឹងការកោះហៅអ្នកដែលធ្វើការនៅកន្លែងផ្សេងៗឲ្យមកចូលរួមពិនិត្យមើលតារាងនៃការទទួល និងបញ្ជូនសារទូរលេខ និងរបៀបនៃការបំលែងសារឲ្យទៅជាសារសម្ងាត់ ។ សាក្សីបានបញ្ជាក់ថា នៅតាមភូមិភាគផ្សេងៗ គឺមានអ្នកបកប្រែស្រាប់តាំងពីសម័យមុនៗ ដោយឡែកនៅភូមិភាគឦសានតំបន់មណ្ឌលគិរី មិនមានអ្នកជំនាញខាងបកប្រែសារទេ ដូច្នេះខ្លួនហៅអ្នកដែលនៅភូមិភាគឦសានមករៀនពីរបៀបបកប្រែនៅមន្ទីរក-៧ ។ ចំពោះការបំភ័ន្តអក្ខរៈ សាក្សីបានបញ្ជាក់ថា សារសម្ងាត់នោះមិនទាន់យកមកបកប្រែភ្លាមទេ គឺត្រូវប្រែខ្លឹមសារធម្មតាឲ្យទៅជាលេខសំងាត់ជាមុនសិន រួចហើយទើបអាចបង្កើនដានម្តងទៀតដើម្បីផ្ញើចេញ ។ ការបំភ័ន្តបែបនេះ គឺហៅថាជាការបំភ័ន្តកំរិតខ្ពស់ទាក់ទងនឹងការធ្វើដំណើររបស់កម្មាភិបាល និងកិច្ចការផ្ទៃក្នុងរបស់បក្ស ។

## ២.១.៥) ការចម្លងឯកសារជូនមេដឹកនាំ

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានលើកយកនូវឯកសារសារទូរលេខ ដែលមានលេខ៩៤ ដើម្បីឲ្យសាក្សីពន្យល់ ។ សាក្សីបានពន្យល់ថា ឯកសារនោះនិយាយអំពីសភាពការណ៍ខ្លាំងដែលមានលើកឡើងពីអំពើខុសសីលធម៌ដែលមានសរសេរថា "គោរពជូនបងជាទីគោរព" ។ សាក្សីបានបញ្ជាក់ថា ពាក្យ "បង" គឺសំដៅលើ ប៉ុល ពត ដែលជាលេខាបក្ស ។ នៅក្នុង

សារនោះក៏មានសរសេរថា អ៊ឹ នួន នៅខាងឆ្វេងដែរ ។ ការណ៍ដែលសរសេរដូច្នេះគឺមានន័យថា ឯកសារនេះត្រូវបានផ្ញើទៅ នួន ជា ដោយសារ នួន ជា ទទួលភារកិច្ចលើបញ្ហាសង្គម និងសីលធម៌ ។ តំណាងសហព្រះរាជអាជ្ញា ថារីក បានបន្តសំណួរទាក់ទងនឹងសារទូរលេខ៥៨ ដែលសាក្សីបានបញ្ជាក់ថា ឯកសារនេះជាប្រភេទឯកសារចេញមកពីខេត្តមណ្ឌលគិរី ហើយលេខ៥៨ គឺសំដៅទៅលើលេខរៀងនៃសារទូរលេខនោះ ។ សាក្សីបានបន្តថា ការដាក់លេខនេះ គឺបានដាក់ចាប់ពី០១ ទៅដល់៩៩ និងត្រឡប់មក០១វិញ ។ ចំពោះការបញ្ជូនសារ សាក្សីបានបញ្ជាក់ថា នៅពេលខ្លួនបកប្រែសារទូរលេខនោះរួច ខ្លួនត្រូវចុះថ្ងៃខែ និងម៉ោង រួចបញ្ជូនទៅឲ្យ ប៉ុន និង ថេរ ដើម្បីចម្លងនិងបញ្ជូនទៅថ្នាក់លើ ប៉ុន្តែករណីខ្លះមានការបញ្ជាឲ្យលោកចម្លងឯកសារជាច្រើនច្បាប់ដែរ ។ សាក្សីបានបន្តថា បន្ទាប់ពីបញ្ជូនឯកសារដែលបកប្រែរួចទៅមន្ទីររបស់ ប៉ុន រួចហើយ ឯកសារមួយច្បាប់ត្រូវរក្សាទុកនៅមន្ទីររបស់ខ្លួន ។ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានបន្តសួរសាក្សីថា តើគណៈ៨៧០ សំដៅលើអ្វី? ឆ្លើយតបនឹងសំណួរនេះ សាក្សីបានពន្យល់ថា ពាក្យ“៨៧០” មិនសំដៅទៅលើបុគ្គលណាម្នាក់ឡើយ គឺសំដៅលើគណៈមជ្ឈិម ប៉ុន្តែបើសារនោះមានចារថា “ជូនបងជាទីគោរព” គឺសំដៅទៅលើបងទី១ គឺ ប៉ុល ពត ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបន្តសួរដោយបង្ហាញឯកសារទូរលេខ ដែលមានរៀបរាប់ពីការបំបែកជនជាតិចាមនៅភូមិភាគបូព៌ា និងមានការស្នើសុំសម្ភារៈប្រើប្រាស់យកទៅភូមិភាគ ។ ទាក់ទងនឹងឯកសារនេះសាក្សីបានបញ្ជាក់ថា ជាឯកសារដែលត្រូវបានផ្ញើជូន ប៉ុល ពត ប៉ុន្តែខ្លួនមិនបានបកប្រែឯកសារទាំងនោះទេ ដោយសារឯកសារនោះផ្ញើចេញពីភូមិភាគបូព៌ាផ្ទាល់ ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានលើកឡើងនូវឈ្មោះរបស់កម្មាភិបាលមួយចំនួន ដែលមានសរសេរថា “ចម្លងជូនបងនួន បងខឿន បងយ៉ែម និងទុកជាឯកសារ” ដើម្បីឲ្យសាក្សីពន្យល់ ។ សាក្សីបានបញ្ជាក់ថា ទាក់ទងនឹងឈ្មោះ ខឿន បើយោងលើខ្លឹមសារនៃសារនោះលោកមិនដឹងថា ខឿន ជាអ្នកណានោះទេ ។ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងនូវឯកសារសារទូរលេខដែលផ្ញើជូន ខឿន និងមានរៀបរាប់អំពីការស្នើសុំសម្ភារៈផ្សេងៗព្រមទាំងការបញ្ជូនបុគ្គលិកនៅខាងវិទ្យុឲ្យទៅរៀននៅខាងអក្សរសម្ងាត់ ។ សាក្សីបានបញ្ជាក់ថា ខ្លួនមិនដឹងច្បាស់ថា តើ ខឿន មានតួនាទីជាអ្វីនៅគណៈអចិន្ត្រៃយ៍ទេ ។ តំណាងសហព្រះរាជអាជ្ញាបានបន្តដោយលើកយកនូវឯកសារកំណត់ហេតុសាក្សីដែលធ្វើឡើងដោយ សហចៅក្រមស៊ើបអង្កេតនិយាយអំពីតួនាទីរបស់ ខឿន ។ ជាថ្មីម្តងទៀត សាក្សីបានបញ្ជាក់ថា ខ្លួនមិន បានដឹងពីតួនាទីរបស់ ខឿន ឡើយ ។ ភ្លាមនោះលោក អាកនូរ វែរកែន មេធាវីអន្តរជាតិការពារក្តី ខៀវ សំផន បានជំទាស់នឹងការសួររបស់តំណាងសហព្រះរាជអាជ្ញា ដោយអះអាងថា សំណួរនេះសាក្សីបាន ឆ្លើយរួចហើយ ប៉ុន្តែតំណាងសហព្រះរាជអាជ្ញាបានព្យាយាមសួរឲ្យសាក្សីឆ្លើយស្ទួនៗទៅវិញ ។ បន្ទាប់មក លោកម៉ៃឃើល ការណាវ៉ាស មេធាវីអន្តរជាតិការពារក្តី អៀង សារីក៏បានគាំទ្រចំពោះការជំទាស់របស់ក្រុមមេធាវីការពារក្តី ខៀវសំផន ដែរ ។ ជាការឆ្លើយតប ប្រធានអង្គជំនុំជម្រះ និល ណុនបានអនុញ្ញាតឲ្យតំណាងសហព្រះរាជអាជ្ញាបន្តការសួរ និងរំឭកដល់សាក្សីឲ្យឆ្លើយសំណួរណាដែលខ្លួនបានដឹង ជៀសវាងការឆ្លើយស្ទួនៗ ។

**សូមបញ្ជាក់ថា** មូលហេតុដែលសហព្រះរាជអាជ្ញាព្យាយាមសាកសួរទាក់ទងនឹងឈ្មោះ ខឿន គឺដោយសារតែឈ្មោះនេះធ្លាប់មានតួនាទីជាប្រធានមន្ទីរ៨៧០ ហើយបន្ទាប់មកត្រូវបានចាប់ខ្លួន និងសម្លាប់ដោយសារការចោទប្រកាន់ថា ក្បត់បដិវត្ត ។ បន្ទាប់មកមានការពិភាក្សាថា តំណែងនេះ ត្រូវបានជំនួសដោយ ខៀវសំផន ។ ប៉ុន្តែជនជាប់ចោទ ខៀវ សំផន ធ្លាប់បានបដិសេធជាច្រើនដងថា ខ្លួនមិនធ្លាប់កាន់កាប់តំណែងជាប្រធានមន្ទីរ៨៧០ម្តងណាឡើយ ។

### ២.១.៦) តួនាទីរបស់ ខៀវ សំផន

តំណាងសហព្រះរាជអាជ្ញាបានបន្តអានសេចក្តីថ្លែងការណ៍របស់សាក្សីដែលបញ្ជាក់ថា ខៀវ សំផន គឺជាអ្នកចាត់ចែងសម្ភារៈផ្សេងៗជូនប្រជាជន ។ នៅត្រង់ចំណុចនេះសាក្សីបានទទួលស្គាល់ចំពោះការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញា និងថា ខ្លួនធ្លាប់បានទទួលសាររបស់ ខៀវ សំផន តាមរយៈក្រុមរបស់ សំ

ហើយមានពេលខ្លះខ្លួនបានទទួលទូរស័ព្ទផ្ទាល់ពី ខៀវ សំផន ដើម្បីកត់ត្រាខ្លឹមសារ ។ បន្ថែមពីលើនេះ ខ្លួនបានបកប្រែឯកសាររបស់ ខៀវ សំផន ដែលមានលក្ខណៈជាសារាចរណ៍ណែនាំ ដូចជាសារាចរណ៍ ណែនាំទាក់ទងនឹងបុណ្យជាតិផ្សេងៗ ។ សាក្សីបាន


ខៀវ សំផន នៅប្រទេសបារាំង ឆ្នាំ១៩៨០

បន្តថា ក្នុងករណីដែលសាររបស់ ខៀវ សំផន មានលក្ខណៈមិនច្បាស់លាស់ នោះខ្លួនអាចសាកសួរ ខៀវ សំផន តាមរយៈទូរស័ព្ទបាន ។

## ២.១.៧) ការបញ្ជាក់លើឯកសារសារទូរលេខ

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានបន្តសួរដោយផ្តោតសំខាន់លើការបង្ហាញ ឯកសារសារទូរលេខជាច្រើនទៀតដើម្បីឲ្យសាក្សីបញ្ជាក់ ។ ឯកសារទាំងនោះភាគច្រើនជាឯកសារដែលផ្ញើមកពីភូមិភាគ និងតំបន់ផ្សេងៗដែលរាយការណ៍ជូនថ្នាក់លើទាក់ទងនឹងសភាពការណ៍នៅក្នុងតំបន់របស់ខ្លួន តម្រូវការស្បៀង បញ្ហានៅតាមព្រំដែនកម្ពុជា-វៀតណាម ការធ្វើពាណិជ្ជកម្មក្រៅប្រទេស និងបទបញ្ជាពីថ្នាក់លើដែលដាក់ឲ្យថ្នាក់ក្រោមអនុវត្តតាម ។ ក្នុងចំណោមឯកសារទាំងនោះ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ អាប់ឌុលហាក់ ថារីក បានបង្ហាញឯកសារទូរលេខដែលមានចំណងជើងថា *«សេចក្តីណែនាំរបស់៨៧០ កម្មវត្ថុ ៖ ទស្សនគោលជំហរ និងមាគ៌ាវាយខ្មាំងយួនឈ្លានពាន»* និងមានសំណេរដោយដៃនិង មានពណ៌ក្រហម ។ អត្ថន័យនៅក្នុងសារនោះ គឺជាការណែនាំឲ្យថ្នាក់តំបន់ ភូមិភាគ និងសហករណ៍ឲ្យអនុវត្តតាមផែនការថ្នាក់លើ ។ សាក្សីបានបញ្ជាក់ថាសំណេរនៅលើសារនោះគឺជាអក្សររបស់ ប៉ុល ពត ហើយតាមការចងចាំរបស់ខ្លួន ឯកសារដែលខ្លួនបានឃើញ គឺជាឯកសារដែលមានការកែសម្រួលចុងក្រោយរួចហើយ ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបន្តលើកឡើងនូវសារទូរលេខដែលចុះថ្ងៃទី៨ ខែមេសា ឆ្នាំ១៩៧៨ ដែលនៅក្នុងនោះមាននិយាយអំពីសភាពការណ៍ក្នុងមូលដ្ឋាន និងការសម្រិតសម្រាំងជាបន្តបន្ទាប់ ដោយនៅផ្នែកខាងក្រោមនៃឯកសារនោះមានចុះហត្ថលេខាដោយ «លេខ៤៧» ។ សាក្សីបានបញ្ជាក់ថា លេខ៤៧ គឺជាលេខកូដសម្ងាត់របស់ សុន សេន ។ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាថារីក បានបន្តសួរទាក់ទងនឹងចំណារនៅលើសារ ដែលសរសេរថា

"បងវ៉ាន់" ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបាន បញ្ជាក់ថា បងវ៉ាន់ គឺសំដៅលើ អៀង សារី ។

### ២.១.៨) ការបញ្ជាក់លើឯកសារជាប្រតិចារិក

បន្ទាប់ពីបញ្ចប់ការសាកសួរលើឯកសារសារទូរលេខ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក បានបន្តបង្ហាញ ឯកសារប្រតិចារិក ដើម្បីឲ្យសាក្សីធ្វើការបញ្ជាក់តទៅទៀត ។ ឯកសារទាំងនោះរួមមាន អង្គការលេខដែលនិយាយអំពីរចនាសម្ព័ន្ធនៃមន្ទីរ៨៧០ អង្គភាពទូរគមនាគមន៍ ភូមិភាគ តំបន់ ឃុំ និងភូមិ ។ សាក្សីបានបញ្ជាក់ថា ឯកសារនោះនិយាយអំពីរចនាសម្ព័ន្ធទំនាក់ទំនងការងារ ដែលជាទូទៅប្រសិនបើថ្នាក់ស្រុក ឃុំ និងភូមិ ចង់រាយការណ៍ជូនថ្នាក់លើចាំបាច់ គឺត្រូវរាយការណ៍ជូនភូមិភាគជាមុនសិន បន្ទាប់មកទើបភូមិភាគជាអ្នកបញ្ជូនសារទាំងនោះទៅថ្នាក់លើដោយឆ្លងកាត់ផ្នែកទូរគមនាគមន៍ ។ ដូចគ្នានេះដែរនៅក្រសួងផ្សេងៗ រួមទាំងផ្នែកយោធាផង ក៏មិនអាចទាក់ទងដោយផ្ទាល់មកផ្នែកទូរគមនាគនម៍ដែរ លើកលែងតែតំបន់ស្វយ័តទាំងបីតែប៉ុណ្ណោះ ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាបានស្នើឲ្យសាក្សីពន្យល់ពីអង្គការលេខនៃអង្គភាពគមនាគមន៍ ដោយសាក្សីបានរៀបរាប់ថា នៅក្រោមមន្ទីរ៨៧០គឺមានមន្ទីរ ក-១ និងស-៧១ តែប៉ុណ្ណោះ ។ នៅក្រោមមន្ទីរស-៧១មានមន្ទីរបីទៀតដែលស្ថិតនៅក្រោមការបញ្ជាគឺមន្ទីរក-៧ មន្ទីរក-៨ និងមន្ទីរក-១៨ ។

### ៣) ការសួរសាក្សីដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

នៅរសៀលថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១២ បន្ទាប់ពីតំណាងសហព្រះរាជអាជ្ញាបានបញ្ចប់ការសាកសួររបស់ខ្លួន អង្គជំនុំជម្រះបានប្រគល់វេទិកាសួរដេញដោលសាក្សី នង សុផន់ ជូនសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ ប៉ុន្តែសហមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក ពេជ អង្គ បានឡើងជម្រាបជូនអង្គជំនុំជម្រះថា លោកនឹងផ្ទេរវេទិកាសួរដេញដោលសាក្សី នង សុផន់ ជូនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោកស្រី ទី ស្រ៊ីនណា និងនិងមេធាវីអន្តរជាតិហ៊ីលីពីន



រូបទី៣រាប់ពីឆ្វេងគឺ សុន សេន បន្ទាប់មក ខៀវ សំផន និងរូបស្តាំបង្អស់ អៀង សារី (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

ស៊ុតហ្វ៍ ដែលជាជនជាតិបារាំង ។ ក្នុងអំឡុងពេលនៃការសួរដេញដោល មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូបបានសួរសាក្សីដោយផ្តោតជាសំខាន់លើប្រព័ន្ធការងារនៅក្នុងមន្ទីរបកប្រែលេខកូដសម្ងាត់ ។

### ៣.ក) មេធាវីជាតិ

មេធាវី ទី ស្រ៊ីនណា បានចាប់ផ្តើមសាកសួរសាក្សីដោយរំឭកឡើងវិញអំពីសំណួររបស់តំណាងសហព្រះរាជអាជ្ញាទាក់ទងនឹងការជួបជាមួយ ប៉ុល ពត និង នួន ជា នៅមន្ទីរប-១៧ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា ខ្លួនមិនបានជួបនិយាយសំណេះសំណាលដោយផ្ទាល់ជាមួយមេដឹកនាំទាំងនោះទេ គឺគ្រាន់តែឃើញមេដឹកនាំទាំងនោះ ដើរកាត់កន្លែងធ្វើការតែប៉ុណ្ណោះ ។ ម្យ៉ាងវិញទៀត សាក្សីបានស្គាល់ឈ្មោះមេដឹកនាំទាំងនោះ ដោយសារការនិយាយប្រាប់តៗគ្នា ។ បន្ទាប់មកមេធាវី ស្រ៊ីនណា បានបន្តសួរទាក់ទងនឹងការបកប្រែសារទូរលេខដែលនិយាយអំពីខ្មាំង លន់ នល់ ប៉ុន្តែសំណួរនេះសាក្សីបានបញ្ជាក់ថា ខ្លួនមិនធ្លាប់បានឃើញ និងទទួលបានសារទូរលេខនោះឡើយ ។ សាក្សីបានឆ្លើយតបនឹងសំណួរបន្តទាក់ទងនឹងប្រភេទសារទូរលេខថា សារនោះមានពីរប្រភេទ គឺសារទូរលេខចំហ និង សារសម្ងាត់ ។ សារដែលទាក់ទងនឹងការជួបគ្នាជាមួយគណៈតំបន់ និងថ្នាក់លើគឺជាប្រភេទសារសម្ងាត់ ។ ចំណែកសារទូរលេខចំហ គឺជាប្រភេទដំណឹងដែលទាក់ទងនឹងជ័យជម្នះផ្សេងៗ ។ សាក្សីបានបន្តថា បន្ទាប់ពីមានការបកប្រែរួចសារនោះត្រូវបញ្ជូនឲ្យ ប៉ុន ហើយក្នុងករណីមិនត្រឹមត្រូវ ឬមិនច្បាស់លាស់នោះ ប៉ុន នឹងទាក់ទងមកមន្ទីរខ្លួនដើម្បីកែតម្រូវឡើងវិញ ។

បន្ទាប់មកមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្រ៊ីនណា បានបន្តសាកសួរអំពីទំនាក់ទំនងរវាង មន្ទីរ៨៧០ និងសភាតំណាងរាស្ត្រ ។ សាក្សីបានពន្យល់ថា ខ្លួនមិនដែលបានឃើញសារណាដែលនិយាយពីការកោះប្រជុំនោះឡើយ ដោយសារតំណាងសភាប្រជាជនមានទីតាំងនៅទីក្រុងភ្នំពេញស្រាប់ ។ បន្ទាប់ពីលើកយកសារទូរលេខមួយចំនួនដែលសាក្សីបានឆ្លើយជាមួយតំណាងសហព្រះរាជអាជ្ញារួចមក មេធាវី ស្រ៊ីនណា បានបន្តលើកយកសារទូរលេខមួយចំនួនទៀតឲ្យសាក្សីបញ្ជាក់ដោយផ្តោតលើបទពិសោធការងាររបស់សាក្សីនៅក្នុងមន្ទីរបកប្រែ, ការធ្វើទំនាក់ទំនងរវាងមេដឹកខ្មែរក្រហម, សភាពការណ៍នៅតាមព្រំដែន និងការកម្រិតសម្រាំងខ្មាំងរបស់បក្ស ។

### ៣.ខ) មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុលីពីន ស៊ុតហ្វ៍ បានបន្តការសួរសាក្សី នង សុផង់ ដើម្បីបញ្ជាក់នូវចម្លើយទាំងឡាយដែលសាក្សីធ្លាប់បានឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញា ។ ភាគច្រើននៃសំណួរទាំងនោះ គឺទាក់ទងនឹងសារទូរលេខដែលសរសេរអំពីសភាពការណ៍នៅក្នុងទីក្រុងភ្នំពេញ និងការបង្ហាត់បង្រៀនរបស់សាក្សីនៅមន្ទីរបកប្រែលេខកូដសម្ងាត់ ។ បន្ទាប់មកមេធាវីបានលើកយកកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ដែលធ្វើឡើងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតទាក់ទងនឹងការបាត់ខ្លួនកម្មាភិបាលមួយចំនួន ដើម្បីឲ្យសាក្សីបញ្ជាក់ ។ សាក្សី នង សុផង់ បានបញ្ជាក់ថា ខ្លួនបានប្រាប់សហចៅក្រមស៊ើបអង្កេតថា ខ្លួនមិនដឹងច្បាស់ពីបញ្ហានេះទេ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតនៅតែបន្តសួរទើបខ្លួនចេះតែឆ្លើយទៅដូច្នេះហើយខ្លួនក៏បានស្នើឲ្យតុលាការលុបចោលនូវចម្លើយណាដែលមិនច្បាស់លាស់ចេញពីកំណត់ហេតុស្តាប់ចម្លើយវិញ ។

**សូមបញ្ជាក់ថា** បន្ទាប់ពីក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបញ្ចប់ការសាកសួរដេញដោលរបស់ខ្លួន អង្គជំនុំជម្រះបានប្រគល់វេទិកាបន្តជូនលោកចៅក្រម ហ្សង់ម៉ាក ឡាវែរញ (Jean-Marc Lavergne) សួរដេញដោលសាក្សីមុននឹងប្រគល់វេទិកាជូនមេធាវីការពារក្តីទាំងបីក្រុម ។

## ៤) ការសួរដេញដោលសាក្សីដោយចៅក្រម ហ្សង់ម៉ាក ឡាវែរញ

ចៅក្រមអន្តរជាតិដែលមានសញ្ជាតិបារាំង គឺលោកចៅក្រម ហ្សង់ម៉ាក ឡាវែរញ បានចាប់ផ្តើមសាកសួរ ដោយលើកយកឯកសារសារទូរលេខដែលចម្លងជូនអ៊ំ នួន បងវ៉ាន់ បងខៀវ ដើម្បីឲ្យសាក្សីពន្យល់ថា តើពាក្យ "អ៊ំ" និងពាក្យ "មន្ទីរ" នោះមានន័យជាពហុវចនៈ ឬឯកវចនៈ? ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា ពាក្យ "អ៊ំ" គឺសំដៅលើ ប៉ុល ពត ហើយពាក្យ"មន្ទីរ" គឺសំដៅលើមន្ទីរ៨៧០ ។ សាក្សីបានបន្ថែមថា ខ្លួនមិនដឹងពីទីតាំងនៃមន្ទីរ៨៧០នោះទេ ។ ចំពោះបុគ្គលដែលទទួល

ខុសត្រូវនៅមន្ទីរ៨៧០វិញ សាក្សីបានបញ្ជាក់ថា ខ្លួនមិនបានដឹងច្បាស់ពីមន្ទីរ៨៧០ទេ ប៉ុន្តែខ្លួនធ្លាប់បានឃើញសារចាត់តាំងដែលសរសេរថា ខៀន គឺជាអ្នកទទួលបន្ទុកខាងនយោបាយ ហើយ ប៉ង់ ជាអ្នកទទួលបន្ទុកខាងផ្នែករដ្ឋបាល ។

បន្ទាប់មកចៅក្រម ឡាវ៉ើញ បានបន្តលើកយកឯកសារសារទូរលេខដែលបានសាកសួរដោយតំណាងសហព្រះរាជអាជ្ញា ដើម្បីឲ្យសាក្សីបញ្ជាក់បន្ថែមថា តើឯកសារទាំងនោះត្រូវបានបកប្រែដោយអង្គភាពរបស់សាក្សីដែរ ឬយ៉ាងណា ។ អត្ថន័យនៃសារទូរលេខនោះ គឺទាក់ទងនឹងការផ្លាស់ប្តូរលំនៅស្ថាន និងការបំបែកជនជាតិចាម ការរៀបចំបញ្ចូលស្រុកសៀមរាប និងស្រុកបន្ទាយស្រី ស្ថានភាពខ្លាំងនៅតាមព្រំដែនឡាវ និងវៀតណាម ។ ទាក់ទងនឹងការសម្អាតខ្មាំង ចៅក្រម ឡាវ៉ើញ បានស្នើឲ្យសាក្សីធ្វើការពន្យល់អំពីពាក្យមួយចំនួនដូចជា "សម្រិតសម្រាំង" "បោសសម្អាត" និង "កម្ទេច" ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា ពាក្យថា "***សម្រិតសម្រាំង***" គឺសំដៅលើការជ្រើសរើសដោយប្រយ័ត្នប្រយែង ឲ្យច្បាស់លាស់ ដោយត្រូវពិនិត្យទាំងប្រវត្តិរូប និងសីលធម៌រស់នៅមុនពេលទទួលឲ្យដឹកនាំការងារអ្វីមួយ និងពិនិត្យការងារជាបន្តបន្ទាប់ដើម្បីកសាងជាគណៈកម្មការ ឬទទួលខុសត្រូវអង្គភាពណាមួយ ។ ពាក្យ "***បោសសម្អាត***" គឺសំដៅលើការដកចេញនូវសមាសភាពមិនល្អចេញពីរបប ។ ចំណែកឯពាក្យថា "***កម្ទេច***" គឺសំដៅលើសម្ភារៈ និងសំដៅលើមនុស្ស ។ បើកម្ទេចសម្ភារៈ គឺធ្វើឲ្យសម្ភារៈនោះប្រើប្រាស់លែងកើត ឬគាំង ហើយបើសំដៅលើមនុស្សមានន័យថា "សម្លាប់" ។

## ៥) ការសួរដេញដោលសាក្សីដោយមេធាវីការពារក្តីទាំងបីក្រុម

បន្ទាប់ពីបញ្ចប់ការសួរដេញដោលសាក្សី នង សុផង់ ដោយចៅក្រម ឡាវ៉ើញ លោកប្រធានបានប្រគល់វេទិកាជូនក្រុមមេធាវីការពារក្តីដើម្បីសាកសួរបន្តតាមលំដាប់ គឺក្រុមមេធាវីការពារក្តី ខៀវ សំផន ក្រុមមេធាវីការពារក្តី នួន ជា និងក្រុមមេធាវីការពារក្តី អៀង សារី ។ ដោយសារតែការផ្តល់សក្ខីកម្មរបស់ សាក្សី នង សុផង់ បានលើកឡើងភាគច្រើនទាក់ទងនឹងជនជាប់ចោទ ខៀវ សំផន អង្គជំនុំជម្រះបានសម្រេចប្រគល់វេទិកាសួរដេញដោលសាក្សីជូនក្រុមមេធាវីការពារក្តី ខៀវ សំផន មុនក្រុមមេធាវីការពារក្តីជនជាប់ចោទផ្សេងទៀត ។

### ៥.ក) ក្រុមមេធាវីការពារក្តី ខៀវ សំផន

មេធាវីជាតិការពារក្តីជនជាប់ចោទ ខៀវ សំផន គឺលោក គង់ សំអុន បានចាប់ផ្តើមសួរ ដោយស្នើឲ្យសាក្សីធ្វើការបញ្ជាក់អំពីការងារនៅក្នុងមន្ទីរបកប្រែលេខកូដសម្ងាត់ ។ ទាក់ទងនឹងបញ្ហានេះ សាក្សី នង សុផង់ បានរៀបរាប់ដូចអ្វីដែលខ្លួនបានបញ្ជាក់នៅចំពោះមុខតំណាងសហព្រះរាជអាជ្ញាថា មន្ទីរដែលខ្លួនធ្វើការ គឺមានទីតាំងនៅក្នុងវិទ្យាល័យសុធារស ។ សាក្សីបានបន្តទៀតថា នៅទីនោះខ្លួនមានតួនាទីជាអ្នកបកប្រែ បណ្តុះបណ្តាលសិស្ស ត្រួតពិនិត្យអក្ខរាវិរុទ្ធ និងឃ្លោងឃ្លាមុនពេលសារត្រូវបានផ្ញើចេញ ។ មុនពេលបញ្ចប់ការសាកសួរឲ្យរបស់ខ្លួន មេធាវី គង់ សំអុន បានស្នើឲ្យសាក្សីពន្យល់ឡើងវិញនូវចម្លើយរបស់ខ្លួនចំពោះមុខតំណាងសហព្រះរាជអាជ្ញាទាក់ទងនឹងការបញ្ជូនឯកសារចេញបន្ទាប់ពីមានការបកប្រែរួច និងការប្រើប្រាស់ពាក្យក្នុងការកំណត់គណៈមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ។ ឆ្លើយតបនឹងសំណើនេះ សាក្សីបានរៀបរាប់ដូចអ្វីដែលខ្លួនធ្លាប់បានឆ្លើយតបចំពោះសំណួររបស់សហព្រះរាជអាជ្ញា ។

បន្ទាប់មក មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ ខៀវ សំផន គឺមេធាវី អាកទូរ វែកគែន ដែលមានសញ្ជាតិបារាំងត្រូវបានអង្គជំនុំជម្រះប្រគល់វេទិកាជូន ដើម្បីបន្តសួរបន្ទាប់ពីសហមេធាវីជាតិរបស់ខ្លួន ។ មេធាវី វែកគែន ចាប់ផ្តើមសំណួរដំបូងរបស់ខ្លួនដោយផ្តោតលើក្រសួងការបរទេស ថាតើនៅក្រសួងការបរទេសមានមន្ទីរបកប្រែដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា ខ្លួនមិនដឹងថានៅក្រសួងការបរទេសមានមន្ទីរបកប្រែ ឬមិនមាននោះទេ ប៉ុន្តែនៅក្រសួងការពារជាតិពិតជាមានអ្នកបកប្រែ អ្នកវាយអង្គលីលេខ និងមានប្រព័ន្ធទូរស័ព្ទគ្រប់ប្រភេទ ។ បន្ទាប់មកមេធាវីបានបន្តសួរទាក់ទងនឹងពាក្យថា "ចម្លងជូន" ដើម្បីឲ្យសាក្សីបញ្ជាក់ ។ សាក្សីបានបញ្ជាក់ថា ក្នុងករណីអ៊ីៗមិននៅដោយសារជាប់បំពេញភារកិច្ចនៅក្រៅប្រទេស ការផ្ញើសារទូរលេខទៅតំបន់ផ្សេងៗមិនចាំបាច់ចម្លងជូនទៅឈ្មោះអ៊ីៗទាំងនោះឡើយ ។ មុនពេលបញ្ចប់ការសាកសួររបស់ខ្លួន មេធាវីអន្តរជាតិ អាកទូរ វែកគែន បានសង្កត់ធ្ងន់លើកំណត់

ហេតុស្តាប់ចម្លើយរបស់សាក្សីដែលឆ្លើយឡើងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ដោយមេធាវីបានស្នើឲ្យសាក្សីរំឭកឡើងវិញនូវចម្លើយរបស់ខ្លួនកាលពីមុន ប៉ុន្តែសំណើនេះមិនត្រូវបានសាក្សីផ្តល់ចម្លើយជាក់លាក់ទេ ដោយសារសាក្សីមិនអាចចាំនូវអ្វីដែលខ្លួនបាននិយាយកាលពីមុន ។

### ៩.១) ក្រុមមេធាវីការពារក្តី នួន ជា

មេធាវីជាតិការពារក្តីជនជាប់ចោទ នួន ជា គឺលោក សុន អរុណ បានចាប់ផ្តើមសំណួររបស់ខ្លួន ដោយចោទសួរអំពីស្ថានភាពសុខភាពរបស់សាក្សីក្នុងការចូលរួមក្នុងកិច្ចដំណើរការសវនាការ ។ បន្ទាប់មក មេធាវី អរុណ បានបន្តសួរទាក់ទងនឹងការចូលធ្វើបដិវត្តន៍របស់សាក្សី ។ សាក្សី នង សុផង់ បានបញ្ជាក់ថា ខ្លួនបានចូលធ្វើបដិវត្តន៍នៅក្នុងឆ្នាំ១៩៧៣ ហើយនៅពេលនោះលោកបានធ្វើការពីរកន្លែងផ្សេងគ្នា គឺនៅកន្លែងដែលខ្លួនរៀន និងធ្វើការនៅក្នុងព្រៃរហូតដល់ឆ្នាំ១៩៧៤ ទើបខ្លួនបានមកធ្វើការនៅបរិវេណនៃមន្ទីរ ប-២០ ។ បន្ទាប់មកមេធាវី អរុណ បានសួរទាក់ទងនឹងសារដែលផ្ញើជូន ប៉ុល ពត និង នួន ជា ។ សាក្សីបានបញ្ជាក់ថា នៅពេលនោះសារភាគច្រើនត្រូវផ្ញើជូនបង ប៉ុល ដែលពាក់ព័ន្ធនឹងការងារគ្រប់ផ្នែក ។ ចំណែកឯសារដែលផ្ញើជូនបង នួន គឺ ជាសារដែលពាក់ព័ន្ធនឹងថ្នាក់មូលដ្ឋាន ។ ពាក់ព័ន្ធនឹងការសរសេរពាក្យ "ជូន" និង "ចម្លងជូន" នៅផ្នែកខាងក្រោមនៃសារទូរលេខ សាក្សីបានពន្យល់ថា "ជូន" គឺជាការសរសេរជូនពរ ហើយអាស្រ័យលើអ្នកផ្ញើតែប៉ុណ្ណោះ ដែលខុសគ្នាពីពាក្យថា "ចម្លងជូន" ដែលជាទម្រង់នៃសារ និងត្រូវតែដាក់ជាដាច់ខាត ។ ឆ្លើយតបនឹងសំណួរបន្ទាប់របស់មេធាវី អរុណ អំពីអត្តចរិតរបស់ជនជាប់ចោទ នួន ជា សាក្សីបានបញ្ជាក់ថា លោកធ្លាប់ឃើញ នួន ជា នៅកន្លែងដែលលោកធ្វើការ និងបានកត់សម្គាល់ឃើញថា នួន ជា ក៏ដូចជាមេដឹកនាំផ្សេងទៀតសុទ្ធតែមានចរិតចាស់ទុំគួរជាទីគោរព និងជាអ្នកចេះដឹងទៀតផង ។ បន្ទាប់មក មេធាវីបានលើកយកសំណួរដែលសួរដេញដោលដោយតំណាងសហព្រះរាជអាជ្ញាទាក់ទងនឹងតារាងដែលសាក្សីបានគូរអំពីរចនាសម្ព័ន្ធ និងការធ្វើទំនាក់ទំនងរបស់មន្ទីរ៨៧០ ស្នើឲ្យសាក្សីធ្វើការពន្យល់ឡើងវិញ ។ សាក្សីបានធ្វើការពន្យល់ឡើងវិញយ៉ាងលំអិត និងបានធ្វើការកត់សម្គាល់ថា ជាសរុបមកស្ថាប័នកំពូលនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានចំនួន៤ គឺគណៈ៨៧០ គណៈប្រធានរដ្ឋ សភាតំណាងប្រជាជន និងតុលាការ ។

បន្ទាប់ពីបញ្ចប់ការសាកសួររបស់មេធាវីជាតិ សុន អរុណ មេធាវីអន្តរជាតិ គឺ អេនខ្រូ អ៊ីទូហ្ស៊ី បានបន្តការសួរសំណួរទាក់ទងនឹងការបញ្ជូនសារទូរលេខពីមន្ទីរបកប្រែលេខកូដសម្ងាត់ទៅឲ្យ ប៉ុន ដោយស្នើឲ្យសាក្សីធ្វើការបញ្ជាក់ជាថ្មីឡើងវិញ ។



មេធាវីការពារក្តី អេនខ្រូ អ៊ីទូហ្ស៊ី

បន្ទាប់មកមេធាវី អ៊ីទូហ្ស៊ី បានបន្តដោយលើកយកចម្លើយរបស់សាក្សីដែលថា ចៅក្រមស៊ើបអង្កេតបានសាកសួរខ្លួនជាច្រើនដងនូវចំណុចណាដែលខ្លួនមិនដឹងច្បាស់ ។ ប៉ុន្តែសំណួរនេះត្រូវបានតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ថារីក ជំទាស់ដោយអះអាងថា បញ្ហានេះសាក្សីបានបញ្ជាក់រួចជាច្រើនដងហើយ ។ ភ្លាមៗនោះមេធាវីការពារក្តី អៀង សារី គឺលោក ម៉ៃឃើល កាណាវ៉ាស បានគាំទ្រចំពោះការសាកសួរដោយមេធាវី អ៊ីទូហ្ស៊ី ដោយអះអាង ថាច្ចេកទេសនៃការចោទសួររបស់សហចៅក្រមស៊ើបអង្កេតចំពោះសាក្សីដោយការបង្ហាញឯកសារ និងព្យាយាមសួរឲ្យសាក្សីរំឭកពីការចងចាំ អាចធ្វើឲ្យមេធាវីការពារក្តីមិនមានទំនុកចិត្តចំពោះចម្លើយរបស់សាក្សី ។ ដើម្បីដោះស្រាយនូវបញ្ហានេះ ប្រធានអង្គជំនុំជម្រះ ចៅក្រម និល ណុន បានរំឭកពីករណីកិច្ចរបស់សាក្សីដែលត្រូវផ្តល់ចម្លើយដែលខ្លួនបានដឹងបានឃើញ

ដោយមិនត្រូវឆ្លើយដោយស្មានៗនោះទេ។ ប៉ុន្តែអង្គជំនុំជម្រះក៏បានបង្គាប់ឲ្យក្រុមមេធាវីលើកយកបញ្ហានេះមកពិភាក្សា ដោយធ្វើឡើងជាលាយលក្ខណ៍អក្សរ ដើម្បីឲ្យអង្គជំនុំជម្រះធ្វើការសម្រេចលើបញ្ហានេះ។ ជាថ្មីម្តងទៀត មេធាវីបានបន្តសំណួរដោយស្នើសាក្សីបញ្ជាក់ជាថ្មី លើចម្លើយរបស់ខ្លួនទាក់ទងនឹងការសាកសួររបស់ចៅក្រមស៊ើបអង្កេត។ ចៅក្រម ហ្សង់ម៉ាក ឡាវើញ បានរំឭកសារជាថ្មីដល់មេធាវី អ៊ីនូហ្ស៊ី ចំពោះសំណួរបែបនេះ ដោយបង្គាប់ឲ្យមេធាវីសួរសំណួរបើកចំហឲ្យសាក្សីឆ្លើយ។ បន្ថែមពីលើនេះ លោកចៅក្រម និល ណុន បានរំឭកដល់មេធាវី អ៊ីនូហ្ស៊ី ឲ្យពិនិត្យមើលវិធាន៣៦(៧) និងវិធាន៧៦(៧) ឡើងវិញ ទាក់ទងនឹងការជំទាស់របស់ខ្លួន។ ទោះបីជាមានការសម្រេចរបស់ចៅក្រម និល ណុន ទាក់ទងនឹងការមិនអនុញ្ញាតឲ្យខ្លួនលើកយកបញ្ហានីតិវិធីនៃកាស៊ើបអង្កេតរបស់សហចៅម្រស៊ើបអង្កតក៏ដោយ មេធាវី អ៊ីនូហ្ស៊ី នៅតែបន្តលើកឡើងនូវបញ្ហានេះមកពិភាក្សានៅចំពោះមុខអង្គជំនុំជម្រះម្តងហើយម្តងទៀត។ ប៉ុន្តែបញ្ហានេះត្រូវបាន ចៅក្រម និល ណុន ដោះស្រាយដោយបញ្ឈប់ឲ្យមានការសាកសួរសំណួរបែបនេះសារជាថ្មី។

បន្ទាប់មក មេធាវី អ៊ីនូហ្ស៊ី បានបន្តការសាកសួរដោយលើកយកនូវចម្លើយរបស់សាក្សីដែលបានឆ្លើយនៅចំពោះមុខភាគីផ្សេងទៀតដើម្បីឲ្យសាក្សីបញ្ជាក់។ ចំណុចដែលមេធាវីស្នើឲ្យសាក្សីបញ្ជាក់គឺពាក់ព័ន្ធនឹងតួនាទីរបស់ នួន ជា ការផ្ញើសារទូរលេខទៅឲ្យ នួន ជា ការចម្លងជូនសារទូរលេខដែលបានផ្ញើចេញ និងស្ថានភាពនៅថ្នាក់មូលដ្ឋាន។

### ៥.គ) ក្រុមមេធាវីការពារក្តី អៀង សារី

បន្ទាប់ពីបញ្ចប់ការសួរសាក្សី នង សុជង់ ដោយមេធាវីការពារក្តីនួនជា លោកប្រធានអង្គជំនុំជម្រះសាលាដំបូង និល ណុន បានផ្ទេរវេទិកាជូនមេធាវីការពារក្តី អៀង សារី ដើម្បីសួរសំណួរបន្ត។ មេធាវី ម៉ៃឃើល កាណាវ៉ាស បានបន្តការសួរដោយផ្តោតលើនីតិវិធីនៃការសួររបស់សហចៅក្រមស៊ើបអង្កេតដែលបានសួរសំណួរសាក្សីមុនពេលថតសំឡេង។ ប៉ុន្តែករណីនេះសាក្សីបានបញ្ជាក់ថា ខ្លួនត្រូវបានសួរសំណួរស្របពេលកំពុងថតសំឡេងដែរ។ ពាក់ព័ន្ធនឹងបញ្ហានេះ ចៅក្រម និល ណុន បានរំឭកដល់មេធាវីមិនឲ្យសាកសួរសំណួរបែបនេះទេ ដោយបង្គាប់ឲ្យមេធាវីដាក់ពាក្យបណ្តឹងជាលាយលក្ខណ៍អក្សរក្នុងករណីខ្លួនមានបំណងប្តឹងមោឃភាពចំពោះកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបអង្កេត។ មេធាវីកាណាវ៉ាស បានឆ្លើយតបនឹងការរំឭកនេះថា ខ្លួនមិនមានបំណងប្តឹងមោឃភាពកិច្ចដំណើរការនីតិវិធីនេះទេ ប៉ុន្តែខ្លួនគ្រាន់តែចង់ទាញការចាប់អារម្មណ៍ចំពោះខ្សែអាត់សំឡេងតែប៉ុណ្ណោះ។ ដើម្បីបញ្ជាក់ឲ្យកាន់តែច្បាស់លើបញ្ហា ដែលលើកឡើងដដែលៗនេះ ចៅក្រម ហ្សង់ម៉ាក ឡាវើញ បានរំឭកអំពីបញ្ហាចំនួនពីរគឺ ទី១) ពាក់ព័ន្ធនឹងកិច្ចស៊ើបអង្កេតរបស់សហចៅក្រមស៊ើបអង្កេត ដោយលោកចៅក្រមបានបញ្ជាក់ថា នីតិវិធីនៃការស៊ើបអង្កេតនោះបានបញ្ចប់យូរឆ្នាំមកហើយ ហើយឯកសារទាំងអស់ត្រូវបានដាក់នៅក្នុងសំណុំរឿងដែលមេធាវីអាចធ្វើការពិនិត្យឡើងវិញបាន។ ទី២) ចំពោះខ្សែអាត់សំឡេងវិញ ចៅក្រម ឡាវើញ បានបញ្ជាក់ថា ដោយសារតែឯកសារបទសម្ភាសន៍នោះជាភាសាខ្មែរ មេធាវីអាចឲ្យសហភាគីរបស់ខ្លួនបកប្រែ និងពន្យល់ពីអ្វីដែលបានសាកសួរនៅក្នុងបទសម្ភាសន៍នោះ។ លើសពីនេះ ចៅក្រម ឡាវើញ បានចោទជាសំណួរចំពោះមេធាវី កាណាវ៉ាស ថាតើក្នុងអំឡុងពេលប៉ុន្មានឆ្នាំនៃកិច្ចស៊ើបសួរកន្លងទៅនោះមេធាវីកំពុងធ្វើអ្វីខ្លះ? ឆ្លើយតបនឹងការលើកឡើងរបស់ចៅក្រម ឡាវើញ មេធាវី កាណាវ៉ាស បានបញ្ជាក់ថា មូលហេតុដែលខ្លួន លើកយកខ្សែអាត់នោះមកពិភាក្សា គឺដោយសារតែនៅក្នុងខ្សែអាត់នោះអាចឲ្យខ្លួនយល់បានថា ការធ្វើបទសម្ភាសន៍ជាមួយសាក្សី គឺធ្វើឡើងមុនពេលថតសម្លេងមួយថ្ងៃ។ ដូច្នេះ ខ្លួនមានបំណងចង់ឲ្យអង្គជំនុំជម្រះ ធ្វើការថ្លឹងថ្លែងលើបញ្ហានេះ។ ជាការឆ្លើយតប តំណាងសហព្រះរាជអាជ្ញា ថារីក បានលើកឡើងថា មេធាវីមិនគួរលើកយកបញ្ហានេះមកពិភាក្សានៅក្នុងសវនាការទេ ដោយហេតុថា មេធាវីខកខានមិនធ្វើការជំទាស់នៅក្នុងដំណាក់កាលស៊ើបអង្កេត។

ដើម្បីដោះស្រាយនូវបញ្ហានេះ លោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយត៍ បានបញ្ជាក់ពីរចំណុចគឺ ទី១) ដោយសារតែអ្នកដែលអនុវត្តច្បាប់នៅតុលាការនេះ មកពីប្រទេសដែលអនុវត្តប្រព័ន្ធច្បាប់ផ្សេងគ្នា ដូច្នេះនាំឲ្យមានការយល់ឃើញខុសគ្នា។ ប៉ុន្តែ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានអនុវត្តតាមវិធានមួយដែលថា ក្នុងករណីមានកំហុសពាក់ព័ន្ធនឹងការស៊ើបអង្កេត ភាគីត្រូវតែធ្វើការលើកឡើងនៅក្នុងអំឡុងពេលនៃការស៊ើបអង្កេតតែម្តង ។ ជាងនេះទៅទៀត ការជំទាស់នោះត្រូវតែពាក់ព័ន្ធ



ចៅក្រម ស៊ីលវៀ ខាតវ្រ៉ាយត៍

នឹងខ្លឹមសារ មិនមែនពាក់ព័ន្ធតែលើបញ្ហាបច្ចេកទេសនោះទេ ។ ទី២) រាល់ការបញ្ជាក់ឡើងវិញអំពីភាពពិតប្រាកដនៅក្នុងដំណាក់កាលស៊ើបអង្កេត គឺភាគីអាចសាកសួរសាក្សីនៅចំពោះមុខអង្គជំនុំជម្រះតែប៉ុណ្ណោះ ។

បន្ទាប់មកមេធាវី កាណាវ៉ាស បានបន្តសំណួររបស់ខ្លួនដោយការសួរបញ្ជាក់នូវចម្លើយរបស់សាក្សីទាក់ទងនឹងតួនាទីរបស់ អៀង សារី ការងារនៅមន្ទីរបកប្រែ ការងារបង្រៀនរបស់សាក្សី ការបញ្ជូនសាទូរលេខ ទីតាំងមន្ទីរបកប្រែមុនឆ្នាំ ១៩៧៥ និងគោលការណ៍សម្ងាត់នៃមន្ទីរនីមួយៗដើម្បីឲ្យសាក្សីបញ្ជាក់ឲ្យបានច្បាស់ចំពោះចំណុចដែលខ្លួនបានលើកឡើង ។ ដោយសារតែមានការភាន់ច្រឡំអំពីឈ្មោះកម្មាភិបាល ដែលមានតួនាទីនៅក្នុងមន្ទីរបកប្រែដូចជា ប៉ាំង, ប៊ុន និង ផង់ មេធាវីកាណាវ៉ាស បានចោទសួរសាក្សីជាច្រើនដងដែលជាហេតុនាំឲ្យមានអន្តរាគមន៍ពីសំណាក់ប្រធានអង្គជំនុំជម្រះ ដោយបង្គាប់ឲ្យសាក្សីឆ្លើយតបចំពោះចំណុចនេះ ។ សាក្សីបានបញ្ជាក់ថា ប៉ាំងមានតួនាទីទទួលខុសត្រូវលើកិច្ចការទាំងអស់នៅមន្ទីរស-៧១ ដែលមានមន្ទីរកជាច្រើននៅក្រោមបង្គាប់ ។ ចំណែកឯ ប៊ុន មានតួនាទីគ្រប់គ្រងនៅមន្ទីរក-១ ។ រីឯ ផង់ (សាក្សី) មានតួនាទីទទួលខុសត្រូវនៅមន្ទីរដែលមានទីតាំងនៅវិទ្យាល័យសុធារស ។ បន្ទាប់មក មេធាវី កាណាវ៉ាស បានសួរថា តើរាល់សារទូរលេខទាំងអស់ដែលត្រូវចម្លងជូន ប៉ុល ពត នោះដោយសារតែ ប៉ុល ពត ជាអ្នកទទួលខុសត្រូវលើគ្រប់ការងារទាំងអស់ឬយ៉ាងណា? ឆ្លើយតបនឹងសំណួរនេះ សាក្សីបានពន្យល់រៀបរាប់ថា រាល់សារទាំងអស់ត្រូវចម្លងជូន ប៉ុល ពត ដោយសារ ប៉ុល ពត ត្រូវដឹងពីគ្រប់កិច្ចការទាំងអស់ ប៉ុន្តែខ្លួនមិនដឹងថាសិទ្ធិអំណាចរបស់ ប៉ុល ពត មានកម្រិតណាទេ ។

មេធាវី កាណាវ៉ាស បានបន្តសួរឲ្យសាក្សីបញ្ជាក់ពីភាពខុសគ្នារវាងគណៈមជ្ឈិម គណៈអចិន្ត្រៃយ៍ និងគណៈ៨៧០ ។ សាក្សី នង សុផង់ បានបញ្ជាក់ថា ខ្លួនមានការយល់ច្រឡំរវាងគណៈមជ្ឈិម និងគណៈអចិន្ត្រៃយ៍ ព្រមទាំងពាក្យ "គណៈ" និង "អង្គការ" ប៉ុន្តែខ្លួនដឹងថា៨៧០ គឺសំដៅលើគណៈមជ្ឈិម ។ មេធាវី កាណាវ៉ាស បានបន្តសួរសាក្សីថា តើ៨៧០នោះសំដៅលើ ប៉ុល ពត ឬ? ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា ខ្លួនមិនធ្លាប់ឮនរណាហៅ ប៉ុល ពត ថា ៨៧០ នោះទេ ដោយសារតែ៨៧០ សំដៅលើមន្ទីរ ។ ចំណែកឯ ប៉ុល ពត ត្រូវបានហៅថា បងទី១ ឬ បងប៉ុល ។ មុនពេលបញ្ចប់ មេធាវី កាណាវ៉ាស បានសួរថាតើសាក្សីមានការប្រុងប្រយ័ត្នក្នុងការទទួលយកចម្លើយរបស់ខ្លួន ឬយ៉ាងណា? ពាក់ព័ន្ធនឹងសំណួរនេះ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ អាប់ឌុលហាក់ ថារីក បានជំទាស់ដោយអះអាងថា មេធាវីមិនអាចសួរសំណួរដែលឲ្យសាក្សីបង្គាប់អង្គជំនុំជម្រះក្នុងការវិភាគទៅលើភស្តុតាងបានទេ ។ ឆ្លើយតបនឹងការលើកឡើងទាំងនេះ ចៅក្រម ស៊ីលវៀ ខាតវ្រ៉ាយត៍ បានគាំទ្រនូវសេចក្តីជំទាស់របស់តំណាងសហព្រះរាជអាជ្ញា ដោយបញ្ជាក់ថា ការវិភាគលើភស្តុតាងទាក់ទងនឹងចម្លើយរបស់សាក្សី គឺជាសមត្ថកិច្ចរបស់អង្គជំនុំជម្រះតែប៉ុណ្ណោះ ។

**សូមបញ្ជាក់ថា** សវនាការសួរដេញដោលសាក្សី នង សុផង់ បានបញ្ចប់នៅថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១២ ។

# សវនាការសួរដេញដោលសាក្សី ជា សាយ

## ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១២

### ១) ប្រវត្តិសាវតាររបស់សាក្សី ជា សាយ

សាក្សី ជា សាយ អាយុ ៥៩ឆ្នាំ សព្វថ្ងៃរស់នៅភូមិខ្ទង់ សង្កាត់អូរតាវ៉ៅ ក្រុងប៉ៃលិន ខេត្តប៉ៃលិន ។ ឪពុកឈ្មោះ កើត ជា ម្តាយឈ្មោះ ជា ដេង និងប្រពន្ធឈ្មោះ សៅ សារុន ។ លោកមានកូនចំនួន ៤នាក់ ប្រុស២ និងស្រី២ ។ មុខរបរសព្វថ្ងៃ គឺជាកសិករធ្វើស្រែចម្ការ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ជា សាយ គឺជាជាងជួសជុលរថយន្តនៅមន្ទីរក-១២ ដែលជាផ្នែកមួយនៃមន្ទីរ៨៧០ ។ ក្រៅពីនេះ ជា សាយ គឺជាអ្នកដឹកជញ្ជូនកងទ័ព និងបុគ្គលិកពេទ្យនៅទីក្រុងភ្នំពេញ ។

### ២) សក្ខីកម្មរបស់ ជា សាយ ក្នុងអំឡុងពេលសួរដេញដោល

ឆ្លើយតបនឹងសំណួររបស់លោកតំណាងសហព្រះរាជ អាជ្ញា វ៉េង ហ៊ិត សាក្សី ជា សាយ បញ្ជាក់ថា មន្ទីរក-១២ ត្រូវបានដឹកនាំដោយ តាមៀល និង វ៉ុយ ជាអនុប្រធាន ។ មន្ទីរនេះត្រូវបានបែងចែកជាពីរផ្នែក គឺផ្នែកជួសជុលរថយន្ត និងផ្នែកដឹកជញ្ជូនសម្ភារៈនិងភ្ញៀវ ។ ក្នុងផ្នែកជួសជុលរថយន្តមានគ្នា ប្រមាណ ៣០នាក់ ប៉ុន្តែបុគ្គលិកទាំងនោះមួយចំនួនធំត្រូវបានដកយកទៅធ្វើផ្លូវរទេះភ្លើង និងបង្កបង្កើនផល ។ ចំណែកផ្នែកដឹកជញ្ជូន គឺមានភារៈកិច្ចដឹកភ្ញៀវបរទេស ដែលចេញចូលស្រុកខ្មែរ ។ ផ្នែកនេះត្រូវបានបែងចែកជាពីរទៀត គឺផ្នែកឡានតូច (សម្រាប់ដឹកកម្មាភិបាល និងភ្ញៀវបរទេស) និងផ្នែកឡានធំ (សម្រាប់ដឹកសម្ភារៈទៅឲ្យភូមិភាគ តំបន់ ឬសហករណ៍) ។

ពាក់ព័ន្ធនឹងការចូលរួមវគ្គបណ្តុះបណ្តាលនយោបាយ ជា សាយ បញ្ជាក់ថា លោកធ្លាប់បានចូលរួមជាច្រើនដងនៅវិទ្យាស្ថានបច្ចេកវិទ្យា និងនៅបុរីកីឡា ។ វគ្គទាំងនេះអប់រំអំពីការខិតខំប្រឹងប្រែងធ្វើការងារឲ្យបានល្អ ការបោះសន្ទុំសំចៃ របៀបរស់នៅក្នុងអង្គភាពនីមួយៗការកសាងប្រទេសជាតិ ។ល ។ វគ្គនីមួយៗ មានរយៈពេលយ៉ាងតិច៣ថ្ងៃ ។ ជា សាយ បញ្ជាក់ថា វគ្គនយោបាយត្រូវបានធ្វើឧទ្ទេសនាមដោយ នួន ជា និង ខៀវ សំផន ហើយអ្នកទាំងពីររូបនេះ គឺធ្វើសន្ទរកថាស្រដៀងៗគ្នា ពោលដូចជាមនុស្សតែម្នាក់ ។ បន្ថែមលើនេះ លោកធ្លាប់បានឮ ខៀវ សំផន និយាយតាមវិទ្យុជាច្រើនដងអំពីការជម្រុញឲ្យខិតខំធ្វើការងារ ។

សាក្សី ជា សាយ បញ្ជាក់បន្ថែមថា នៅក្នុងអង្គភាពរបស់លោក គឺប្រធានអង្គភាពបានណែនាំឲ្យបុគ្គលិកទាំងអស់ត្រូវមានការប្រុងប្រយ័ត្នខ្ពស់ ហើយត្រូវតាមដានគ្នាទៅវិញទៅមក និងរាយការណ៍ទៅថ្នាក់លើ ។ លោកបានបន្ថែមថា បក្សបានចាត់វិធានការការពារការជ្រៀតចូលរបស់ខ្មាំងជាមុន ហើយក្នុងករណី


សាក្សី ជា សាយ

មានខ្មាំងនោះនឹងត្រូវចាប់ខ្លួនភ្លាម ។ ទោះបីជាយ៉ាងណាក៏ដោយ សាក្សីមិនបានបញ្ជាក់ថា ខ្មាំងទាំងនោះ នឹងត្រូវបានបក្សយកទៅសម្លាប់ចោល ឬយកទៅធ្វើអ្វីឡើយ ។

ឆ្លើយតបនឹងសំណួររបស់លោកស្រី បេនី យេ ជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ សាក្សី បញ្ជាក់ថា បន្ទាប់ពីចូលកាន់កាប់ទីក្រុងភ្នំពេញ ការជម្លៀសប្រជាជនចេញពីទីក្រុង គឺជាទិសដៅ

របស់របបកម្ពុជាប្រជាធិបតេយ្យ ។ នៅពេលនោះរូបលោក គឺជាយោធាម្នាក់ ហើយបានទទួលបញ្ជាឲ្យអមដំណើរប្រជាជនដែលត្រូវបានជម្លៀសទាំងនោះ ។ ទោះបីជាយ៉ាងណា សាក្សីមិនចាំឈ្មោះបុគ្គលដែលបញ្ជានោះឡើយ ។ សាក្សីបញ្ជាក់បន្ថែមថា ប្រជាជនជាច្រើនត្រូវបានដឹកតាម កាណូត ដែលកាណូតនីមួយៗមានគ្នាពី៥០ ទៅ១០០នាក់ ហើយមានយោធាខ្មែរក្រហម៥នាក់នៅការពារ ។ ប្រជាជនទាំងនោះត្រូវបានដឹកទៅដល់ព្រែកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ ពេលទៅដល់អាជ្ញាធរនៅតាមមូលដ្ឋានបានមកទទួលយក តែលោកមិនដឹងថា គេយកទៅទីណាឡើយ ។

ចំពោះការប្រជុំទិតៀន និងស្វ័យទិតៀន សាក្សី ជា សាយ បញ្ជាក់ថា នៅក្នុងអង្គភាពរបស់លោក មានការប្រជុំជាញឹកញាប់ ពោលគឺស្ទើររាល់ថ្ងៃ ។ បុគ្គលណាម្នាក់ដែលធ្វើការងារមិនបានល្អ នោះនឹងត្រូវទទួលការទិតៀននៅក្នុងអង្គប្រជុំ ។ ជាទូទៅបុគ្គលិកនៅអង្គភាពរបស់លោក គឺត្រូវបានតម្រូវឲ្យធ្វើការពី៧ ទៅ១១ម៉ោងក្នុងមួយថ្ងៃ ។

បន្ទាប់ពីក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីបញ្ចប់សំណួររបស់ខ្លួន លោកចៅក្រម ហ្សង់ម៉ាក ឡាវែរ៉ញ បានចោទសំណួរមួយចំនួនទាក់ទងការបាត់ខ្លួនបុគ្គលិកនៅមន្ទីរក-១២ ។ ឆ្លើយតបនឹងសំណួររបស់ចៅក្រម សាក្សីបញ្ជាក់ថា បុគ្គលិកដែលត្រូវបាននាំខ្លួនទៅ គឺគ្មានបុគ្គលណាម្នាក់វិលត្រឡប់មកវិញឡើយ ។ ដោយមើលឃើញសភាពការណ៍បែបនេះ លោកមានការភ័យខ្លាចជាខ្លាំងអំពីសុវត្ថិភាពផ្ទាល់ខ្លួនរបស់លោក ទោះបីលោកមិនបានធ្វើខុសក៏ដោយ ដំនួសមកវិញ គឺមានតែខិតខំធ្វើការឲ្យបានល្អ ។

គួរបញ្ជាក់ថា ក្នុងការសួរដេញដោលសាក្សី ក្រុមមេធាវីការពារក្តីទាំងបីក្រុមមានសំណួរតិចតួចណាស់ក្នុងការសួរសាក្សី ។ ក្រុមមេធាវីរបស់ជនជាប់ចោទ នួន ជា គឺបានផ្តោតជាសំខាន់ទៅលើបុគ្គលពីររូប គឺ តាម៉ុត និង តាស៊ុម ។ ទោះបីជាយ៉ាងណាក៏ដោយ សាក្សីពុំបានបញ្ជាក់ឲ្យបានច្បាស់លាស់អំពីតួនាទីមុខតំណែង និងសូម្បីតែនាមត្រកូលរបស់បុគ្គលទាំងពីររូបនេះ ។ ពោលគឺលោកគ្រាន់តែដឹងថា អ្នកទាំងនោះ ធ្លាប់កាន់កងទ័ពនៅតំបន់២៧ និងឆ្លើយទាំងភាពមិនប្រាកដថា ស៊ឹម ត្រូវបានចាត់ឲ្យទៅគ្រប់គ្រងនៅកំពង់សោម ។

ចំពោះសំណួររបស់ក្រុមមេធាវីការពារក្តីជនជាប់ចោទ អៀង សារី គឺផ្តោតសំខាន់អំពីភាពត្រឹមត្រូវនៃកិច្ចសម្ភាសន៍ដែលសាក្សីផ្តល់ជូនអ្នកស៊ើបអង្កេត និងភាពត្រឹមត្រូវនៃការធ្វើកំណត់ហេតុដែលដកស្រង់ចេញពីខ្សែអាត់ថតសម្លេង ។ ជាងនេះទៅទៀត គឺពាក់ព័ន្ធនឹងចម្លើយរបស់សាក្សី ដែលមានការឆ្លើយបន្ថែមដោយប្រពន្ធរបស់ខ្លួនក្នុងអំឡុងពេលផ្តល់បទសម្ភាសន៍នោះ ។ ឆ្លើយតបនឹងបញ្ហាទាំងនេះ សាក្សីបានបំភ្លឺថា អ្នកស៊ើបអង្កេតបានទៅជួបលោក៣ទៅ៤ដង តែធ្វើការសម្ភាសន៍តែម្តងប៉ុណ្ណោះ ។ ក្នុងអំឡុងពេលផ្តល់បទសម្ភាសន៍នោះ ប្រពន្ធរបស់លោកបានជួយរំឭកបន្ថែមមួយចំនួន ។ ទោះបីជាយ៉ាងណា ការបន្ថែមនេះ គឺគ្រាន់តែជាអ្វីដែលលោកធ្លាប់បាននិយាយតែប៉ុណ្ណោះ ។ ពោលគឺប្រពន្ធរបស់លោកគ្រាន់តែជួយបញ្ជាក់ឲ្យបានច្បាស់តែប៉ុណ្ណោះ ។

រីឯក្រុមមេធាវីការពារក្តីជនជាប់ចោទ ខៀវ សំផន គឺលោក គង់ សំអុន ចោទសំណួរមួយចំនួនពាក់ព័ន្ធនឹងការបើកវគ្គបណ្តុះបណ្តាលនយោបាយ ដែលខទ្ទេសនាមដោយជនជាប់ចោទ ខៀវ សំផន ។ សាក្សីបានបញ្ជាក់ថា ខៀវ សំផន បានបើកវគ្គបណ្តុះបណ្តាលម្តងម្កាលតែប៉ុណ្ណោះ ពោលគឺមានតែជនជាប់ នួន ជា ទេ ដែលបើកវគ្គបណ្តុះបណ្តាលនយោបាយជាញឹកញាប់ ។ សាក្សីស្គាល់ ខៀវ សំផន ជាលើកដំបូងនៅពេល ខៀវ សំផន ទៅលេងកូនរបស់ខ្លួន (កូនរបស់ ខៀវ សំផន) នៅមន្ទីរក-១២ ដែលពេលនោះ បុគ្គលិកទូទៅហៅថា «អ៊ំហែម» ។

ពាក់ព័ន្ធនឹងមន្ទីរ៨៧០ សាក្សី ជា សាយ បញ្ជាក់ថា មៀលដែលជាប្រធាននៃមន្ទីរក-១២ បានប្រាប់លោកថា មន្ទីរ៨៧០ គឺជាមន្ទីរមជ្ឈិម ដែលគ្រប់គ្រងពីលើមន្ទីរ និងភូមិភាគផ្សេងៗទៀត គឺជាកន្លែងរបស់មជ្ឈិម ។ ទោះបីជាយ៉ាងណាក៏ដោយ សាក្សីមិនអាចបញ្ជាក់ឲ្យបានច្បាស់ថា មន្ទីរនេះត្រូវបានដឹកនាំដោយមេដឹកនាំខ្មែរក្រហមរូបណាឡើយ គឺលោកគ្រាន់តែបញ្ជាក់ថា ដឹកនាំដោយ «អ៊ំៗ» តែប៉ុណ្ណោះ ។

បន្ទាប់ពីបញ្ចប់ការសួរដេញដោលសាក្សី ជា សាយ ប្រធាន

អង្គជំនុំជម្រះបានជូនដំណឹងដល់ភាគី និងសាធារណៈជនថា នៅថ្ងៃបន្ទាប់គឺទី២១ ខែកញ្ញា ឆ្នាំ២០១២ អង្គជំនុំជម្រះនឹងបើកសវនាការដាច់ដោយឡែកចំនួនពីរ ។ សវនាការទី១ គឺការស្តាប់សក្ខីកម្មរបស់វេជ្ជបណ្ឌិតពីររូបដែលទទួលបន្ទុកព្យាបាលជំងឺជនជាប់ចោទ អៀង សារី នៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ដើម្បីពិនិត្យថា តើ អៀង សារី អាចចេញពីមន្ទីរពេទ្យបាននៅពេលណា ហើយអាចចូលរួមកិច្ចដំណើរការនីតិវិធីរបស់តុលាការបានឬទេ ។ សវនាការទី២ គឺការពិភាក្សាអំពីការកំណត់កាលបរិច្ឆេទក្នុងការស្តាប់សក្ខីកម្មរបស់សាក្សីជំនាញ ហ៊ីលីព ស្សូត ដែលនឹងត្រូវធ្វើការផ្លាស់ប្តូរដោយសារបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង សារី ។



ទាហានខ្មែរក្រហមនៅអាកាសយានដ្ឋានពោធិ៍ចិនតុង (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

## ៣) បញ្ហាផ្សេងៗ

ក) មុនចូលដល់ការសួរដេញដោលសាក្សី លោកមេធាវី ម៉ៃឃើល ផេស្តមេន ស្នើសុំឲ្យប្រធាន អង្គជំនុំជម្រះធ្វើការបំភ្លឺអំពីមូលហេតុដែលប្រវត្តិរូបរបស់លោកប្រធានចៅក្រមមានការកែ

តម្រូវ ហើយព័ត៌មានមួយចំនួន ដែលអាចស្វែងរកអត្ថបទមួយចំនួន ដែលលោកចៅក្រមបានបោះផ្សាយ គឺត្រូវបានលុបចោល ។ ឆ្លើយតបនឹងសំណើនេះ ប្រធានអង្គជំនុំជម្រះគឺលោកចៅក្រម



និល ណុល បានបញ្ជាក់ថា លោកធ្លាប់បានសរសេរអត្ថបទខ្លីៗមួយចំនួនដូចជា វិធានការនៃការកំណត់បទល្មើស និងកំណត់ទោស ដែលលោកធ្លាប់បានធ្វើបទបង្ហាញពេលដែលធ្វើជាគ្រូបង្គោលនៅសាលាភូមិន្ទចៅក្រម ។ បន្ថែមលើនេះ លោកបានសរសេរអត្ថបទខ្លីមួយទៀត ពាក់ព័ន្ធនឹងវិធានគ្រប់គ្រងរដ្ឋបាលតុលាការកម្ពុជា ដែលជាបទពិសោធផ្ទាល់ខ្លួនរបស់លោក ។ លោកចៅក្រមបញ្ជាក់ថា ក្រុមមេធាវីការពារក្តីអាចស្វែងរកឯកសារទាំងនេះបាននៅសាលាភូមិន្ទចៅក្រម ហើយមូលហេតុដែលនាំឲ្យលោកសម្រេចលុបចោលព័ត៌មានទាំងនោះ គឺដោយសាររបៀបនៃការសរសេររបស់លោក គឺមានភាពខុសគ្នាឆ្ងាយបើធៀបនឹងកម្រិតអន្តរជាតិ ។ ទោះបីមានការបញ្ជាក់ដូច្នេះក្តី ប៉ុន្តែលោកមេធាវីនៅតែមិនអស់ចិត្ត ដោយលោកព្យាយាមក្រោកឈរម្តងហើយម្តងទៀត ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រធានអង្គជំនុំជម្រះមិនអនុញ្ញាតឲ្យមេធាវីបន្តលើកឡើងទៀតឡើយ ប៉ុន្តែទុកលទ្ធភាពឲ្យមេធាវីធ្វើសំណើជាលាយលក្ខអក្សរតាមនីតិវិធី ដើម្បីអាចឲ្យអង្គជំនុំជម្រះមានលទ្ធភាពឆ្លើយតបបាន ប្រសិនបើមេធាវីនៅតែមិនអស់ចិត្ត ។

២) ក្នុងការឆ្លើយតបសំណួររបស់ភាគី និងអង្គជំនុំជម្រះ សាក្សីលើកឡើងថា ខ្លួនមានការភ្លេចភ្លាំងច្រើន ដោយសារព្រឹត្តិការណ៍បានកន្លងហួសយូរមកហើយ ម្យ៉ាងវិញទៀតលោកក៏រៀនសូត្របានតិចតួច ។ ដូច្នេះសំណួរជាច្រើនដែលភាគីបានចោទសួរ គឺមិនបានទទួលចម្លើយឡើយ ដោយសាក្សីអះអាងថា ខ្លួនមិនចងចាំ ។

៣) ដូចគ្នានឹងសាក្សីមុនៗដែរ មុននឹងអនុញ្ញាតឲ្យភាគីចោទសួរ ប្រធានអង្គជំនុំជម្រះបានបញ្ជាក់ជូនសាក្សីអំពីសិទ្ធិមិនផ្តល់សក្ខីកម្មប្រឆាំងនឹងខ្លួនឯងដែលនាំឲ្យមានពិរុទ្ធភាព និងករណីកិច្ចរបស់សាក្សីក្នុងការឆ្លើយតបសំណួររបស់ភាគីផ្សេងៗនូវអ្វី ដែលខ្លួនបានដឹងបានឮ បានឃើញក្នុងរបបកម្ពុជាប្រជាធិបតេយ្យ លើកលែងតែការឆ្លើយសំណួរនោះអាចបណ្តាលឲ្យដាក់ពិរុទ្ធភាពមកលើខ្លួនឯង ។ ក្នុងអំឡុងពេលនោះដែរ លោក ពេជ អង្គ ជាសហមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំអង្គជំនុំជម្រះទទួលស្គាល់ លោកស្រីមេធាវី ហ្វ្រង់ស៊័រ ហ្គោលទ្រី ជនជាតិបារាំងដែលជាសមាជិករបស់ក្រុមមេធាវីគ្មានព្រំដែន ឲ្យមានសិទ្ធិការពារផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០២ ។ សំណើនេះត្រូវបានអង្គជំនុំជម្រះទទួលយកដោយអនុលោមតាមវិធានផ្ទៃក្នុងរបស់អង្គជម្រះ ។

# សវនាការសាកសួរសាក្សី នឹម សែម

## ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២

នៅថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានប្រកាសបន្តកិច្ចដំណើរការនីតិវិធីស្តាប់សក្ខីកម្មសាក្សី នឹម សែម ដែលជាអតីតអ្នកចម្រៀង និងអានព័ត៌មាននៅក្នុងក្រសួងឃោសនាការនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ សវនាការសួរដេញដោលសាក្សីរូបនេះ បានប្រព្រឹត្តទៅក្នុងរយៈពេលពេញមួយថ្ងៃ ដោយ



សាក្សី នឹម សែម

ផ្តោតសំខាន់លើតួនាទីរបស់សាក្សី មុន និងក្រោយឆ្នាំ១៩៧៥ ការចាប់ខ្លួនកម្មាភិបាល និងទីតាំងនៃមន្ទីរមួយចំនួន ។

សវនាសាកសួរសាក្សី នឹម សែម បានធ្វើឡើងបន្ទាប់ពីមានសវនាការដាច់ដោយឡែកមួយ នៅពីថ្ងៃទី២១ ខែកញ្ញា ដើម្បីពិភាក្សាលើបញ្ហាទាក់ទងនឹងបញ្ហាសុខភាពរបស់ជនជាប់ចោទ អៀង សារី និងពិភាក្សាអំពីការកំណត់ពេលសវនាការដើម្បីសាកសួរអ្នកជំនាញ ហ្វីលីព ហ្សត (Philip Short) ។ មុនពេលចាប់ផ្តើមសវនាការសួរដេញដោលសាក្សី នឹម សែម ប្រធានអង្គជំនុំជម្រះ គឺលោកចៅក្រម និល ណុន បានប្រកាសអំពីពាក្យស្នើសុំរបស់ជនជាប់ចោទ អៀង សារី ក្នុងការលះបង់សិទ្ធិមិនមានវត្តមាននៅក្នុងបន្ទប់សវនាការក្នុងអំឡុងពេលសាកសួរដេញដោលសាក្សីចំនួន៧រូប ។

### ១) ប្រវត្តិសាវតាររបស់សាក្សី

លោកចៅក្រម និល ណុន បានចាប់ផ្តើមដោយសាកសួរអំពីប្រវត្តិសាវតាររបស់សាក្សី ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានរៀបរាប់ថា ខ្លួនមានឈ្មោះ នឹម សែម កើតនៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ១៩៥៣ ។ សព្វថ្ងៃរស់នៅភូមិអូរអំពិល ឃុំពង្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ និងមានមុខរបរ ធ្វើស្រែចម្ការ ។ ឪពុកឈ្មោះ អ៊ឹម និងម្តាយឈ្មោះ ម៉ុក គិន ហើយមានស្វាមីឈ្មោះ ខាន់ លីន (សព្វថ្ងៃស្លាប់) និងមានកូន៥នាក់ ។ ចំពោះការអប់រំ សាក្សីបានបញ្ជាក់ថា ខ្លួនបានរៀនត្រឹមថ្នាក់ទីបី កាលពីសង្គមចាស់តែប៉ុណ្ណោះ ។ បន្ទាប់មកចៅក្រម និល ណុន បានណែនាំដល់សាក្សីអំពីសិទ្ធិ និងករណីកិច្ចមួយចំនួនរបស់សាក្សីនៅក្នុងដំណាក់កាលសាកសួរដេញដោល ។ បន្ទាប់មកចៅក្រម និល ណុន បានបន្តសាកសួរសាក្សី ទាក់ទងនឹងការផ្តល់បទសម្ភាសន៍ជាមួយសហចៅក្រមស៊ើបអង្កេត ។ សាក្សីបានបញ្ជាក់ថា ខ្លួនពិតជាបានផ្តល់បទសម្ភាសន៍ម្តងនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ហើយខ្លួនក៏បានអានបទសម្ភាសន៍នោះច្រើនដងមកហើយ ។

### ២) ការសួរដេញដោលសាក្សីដោយសហព្រះរាជអាជ្ញា

#### ២.ក) សហព្រះរាជអាជ្ញារងជាតិ

បន្ទាប់ពីបញ្ចប់ការសាកសួររបស់ចៅក្រម និល ណុន សហព្រះរាជអាជ្ញារង ចាន់ តារាស្មី បានសួរសាក្សីដោយផ្តោតសំខាន់លើបទពិសោធន៍ការងាររបស់សាក្សីមុនឆ្នាំ១៩៧៥ និងការងាររបស់ សាក្សីនៅក្នុងក្រសួងឃោសនាការ ។

#### ២.ក.១) បទពិសោធន៍ការងារមុនឆ្នាំ១៩៧៥

សហព្រះរាជអាជ្ញារង ចាន់ តារាស្មី បានចាប់ផ្តើមសួរសាក្សីអំពីមូលហេតុដែលនាំឲ្យសាក្សីចូលបម្រើបដិវត្តន៍ ។ ឆ្លើយតបនឹងសំណួរនេះសាក្សីបានបញ្ជាក់ថា ខ្លួនបានចូលបដិវត្តន៍

នៅឆ្នាំ១៩៦៣ ដោយសារពេលនោះ បងប្រុសរបស់ខ្លួនដែលបានចូលបដិវត្តន៍មុនផ្ញើសំបុត្រមកផ្ទះ ប៉ុន្តែសំបុត្រនោះ ត្រូវបានរដ្ឋការក្នុងរបប លន់ នល់ ចាប់បាន។ ដោយសារមានការភ័យខ្លាចខ្លួនបានចូលក្នុងព្រៃជាមួយបងស្រីម្នាក់ទៀត។ សាក្សីបានបន្តថា នៅពេលខ្លួនចូលបដិវត្តន៍ដំបូង ខ្លួនបានទៅរស់នៅ និងធ្វើការនៅភ្នំឳរ៉ាល់នៅផ្នែកពេទ្យរហូតដល់១៩៦៨ ទើបខ្លួនត្រូវបាន ហ៊ូ នឹម បញ្ចូលជាសមាជិកបក្ស ដោយសារខ្លួនមានវណ្ណៈជាកសិករ និងសួរទាក់ទងនឹងប្រធានសិល្បៈ ហើយសាក្សីបានបញ្ជាក់ថា ប្រធាននៅទីនោះឈ្មោះ ទ្រា ហៅ សៅ។ សាក្សីបានបញ្ជាក់ថា ពេលកំពុងធ្វើការនោះខ្លួនធ្លាប់បានឃើញ នួន ជា នៅកន្លែងបង្រៀននយោបាយ ប៉ុន្តែពេលនោះ ខ្លួនមិនបានដឹងពីតួនាទីរបស់ នួន ជា នោះទេ។ បន្ទាប់មក សហព្រះរាជអាជ្ញារងជាតិបានបន្តសួរសាក្សីអំពីការយល់ដឹងទាក់ទងនឹងទីកន្លែងរស់នៅរបស់ នួន ជា ចាប់ពីចន្លោះឆ្នាំ១៩៧៣រហូតដល់ឆ្នាំ១៩៧៤។ ឆ្លើយតបនឹង



រូបទី៣ រាប់ពីស្តាំ ៖ អៀង ធីរិទ្ធ ជួបជាមួយគណៈប្រតិភូបរទេស ពេលធ្វើទស្សនកិច្ចនៅប្រទេសជប៉ុន និងរូបខាងស្តាំបំផុត នឹម សែម អ្នកចម្រៀងនៅក្រសួងអប់រំ និងឃោសនាការនៃរបបកម្ពុជាប្រជាធិបតេយ្យ

ជាសមាជិកសម្ព័ន្ធយុវកក។ តំណាងសហព្រះរាជអាជ្ញាបានបន្តសំណួរថា តើសាក្សីស្គាល់ ហ៊ូ នឹម ដោយរបៀបណា? ឆ្លើយតបនឹងសំណួរនេះសាក្សីបានបញ្ជាក់ថា ខ្លួនបានស្គាល់ ហ៊ូ នឹម ដោយសារខ្លួនធ្លាប់ធ្វើការនៅមន្ទីរ៣២ ប៉ុន្តែនៅពេលនោះខ្លួនក៏មិនបានដឹងពីតួនាទីរបស់ ហ៊ូ នឹម ឡើយ។ សាក្សីបានបន្តរៀបរាប់ថា បន្ទាប់ពីបញ្ចូលជាសមាជិកហើយ ខ្លួនត្រូវបានបញ្ជូនឲ្យធ្វើការនៅមន្ទីរ៣០៤ដែលមានទីតាំងនៅខេត្តកំពង់ធំជិតភូមិបឹងគគីរ។ នៅទីនោះប្រហែលមួយឆ្នាំ ខ្លួនបានផ្លាស់ទៅនៅក្នុងក្រុមសិល្បៈចម្រៀង និងរបាំ។ សហព្រះរាជអាជ្ញារងជាតិ គារ ស្មី បានបន្តសំណួរនេះ សាក្សីបានបញ្ជាក់ថា នៅពេលនោះ ខ្លួនមិនបានដឹងអំពីការរស់នៅរបស់ នួន ជា ទេ។ បន្ទាប់មក សហព្រះរាជអាជ្ញារងបានបន្តសួរថា តើឃុំពាមដែលនៅក្នុងស្រុកកំពង់ត្រឡាចនោះជាទីតាំងមូលដ្ឋានរបស់មេដឹកនាំខ្មែរក្រហមដែរឬយ៉ាងណា? ទាក់ទងនឹងទីតាំងនេះសាក្សីបានបញ្ជាក់ថា ឃុំពាម មិនមែនជាមូលដ្ឋានរបស់មេដឹកនាំទេ មូលដ្ឋានរបស់មេដឹកនាំខ្មែរក្រហមនាពេលនោះគឺមានតែនៅក្នុងខេត្តកំពង់ធំ និងកំពង់ចាមប៉ុណ្ណោះ។ សាក្សីបានបន្តថា នៅក្នុងឆ្នាំ១៩៧៤ ខ្លួនបានទៅបរទេសជាមួយ អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធ, និង ទីវ អុល គឺទៅប្រទេសចិន

កូរ៉េ និងប្រទេសចំនួន១៣ផ្សេងទៀត រួមទាំងប្រទេសមួយចំនួននៅអឺរ៉ុបដែរ ។ សាក្សីបានបន្ថែមថា ខ្លួនបានទៅបរទេសដោយសារខ្លួនត្រូវសម្តែងសិល្បៈជាមួយសិល្បករពីររូប ផ្សេងទៀត ។

សហព្រះរាជអាជ្ញារងជាតិបានបន្តសួរទៀតថា តើសាក្សីស្គាល់ឈ្មោះ ទីវ អុល និង សួង ស៊ីគឿន ដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា ខ្លួនបានស្គាល់ ទីវ អុល និង សួង ស៊ីគឿន ប៉ុន្តែខ្លួនមិនបានដឹងអំពីតួនាទីរបស់អ្នកទាំងនោះឡើយ ។ បន្ទាប់មក សហព្រះរាជអាជ្ញារងជាតិបានសាកសួរដោយយោងលើឯកសារកំណត់ហេតុរបស់រណសិរ្សដែលនិយាយអំពីដំណើរទស្សនកិច្ចរបស់មេដឹកនាំខ្មែរក្រហមដើម្បីជាការរំឭកដល់សាក្សី ។ ទាក់ទងនឹងសំណួរនេះ សាក្សី នឹម សែម បានរៀបរាប់ថា នៅអំឡុងពេលនោះមេដឹកខ្មែរក្រហមមិនបានចេញទៅធ្វើទស្សនកិច្ចញឹកញាប់ទេ ។ សាក្សីបានរៀបរាប់បន្ថែមថា ក្រោយពេលត្រឡប់មកពីបរទេសវិញ ខ្លួនមិនបានចូលមកប្រទេសកម្ពុជាទេ គឺនៅពេលនោះ អៀង សារី បានចាត់តាំងឲ្យខ្លួនទៅធ្វើការនៅស្ថានីយវិទ្យុផ្សព្វផ្សាយសំឡេងនៅប្រទេសវៀតណាម ដោយមានតួនាទីជាអ្នកចម្រៀង ។ ចំណែកមេដឹកនាំដែលខ្លួនបានរួមដំណើរជាមួយនោះក៏បានទៅស្នាក់នៅក្នុងប្រទេសវៀតណាមដែរ ។ សាក្សីបានបន្ថែមថា នៅក្នុងកម្មវិធីវិទ្យុនោះក្រៅពីការផ្សាយចម្រៀងក៏មានការផ្សព្វផ្សាយអំពីការប្រយុទ្ធគ្នាជាមួយកងអាមេរិកដែរ ។

### ២.ក.២) ស្ថានភាពក្នុងក្រសួងឃោសនាការ

សហព្រះរាជអាជ្ញារងជាតិ ចាន់ តារាវស្នី បានបន្តការសួរទាក់ទងនឹងការវិលត្រឡប់មកប្រទេសកម្ពុជាវិញរបស់សាក្សី ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា ខ្លួនបានត្រឡប់ពីប្រទេសវៀតណាមវិញនៅឆ្នាំ១៩៧៥ ហើយមកធ្វើការនៅក្រសួងឃោសនាការខាងផ្នែកសិល្បៈដែលមាន ហ៊ូ នឹម ជាអ្នកចាត់តាំង ។ សាក្សីបានបន្តថា ហ៊ូ នឹម មានតួនាទីជារដ្ឋមន្ត្រីក្រសួងឃោសនាការនៅពេលនោះ ហើយ សៅ គឺជាប្រធានក្រុមសិល្បៈ និងជាអ្នកនិពន្ធបទចម្រៀង ។ ទាក់ទងនឹងការផ្សាយវិញ សាក្សីបានរៀបរាប់ថា រាល់អត្ថបទដែលត្រូវយកមកឲ្យខ្លួនអាន គឺមានឈ្មោះ ហាន ជាអ្នកសរសេរ ហើយអត្ថន័យនៅក្នុងនោះ គឺនិយាយអំពីការលើកទំនប់ និងជីកប្រឡាយជាដើម ។ ក្រៅពីនោះមានការអានអត្ថបទដែលនិយាយអំពីបរាជ័យរបស់ លន់ នល់ និងនិយាយអំពីជ័យជម្នះរបស់ខ្មែរក្រហមដែរ ។ សហព្រះរាជអាជ្ញាជាតិបានបន្តសួរថា តើសាក្សីធ្លាប់បានឮពាក្យ "ការតស៊ូវណ្ណៈ" ដែរឬទេ? សាក្សីបានឆ្លើយតបថា ខ្លួនធ្លាប់ឮពាក្យនេះ ប៉ុន្តែមិនដែលបានអានអត្ថបទណាដែលនិយាយទាក់ទងនឹងពាក្យនេះឡើយ ។

ជាចុងបញ្ចប់ សហព្រះរាជអាជ្ញារងជាតិបានសួរទាក់ទងនឹងការអានអត្ថបទដែលនិយាយអំពីការរៀបអាពាហ៍ពិពាហ៍ ការហាមមិនឲ្យប្រតិបត្តិតាមសាសនា ការជម្លៀសប្រជាជន និងការបង្អត់បាយជាដើម ។ សាក្សីបានបញ្ជាក់ថា ខ្លួនមិនដែលបានអានអត្ថបទដែលពាក់ព័ន្ធនឹងបញ្ហាទាំងនោះឡើយ ។

### ២.ខ) តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ

បន្ទាប់ពីបញ្ចប់ការសាកសួរ សហព្រះរាជអាជ្ញារង ចាន់ តារាវស្នី បានផ្ទេរវេទិកាជូនសហភាគីរបស់ខ្លួន គឺតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វាំងសង់ ដឺវ៉ាល់ ដើម្បីសួរបន្ត ។ ការសួររបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ គឺផ្តោតជាសំខាន់លើការងារនៅមន្ទីរក-៨ ការចាប់ខ្លួនកម្មាភិបាល និងតួនាទីរបស់ ខៀវ សំផន និង នួន ជា ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបន្តសួរទាក់ទងនឹងការងាររបស់សាក្សីចាប់ពីឆ្នាំ១៩៧៦ រហូតដល់ឆ្នាំ១៩៧៩ ។ ជាការឆ្លើយតបសាក្សីបានបញ្ជាក់ថា ខ្លួនបានទៅធ្វើការនៅមន្ទីរក-៨ ដែលជាកន្លែងដាំបន្លែ និងមានទីតាំងនៅជិតមន្ទីរក-១ ប៉ុន្តែ ខ្លួនមិនដឹងថានរណាជាប្រធាននៅទីនោះទេ ដោយគ្រាន់តែដឹងថា មន្ទីរនោះស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរ៨៧០ ។ សាក្សីបានបន្ថែមថា នៅមន្ទីរក-៨ ខ្លួនបានរស់នៅជាមួយគ្រួសាររបស់ ឡើង ដោយគ្រាន់តែនៅមើលកូនតែប៉ុណ្ណោះ ហើយមិនមានការងារអ្វីផ្សេងទៀតទេ ។

ទាក់ទងនឹងមន្ទីរក-៧ សាក្សីបានរៀបរាប់ថា មន្ទីរនោះមានទីតាំងនៅតាមមាត់ទន្លេមុខប្ដូនតាមផ្លូវឆ្ពោះទៅស្ពានជ្រោយចង្វារដែលស្ថិតក្រោមការគ្រប់គ្រងរបស់មន្ទីរ៨៧០ដែរ ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបន្តសួរទាក់ទងនឹងមន្ទីរ៨០៥



អៀង សារី និង វ៉ន វ៉េត (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

និងមន្ទីរក-១៧ ប៉ុន្តែសាក្សីបានបញ្ជាក់ថា ខ្លួនមិនស្គាល់មន្ទីរទាំងនោះទេ ។

### ២.១.១) តួនាទីរបស់កម្មាភិបាលឈ្មោះ លីន (គ្រួសាររបស់សាក្សី)

បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានបង្ហាញរូបថតជូនសាក្សីពិនិត្យ ដែលជារូបថតរបស់សាក្សីជាមួយគ្រួសារថតនៅឆ្នាំ១៩៨៧ ។ សាក្សី នឹម សែម បានទទួលស្គាល់ថារូបថតនោះពិតជារូបរបស់ខ្លួន ។ តំណាងសហព្រះរាជអាជ្ញាបានបង្ហាញរូបថតមួយទៀតដើម្បីឲ្យសាក្សីបញ្ជាក់ ។ សាក្សីបានបន្តថារូបនោះគឺជារូបរបស់ប្រពន្ធ សុន សេន ឈ្មោះ អាត ដែលថតជាមួយគ្រួសារខ្លួនដែរ ។ បន្ទាប់មកតំណាងសហព្រះរាជអាជ្ញាបានបន្តសំណួរទាក់ទងនឹងការងាររបស់ លីន ចាប់តាំងពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ ជាការឆ្លើយតប សាក្សីបានបញ្ជាក់ថា ខ្លួនមិនដឹងកន្លែងធ្វើការពិតប្រាកដរបស់គ្រួសារខ្លួនទេ ដោយសារគ្រួសារខ្លួនបានទៅធ្វើការច្រើនកន្លែង ហើយខ្លួនក៏មិនបានដឹងថា នរណាជាប្រធាននោះដែរ ។ តំណាងសហព្រះរាជអាជ្ញាបានបន្តសួរអំពីទំនាក់ទំនងរវាង ប៉ន់ និង លីន ហើយសាក្សីបានបញ្ជាក់ថា ប៉ន់ គឺជាអ្នកទទួលខុសត្រូវនៅមន្ទីរ៨៧០ ប៉ុន្តែខ្លួនមិនដែលឃើញគ្រួសារខ្លួន ធ្វើការជាមួយ ប៉ន់ ឡើយដោយអះអាងថា ក្រៅពីធ្វើជានីសាររបស់ ប៉ុល ពត គ្រួសាររបស់សាក្សី បានមកធ្វើការនៅមន្ទីរក-១វិញ ។ ចំណែកឯនីសារផ្សេងៗទៀតមានដូចជា គាន, ឡឿង និង ជាម ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាបានបន្តសួរទាក់ទងនឹងមន្ទីរស-៧១ ប៉ុន្តែសាក្សីបានបញ្ជាក់ថា ខ្លួនមិនដឹងអំពីមន្ទីរនេះទេ ។ ឆ្លើយតបនឹងសំណួរផ្សេងទៀតរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងតួនាទីរបស់ លីន សាក្សី នឹម សែម បានបញ្ជាក់ថា លីន ជាអ្នកគ្រប់គ្រងលើមន្ទីរ “ក” ទាំងអស់រួមទាំងមន្ទីរ៨៧០ ។

### ២.១.២) ការចាប់ខ្លួនកម្មាភិបាល

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វ៉ាំងសង់ បានបន្តសួរបន្តទាក់ទងនឹងអំណាចរបស់ លីន លើការស៊ើបអង្កេតចំពោះកម្មាភិបាលដែលក្បត់ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា ខ្លួន មិនបានដឹងពីបញ្ហានេះទេ ដោយអះអាងថាពេលខ្លះប្តីប្រពន្ធក៏មិនត្រូវដឹងរឿងទាំងអស់នោះដែរ ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ បានបន្តដោយលើកឡើងអំពីកំណត់ហេតុដែលនិយាយអំពីការចាប់ខ្លួន ហ៊ូ នឹម ហើយសាក្សីបានរៀបរាប់ថា នៅពេលនោះ លីន បានសាកសួរខ្លួនជាច្រើនដងទាក់ទងនឹង តួនាទីរបស់ ហ៊ូ នឹម ហើយ លីន បានប្រាប់ខ្លួនថា ហ៊ូ នឹម និង សៅ ត្រូវបានអង្គការចាប់ខ្លួន ដោយចោទថាជាខ្សែសេ.អ៊ី.អា ដែលនៅក្នុងនោះក៏មានឈ្មោះរបស់សាក្សីផ្ទាល់ខ្លួនដែរ ។ សំណាងល្អសាក្សីមិនត្រូវបានចាប់ខ្លួនដោយសារ ប៉ុល ពត ជាអ្នកការពារ ។ សាក្សីបានបន្តថា អ្នកដែលត្រូវអង្គការចាប់ខ្លួននឹងត្រូវបញ្ជូនទៅជំរំ តាឡី ដែលមានទីតាំងនៅស្ទឹងមានជ័យ ដើម្បីធ្វើស្រែ ហើយបន្ទាប់មកនឹងត្រូវបញ្ជូនទៅកន្លែងផ្សេងៗទៀត ។

### ២.១.៣) តួនាទីរបស់មេដឹកនាំខ្មែរក្រហម

បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វ៉ាំងសង់ បានបន្តសួរទាក់ទងនឹងតួនាទីរបស់ នួន ជា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុន្តែសាក្សីបានបញ្ជាក់ថា ខ្លួនមិនដឹងអំពីតួនាទីរបស់ នួន ជា ឡើយដោយសារខ្លួនបានជួប នួន ជា តែម្តងគត់នៅមន្ទីរក-៣ ។ បន្ទាប់មក តំណាងសហព្រះរាជអាជ្ញាបានលើកយកចម្លើយរបស់សាក្សីដែលបានឆ្លើយក្នុងពេលធ្វើបទសម្ភាសន៍ជាមួយអង្គការ អេស.អូ.អា.អេស ដែលបញ្ជាក់ថា ខៀវ សំផន គឺជាថ្នាក់លើរបស់ ប៉ន់ និង លីន ដើម្បីឲ្យសាក្សីបញ្ជាក់ ប៉ុន្តែសាក្សី នឹម សែម បានបដិសេធចំពោះការដកស្រង់នេះ ។ សាក្សីបានបន្តថា ខ្លួនបានជួប ខៀវ សំផន នៅមន្ទីរក-៣តែម្តងគត់ក្នុងពេល ខៀវ សំផន ធ្វើដំណើរទស្សនកិច្ចជាមួយ នួន ជា នៅមន្ទីរក-៣ ។ ជាចុងក្រោយ តំណាងសហព្រះរាជអន្តរជាតិ វ៉ាំងសង់ បានបន្តសួរទាក់ទងនឹងមុខងាររបស់មន្ទីរក-៣ ហើយសាក្សីបានបញ្ជាក់ថា មន្ទីរក-៣ គឺជាកន្លែងស្នាក់នៅរបស់ អៀង សារី, ខៀវ សំផន និង ប៉ុល ពត ។

## ៣) ការសួរដេញដោលសាក្សីដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

បន្ទាប់ពីបញ្ចប់ការសាកសួររបស់តំណាងសហព្រះរាជអាជ្ញា លោកប្រធានបានផ្ទេរវេទិកាជូនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលមានលោក ឡោ ជុនធី និងសហមេធាវីនាំមុខអន្តរជាតិ

តំណាងដើមបណ្តឹងរដ្ឋប្បវេណី អេលីហ្សាប៉ែត ស៊ីម៉ូណូហ្វត ។

### ៣.ក) មេធាវីជាតិ

លោកមេធាវីជាតិ ឡោ ជុនធី បានចាប់ផ្តើមដោយសាកសួរអំពីការធ្វើដំណើរទស្សនកិច្ចរបស់សាក្សីទៅប្រទេសចំនួន១៣ជាមួយមេដឹកនាំខ្មែរក្រហមថា តើនៅពេលនោះមានការជួបជាមួយនិស្សិតខ្មែរដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា ពេលទៅដល់ប្រទេសអាល់ហ្សេរី គណៈប្រតិភូខ្មែរក្រហមបានជួបជាមួយឯកអគ្គរាជទូត និងបានជួបប្រជាជនខ្មែរមួយចំនួនដែរ ។ បន្ទាប់មក មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី បានបន្តសាកសួរទាក់ទងនឹងការផ្សាររបស់សាក្សីនៅប្រទេស


មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឡោ ជុនធី

វៀតណាម ។ សាក្សីបានបញ្ជាក់ថា នៅពេលនោះខ្លួនមានតួនាទីជាអ្នកចម្រៀង និងសម្តែងសិល្បៈតែប៉ុណ្ណោះ ។ ចំណែក សួង និង ស៊ូ មានតួនាទីជាអ្នកអានព័ត៌មាន ។ មេធាវី ឡោ ជុនធី បានបន្តសួរសាក្សីទាក់ទងនឹងការជម្លៀសប្រជាជន ហើយសាក្សីបានបញ្ជាក់ថា ពេលខ្លួនមកដល់ភ្នំពេញដំបូងខ្លួន បានឃើញទីក្រុងមានសភាពស្ងប់ស្ងាត់ ហើយក្រោយមកទើបខ្លួនដឹងថា មានការជម្លៀសប្រជាជនចេញពីភ្នំពេញ ។ ជាចុងក្រោយ មេធាវីជាតិ ឡោ ជុនធី បន្តសួរពីមូលហេតុដែលនាំឲ្យ លីន សួរសាក្សីច្រើនដងអំពីការចាប់ខ្លួនរបស់ ហ៊ូ នឹម ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា នៅពេលនោះ លីន មានការភ័យខ្លាចថាអង្គការនឹងអាចចាប់ខ្លួន ប្រសិនបើអង្គការរកឃើញថាខ្លួនជាជនក្បត់នោះ ។

### ៣.ខ) សហមេធាវីនាំមុខអន្តរជាតិ

បន្ទាប់ពីបញ្ចប់ការសួរដោយសហមេធាវីជាតិ តំណាងដើមបណ្តឹងរដ្ឋប្បវេណីអន្តរជាតិ អេលីហ្សាប៉ែត ស៊ីម៉ូណូហ្វត បានបន្តដោយចាប់ផ្តើមសួរអំពីការធ្វើសេចក្តីថ្លែងការណ៍របស់ ខៀវ សំផន និង នួន ជា ខណៈពេលទៅធ្វើទស្សនកិច្ចទាំង១៣ប្រទេស ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា នៅពេលនោះពិតជាមានការធ្វើសុន្ទរកថាមែន ប៉ុន្តែខ្លួនមិនចាំថាសុន្ទរកថានោះ និយាយអំពីអ្វីនោះទេ ។ ទាក់ទងនឹងការផ្លាស់កន្លែងធ្វើការផ្សារពីវៀតណាមមកភ្នំពេញ សាក្សីបានរៀបរាប់ថា ខ្លួនបានឃើញទិដ្ឋភាពនៅក្នុងទីក្រុងមានសភាពស្ងប់ស្ងាត់ដោយសារ


មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស៊ីមូណូហ្វត

មិនមានប្រជាជនរស់នៅ ។

មេធាវីអន្តរជាតិបានស្នើសាក្សីឲ្យរៀបរាប់អំពីភាពខុសគ្នានៃការរៀបការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងការរៀបការនៅជំនាន់មុន ។ ជាការឆ្លើយតប សាក្សីបានបញ្ជាក់ថា ការរៀបការនៅក្នុងរបបខ្មែរក្រហម គឺខុសពីការរៀបការនៅសម័យមុនដោយសារនៅពេលនោះមានការចូលរួមពីថ្នាក់ដឹកនាំពីរបីនាក់តែប៉ុណ្ណោះ ហើយគ្រាន់តែមានការចាប់ដៃគ្នា និងប្តេជ្ញាថានឹងខំធ្វើការផ្សារបម្រើអង្គការជារៀងរហូត ។ បន្ទាប់មក មេធាវីអន្តរជាតិបានបន្តសួរដោយលើកយកចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ដែលបានរៀបរាប់ថា នៅក្នុងរបបខ្មែរក្រហម អ្នកដែលមានផ្ទៃពោះ និងអ្នកដែលទើបតែសម្រាលកូនរួចត្រូវបានបង្ខំឲ្យ

ទៅធ្វើការងារ ។ ទាក់ទងនឹងបញ្ហានេះ សាក្សីបានបញ្ជាក់ថា ខ្លួនមិនធ្លាប់ឮរឿងទាំងនេះទេ ដោយសារខ្លួនរស់នៅតែក្នុងមន្ទីរក-៨ តែប៉ុណ្ណោះ ។ មេធាវីបានបន្តសួរពីមូលហេតុដែលធ្វើឲ្យសាក្សីមានការភ័យខ្លាចនៅពេលដែល លីន ជជីកសួរខ្លួនអំពីការចាប់ខ្លួន ហ៊ូ នឹម និង សៅ ។ សាក្សីបានបញ្ជាក់ថា នៅពេលនោះប្រសិនបើខ្លួនត្រូវបានអង្គការចាប់នោះខ្លួននឹងត្រូវស្លាប់ ដោយសារនៅកន្លែងដែលចាប់ទៅនោះជាកន្លែងប្រួតស្រូវ ហើយអ្នកដែលត្រូវបានអង្គការនាំទៅ សុទ្ធតែត្រូវស្លាប់ទាំងអស់ ។

## ៤) ការសួរដេញដោលសាក្សីដោយក្រុមមេធាវីការពារក្តីទាំងបីក្រុម

### ៤.ក) ក្រុមមេធាវីការពារក្តី ខៀវ សំផន

មេធាវីជាតិ គង់ សំអុន បានចាប់ផ្តើមដោយស្នើឲ្យសាក្សីបញ្ជាក់ឡើងវិញទាក់ទងនឹងការសិក្សា ដែលសាក្សីបានបញ្ជាក់ថាខ្លួនរៀនបានថ្នាក់ទីបី ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីក៏បានបញ្ជាក់ថា ខ្លួន រៀនបានបីឆ្នាំមិនមែនថ្នាក់ទីបីនោះទេ ។ បន្ទាប់មកសាក្សីបានបន្តរៀបរាប់ពីមូលហេតុដែលនាំឲ្យខ្លួន រត់ចូលព្រៃ ដោយបញ្ជាក់ថា នៅពេលនោះបងរបស់ខ្លួនបានចូលព្រៃមុនដូច្នេះទាហាន លន់ នល់ តែងតែរករឿង ហើយដោយភាពភ័យខ្លាចទើបខ្លួនសម្រេចចិត្តរត់ចូលព្រៃដែរ ។ មេធាវី គង់ សំអុន បានបន្តសួរទាក់ទងនឹងការគ្រប់គ្រងមន្ទីរក-៨ ដោយសាក្សីបានបញ្ជាក់ថា មន្ទីរនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់មន្ទីរ៨៧០ រួមទាំងមន្ទីរកផ្សេងទៀត ។ មេធាវីជាតិបានបន្តសួរទាក់ទងនឹងទីតាំងនៃមន្ទីរក-១ និងក-៣ ។ សាក្សីបានរៀបរាប់ថា មន្ទីរក-១មានទីតាំងនៅតាមមាត់ទន្លេ ចំណែកឯមន្ទីរក-៣ គឺមានទីតាំងនៅខាងលិចវិមានឯករាជ្យ ។ មុនពេលបញ្ចប់ មេធាវីជាតិគង់ សំអុន បានបន្តការសាកសួរ ដោយឲ្យសាក្សីពន្យល់ពីគោលការណ៍រក្សាការសម្ងាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា ការរក្សាការសម្ងាត់នៅពេលនោះ គឺសំដៅលើការមិនឲ្យអ្នកដទៃដឹងរឿងអ្វីមួយក្រៅពីខ្លួនឯងឡើយ ។

### ៤.ខ) ក្រុមមេធាវីការពារក្តី នួន ជា

មេធាវីអន្តរជាតិការពារក្តីជនជាប់ចោទ នួន ជា គឺលោក អេនឌ្រូ អ៊ីនូស្ស៊ី បានចោទសួរទាក់ទងនឹងឈ្មោះ ជាម ដើម្បីឲ្យសាក្សីបញ្ជាក់ថា តើ ជាម នោះជាអ្នកណា? ជាការឆ្លើយតប សាក្សីបានបញ្ជាក់ថា ជាម គឺជាជនជាតិភាគតិចដែលធ្លាប់ធ្វើជាកងការពារ ប៉ុល ពត ហើយក្រោយមកត្រូវបាន ផ្លាស់ទៅធ្វើការនៅក្រសួងការបរទេសវិញ ។ សាក្សីបានបន្តថា ជាម មានឈ្មោះមួយទៀតគឺ ភី ភួន សព្វថ្ងៃរស់នៅទល់មុខសាលាស្រុកម៉ាឡៃ ។ បន្ទាប់មកមេធាវីបានបន្តសួរថា តើសាក្សីបានដឹងអំពីការផ្តល់សក្ខីកម្មរបស់ ជាម នៅតុលាការដែរឬទេ? សាក្សីបានបញ្ជាក់ថា ខ្លួនមិនដឹងអំពីការផ្តល់សក្ខីកម្មរបស់ ជាម នោះទេ ។ ក្រោយមកមេធាវីអន្តរជាតិ អ៊ីនូស្ស៊ី បានបន្តសួរទាក់ទងនឹងការឆ្លើយរបស់ ភី ភួន ពាក់ព័ន្ធនឹងលោក ហោ ណាំហុង ដែលអះអាងថា ភី ភួន បានទទួលរងសម្ពាធពីលោក ហោ ណាំហុង ។ ភ្លាមៗនោះ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ វ៉ាំងសង់ បានជំទាស់នឹងសំណួររបស់សាក្សី ដោយហេតុថា អង្គហេតុដែលមេធាវីលើកឡើងនោះមិនពាក់ព័ន្ធនឹងអង្គហេតុនៅក្នុងសវនាការ ។ បន្ទាប់ មកចៅក្រម និល ណុន បានបង្គាប់មិនឲ្យសាក្សីឆ្លើយតបនឹងសំណួររបស់មេធាវីការពារក្តី នួន ជា និង យល់ស្របចំពោះការជំទាស់របស់តំណាងសហព្រះរាជអាជ្ញា ។

### ៤.គ) ក្រុមមេធាវីការពារក្តី អៀង សារី

បន្ទាប់ពីបញ្ចប់ការសួរដេញដោលរបស់មេធាវីការពារក្តីជនជាប់ចោទ នួន ជា ចៅក្រម និល ណុន បានផ្ទេរវេទិកាជូនមេធាវីការពារក្តី អៀង សារី គឺមេធាវីអន្តរជាតិ ម៉ៃឃើល កាណាវ៉ាស ។ មេធាវីអន្តរជាតិបានបន្តសួរថា តើសាក្សីដឹងថា ជាម ធ្លាប់ធ្វើការជាមួយ លីន ដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា ជាម ពិតជាធ្លាប់ធ្វើការជាមួយ លីន ប៉ុន្តែក្រោយមក ជាម បានផ្លាស់ទៅធ្វើការនៅក្រសួងការបរទេសវិញ ។ មុនពេលបញ្ចប់ មេធាវី កាណាវ៉ាស បានបន្តសួរ ដោយស្នើឲ្យសាក្សីបញ្ជាក់ពីការជួបគ្នាជាមួយ ជាម នៅពេលថ្មីៗនេះ ប៉ុន្តែជាការឆ្លើយតប សាក្សី បានបញ្ជាក់ថា ខ្លួនបានជួប ជាម កាលពីឆ្នាំ២០០៥ ប៉ុន្តែក្រោយមកខ្លួនមិនដែលជួបជាមួយ ជាម ទៀតឡើយ ។

**សូមបញ្ជាក់ថា** សវនាការសួរដេញដោលសាក្សី ទឹម សែម គឺចំណាយពេលត្រឹមតែមួយថ្ងៃតែប៉ុណ្ណោះ ដោយបញ្ចប់នៅថ្ងៃដដែលគឺថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២ ។

# សវនាការសួរដេញដោលសាក្សី ខៀវ អេន
## ថ្ងៃទី១-២ ខែតុលា ឆ្នាំ២០១២

### សេចក្តីផ្តើម

នៅថ្ងៃទី១ ខែតុលា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានកោះហៅសាក្សីមួយរូបទៀត ដែលមានតួនាទីជាអតីតបុគ្គលិកក្រសួងព័ត៌មាន និងឃោសនាការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដើម្បីចូលផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ។ សក្ខីកម្មសាក្សីរូបនេះ បានផ្តោតជាសំខាន់លើការគ្រប់គ្រងរបស់ជនជាប់ចោទ នួន ជា លើក្រសួងឃោសនាការជំនួស យុន យ៉ាត (ភរិយារបស់ សុន សេន) នៅអំឡុងពេលដែល យុន យ៉ាត បានអវត្តមានមួយរយៈពីក្រសួងនេះ ។ មុនពេល យុន យ៉ាត ចូលមកធ្វើជារដ្ឋមន្ត្រីក្រសួងឃោសនាការ ក្រសួងនេះស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ហ៊ូ នឹម ដែលត្រូវបានចោទប្រកាន់ថា "ក្បត់" បន្ទាប់មកត្រូវបានចាប់បញ្ជូនទៅមន្ទីរស-២១ ហើយបុគ្គលិកនៅក្រោមការគ្រប់គ្រងរបស់ ហ៊ូ នឹម ភាគច្រើនត្រូវបានចាប់ខ្លួន ។ ការសួរដេញដោលសាក្សីរូបនេះ បានចាប់ផ្តើមដោយសហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី និងលោកចៅក្រម ហ្សង់ម៉ាក ឡាវ៉ឺញ បន្ទាប់មក អង្គជំនុំជម្រះបានប្រគល់វេទិកាជូនមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម ។

ក្នុងអំឡុងពេលនៃការសាកសួរដេញដោលជនជាប់ចោទ អៀង សារី មិនមានវត្តមាននៅក្នុងបន្ទប់សវនាការឡើយ ដោយសារតែបញ្ហាសុខភាព និងត្រូវសម្រាកព្យាបាលរយៈពេលវែងនៅមន្ទីរមិត្តភាពខ្មែរ-សូវៀត ។

### ១) ប្រវត្តិសាវតារសាក្សី ខៀវ អេន

នៅមុនពេលប្រគល់វេទិកាជូនភាគីដើម្បីសាកសួរដេញដោល ប្រធានអង្គជំនុំជម្រះលោកចៅក្រម និល នុន បានសួរសាក្សីអំពីប្រវត្តិសាវតាររបស់លោក ខៀវ អេន ។ សាក្សីបានឆ្លើយតបនឹងសំណួររបស់ចៅក្រម ដោយបញ្ជាក់ថា សព្វថ្ងៃលោកមានអាយុ៦០ឆ្នាំ រស់នៅខេត្តប៉ៃលិន មានមុខរបរជាមន្ត្រីរាជការ មានឪពុកឈ្មោះ ខៀវ អុន និងម្តាយឈ្មោះ ឃឹម យន និងមានប្រពន្ធឈ្មោះ យួន ចាន់ធី មានកូន៥នាក់ ។

សាក្សីបានអះអាងថា មុនពេលចូលមកផ្តល់សក្ខីកម្មនៅចំពោះអង្គជំនុំជម្រះ លោកធ្លាប់បានផ្តល់កិច្ចសម្ភាសន៍ចំនួនមួយដងជាមួយអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតនៅចំការកាហ្វេ ក្នុងខេត្តប៉ៃលិន ។

### ២) ការសួរដេញដោលសាក្សីដោយសហព្រះរាជអាជ្ញា

នៅអំឡុងពេលនៃការសួរដេញដោលសាក្សី ខៀវ អេន សហព្រះរាជអាជ្ញាបានចំណាយពេលពេញមួយព្រឹកថ្ងៃទី១ ខែតុលា ឆ្នាំ២០១២ ដោយផ្តោតជាសំខាន់លើចាប់ខ្លួន ហ៊ូ នឹម និងការបាត់ខ្លួនកម្មាភិបាលនៃក្រសួងឃោសនា ការជាបន្តបន្ទាប់ ។



សាក្សី ខៀវ អេន

សំណួររបស់សហព្រះរាជអាជ្ញាក៏បានផ្តោតលើការចូលគ្រប់គ្រងក្នុងក្រសួងឃោសនាការជំនួស យុន យ៉ាត ដោយជនជាប់ចោទ នួន ជា ក្នុងរយៈកាលប៉ុន្មានខែមុនពេលទាហានវៀតណាមវាយចូលប្រទេសកម្ពុជា ។

### ២.ក) សហព្រះរាជអាជ្ញាជាតិ

តំណាងសហព្រះរាជអាជ្ញាជាតិ សេង ប៊ុនឃាង បានផ្តើមសំណួរដំបូងរបស់ខ្លួនទាក់ទងនឹងបទសម្ភាសន៍រវាងសាក្សីជាមួយនឹងអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ។

បន្ទាប់មកលោកតំណាងសហព្រះរាជអាជ្ញាបានសួរអំពីជ័យជម្នះរបស់ទាហានខ្មែរក្រហមលើទាហាន លន់ នល់ នៅក្នុងភូមិដែល



គំណាងសហព្រះរាជអាជ្ញាជាតិ សេង ប៊ុនឃាង

លោករស់នៅ។ សាក្សីបានបញ្ជាក់ថា លោកមិនបានចាំច្បាស់ថាតើខ្មែរក្រហមបានយកឈ្នះលើទាហាន លន់ នល់ នៅក្នុងឃុំរបស់លោករស់នៅក្នុងឆ្នាំណាពិតប្រាកដទេ ប៉ុន្តែប្រហែលជានៅពេលដែលអាមេរិកឈប់ទម្លាក់គ្រាប់បែកមកលើប្រទេសកម្ពុជានៅឆ្នាំ១៩៧៣។ លោកបានបន្តថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ លោកកំពុងស្នាក់នៅស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង នៅតាមបណ្តោយមាត់ទន្លេដើម្បីត្រៀមប្រយុទ្ធនៅឡើយ ហើយលោកមិនទាន់ជឿថាខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុងនៅឡើយទេ។ ឆ្លើយតបនឹងសំណួររបស់សហព្រះរាជអាជ្ញាទាក់ទងនឹងការជម្លៀសប្រជាជន សាក្សីបានបញ្ជាក់ថា ខ្លួនធ្លាប់បានដឹងអំពីការជម្លៀសចេញទីរួមខេត្តមកស្រុកដែលខ្លួនស្នាក់នៅ ប៉ុន្តែខ្លួនមិនដឹងអំពីការជម្លៀសប្រជាជននៅទីក្រុងភ្នំពេញទេ ហើយលោកក៏មិនបានដឹងដែរថា តើមានប្រជាជនទីក្រុងភ្នំពេញត្រូវបានជម្លៀសទៅកាន់ស្រុកដែលលោកស្នាក់នៅដែរឬយ៉ាងណានោះទេ។ សាក្សីបន្ថែមថា នៅពេលនោះ លោកជាអ្នកចាំទទួលប្រជាជនដែលត្រូវបានជម្លៀសចេញពីទីប្រជុំជន ដោយទទួលបញ្ជាពីមេកងរបស់លោក។ នៅពេលបន្ទាប់ ប្រជាជនដែលត្រូវបានជម្លៀសទាំងនោះត្រូវបានបញ្ជាឲ្យលើកប្រឡាយ និងជីកទំនប់ និងត្រូវបានដាក់បញ្ចូលក្នុងសហករណ៍នៅតាមឃុំ។

ឆ្លើយតបនឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញាទាក់ទងនឹងការចាកចេញមកទីក្រុងភ្នំពេញ សាក្សីបានបញ្ជាក់ថា ខ្លួនត្រូវបានថ្នាក់លើផ្ទេរមកទីក្រុងភ្នំពេញ ដោយស្នាក់នៅជិតព្រះបរមរាជវាំង ប៉ុន្តែមិនទាន់មានភារកិច្ចអ្វីនៅឡើយទេ។ ក្រោយមកសាក្សីត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅក្រសួងឃោសនាការជាមួយនឹងបងភាស់ ប៉ុន្តែលោកមិនស្គាល់ ភាស់ ថាជានរណា និងមានតួនាទីជាអ្វីទេ។ ក្រោយមកទើបលោកដឹងថា ភាស់ គឺជាឈ្មោះរបស់ ហ៊ូ នឹម និងមានតួនាទីជារដ្ឋមន្ត្រីក្រសួងឃោសនាការ។

សាក្សី ខៀវ អេន បានបន្តថា លោកត្រូវបានផ្ទេរភារកិច្ចឲ្យទៅធ្វើការនៅមន្ទីរក-៣៣ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ឈ្មោះ សម ដែលមានទីតាំងនៅក្បែរសាលា លីសេ ដេកាត។ នៅទីនោះ លោកមានភារកិច្ចជាអ្នកទាញយកព័ត៌មានដែលផ្សព្វផ្សាយនៅក្នុងសារព័ត៌មានបរទេស ហើយប្រភេទព័ត៌មានដែល លោកទាញយក គឺជាព័ត៌មានផ្នែកសេដ្ឋកិច្ច ប៉ុន្តែលោកមិនបានដឹងអំពីខ្លឹមសារនៃព័ត៌មានទាំងអស់នោះទេ ដោយសារព័ត៌មានទាំងនោះផ្សព្វផ្សាយជាភាសាអង់គ្លេស និងបារាំង។ ទីភ្នាក់ងារព័ត៌មានទាំងនោះរួមមាន អាអេសប៉េ, រ៉យទ័រ, អ៊ុយ.ពេ.អ៊ី និងស៊ីនហួរ។ បន្ទាប់ពីទាញយកព័ត៌មានទាំងនោះហើយ លោកបញ្ជូនឯកសារទាំងនោះឲ្យថ្នាក់លើ ប៉ុន្តែលោកមិនដឹងថាឯកសារទាំងនោះត្រូវបញ្ជូនទៅទីណាទៀតទេ។

តំណាងសហព្រះរាជអាជ្ញាបានបន្តសាកសួរទាក់ទងនឹងការបាត់ខ្លួនរបស់ ហ៊ូ នឹម ដោយចោទសំណួរថា តើសាក្សីដឹងអំពីការបាត់ខ្លួនរបស់ ហ៊ូ នឹម ដែរឬទេ? សាក្សី ខៀវ អេន អះអាងថា លោកបានដឹងថា ហ៊ូ នឹម ត្រូវបានដកចេញពីតំណែងរដ្ឋមន្ត្រីក្រសួងឃោសនាការនៅឆ្នាំ១៩៧៧។ ប៉ុន្តែ លោកមិនបានដឹងអំពីមូលហេតុនៃការចាប់ខ្លួននោះទេ។ សាក្សីបន្តថា លោកបានដឹងអំពីការចាប់ខ្លួននេះ នៅពេលដែល យុន យ៉ាត ចូលមកកាន់តំណែងជារដ្ឋមន្ត្រីក្រសួងឃោសនាការជំនួស ហ៊ូ នឹម។ ពេលនោះ យុន យ៉ាត បានបើកវគ្គប្រជុំមួយដើម្បីជូនដំណឹងដល់បុគ្គលិកទាំងអស់អំពីការចាប់ខ្លួន ហ៊ូ នឹម ដោយអះអាងថា ហ៊ូ នឹម បានប្រព្រឹត្តអំពើក្បត់ និងបម្រើការឲ្យភ្នាក់ងារ សេ.អ៊ី.អា។ ឆ្លើយតប

នឹងសំណួររបស់តំណាងសហព្រះរាជអាជ្ញា ដែលសួរថា តើនរណាជាអ្នកបញ្ជូន យុន យ៉ាត ឲ្យមកបើកកិច្ចប្រជុំដែលនិយាយអំពីបញ្ហានេះ? សាក្សីបានបញ្ជាក់ថា លោកមិនបានដឹងថានរណាជាអ្នកបញ្ជូន យុន យ៉ាត មកធ្វើបទបង្ហាញនៅក្នុងកិច្ចប្រជុំនេះទេ ប៉ុន្តែលោកគិតថាប្រហែលជាបក្សជាអ្នកបញ្ជូនមក ។ ទាក់ទងនឹងទីកន្លែងនៃកិច្ចប្រជុំនោះ សាក្សីមិនបានចាំថាមានទីតាំងនៅកន្លែងណាច្បាស់លាស់ទេ ប៉ុន្តែលោកគិតថា អាចនៅមន្ទីរដែលលោកធ្វើការនៅជិតសាលា លីសេ ដេកាត ឬនៅបុរីកីឡា ។

សាក្សី ខៀវ អេន បានរៀបរាប់ថា បន្ទាប់ពីការបាត់ខ្លួនហ៊ូ នឹម ប្រពន្ធកូនរបស់ ហ៊ូ នឹម អ្នកធ្វើការជាមួយលោក(សាក្សី) បានបាត់ខ្លួនជាបន្តបន្ទាប់ ហើយនៅសល់តែលោកម្នាក់គត់ ។ ក្រោយមកទើបមានបញ្ចូលបុគ្គលិកដែលមកពីភូមិភាគនិរតីដើម្បីជំនួសកន្លែងអ្នកដែលបានបាត់ខ្លួន ។ សាក្សីបន្ថែមថា អ្នកដែលបាត់ខ្លួន គឺជាអ្នកដែលធ្លាប់រស់នៅភូមិភាគបូព៌ា ។

តំណាងសហព្រះរាជអាជ្ញាបានសួរសាក្សីទៀតថា តើសាក្សីធ្លាប់បានជួបជាមួយ នួន ជា ដែរឬទេ? សាក្សីបានបញ្ជាក់ថា ខ្លួនធ្លាប់បានជួប នួន ជា ប៉ុន្តែមិនធ្លាប់បាននិយាយជាមួយ នួន ជា ទេ គឺគ្រាន់តែប្រគល់ឯកសារ ជូន នួន ជា តែប៉ុណ្ណោះ ។ សាក្សីបន្តថា នួន ជា ធ្លាប់បានចូលទៅពិនិត្យមើលនៅក្នុងទីកន្លែងធ្វើការរបស់លោក និងដាស់តឿនបុគ្គលិកនៅទីនោះឲ្យខស្សាហ៍ព្យាយាមធ្វើការងារដើម្បីបដិវត្ត ។ សាក្សីបានបន្តថា លោកមិនដឹងថា នួន ជា មានតួនាទីអ្វីនៅក្នុងក្រសួងឃោសនាការទេ លោកគ្រាន់តែដឹងថា នួន ជា បានទៅទីនោះជារៀងរាល់ព្រឹក ។ សាក្សីបន្ថែមទៀតថា ទោះបីជាមានការចាប់ខ្លួនកម្មាភិបាលក៏ដោយ ការប្រជុំនៅក្រសួងរបស់លោកនៅតែបន្តមាន ។ នៅអំឡុងពេលនៃកិច្ចប្រជុំនោះ នួន ជា ធ្លាប់បានប្រាប់អ្នកចូលរួមថា កុំឲ្យមានការបែងចែកបន្តទៀតថានរណាជាប្រជាជនថ្មី និងនរណាជាប្រជាជនចាស់ ។

### ២.១) តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ

តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ គឺលោក ខេល លីសាក់ បានបន្តការសួរដេញដោលសាក្សី ខៀវ អេន ដោយត្រឡប់សួរទាក់ទងនឹងការប្រយុទ្ធនៅឧដុង្គនៅក្នុងឆ្នាំ១៩៧៤ ប៉ុន្តែលោកសាក្សីបានឆ្លើយ តបនឹងសំណួរនេះថា លោកមិនបានដឹងលម្អិតអំពីការប្រយុទ្ធនៅពេលនោះទេ ដោយសារលោកមិនបានរស់នៅទីនោះ ។ បន្ទាប់មកលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ


តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ខេល លីសាក់

បានសួរសំណួរដោយផ្តោតសំខាន់ទាក់ទងនឹងការជម្លៀសប្រជាជនពីទីរួមខេត្តទៅស្រុកដែលសាក្សីស្នាក់នៅ ដែលសំណួរទាំងអស់មានលក្ខណៈស្រដៀងគ្នានឹងសំណួរដែលតំណាងសហព្រះរាជអាជ្ញាជាតិបានចោទសួរ ហើយចម្លើយត្រូវបានសាក្សីយោងលើចម្លើយដែលខ្លួនបានឆ្លើយតបនឹងតំណាងសហព្រះរាជអាជ្ញាជាតិ ។

ឆ្លើយតបនឹងសំណួរទាក់ទងនឹងការងារនៅក្រសួងឃោសនាការ សាក្សីបានបញ្ជាក់ថា ឯកសារដែលខ្លួនបញ្ជូនឲ្យ នួន ជា គឺជាឯកសារបោះពុម្ពចេញពីម៉ាស៊ីន និងបន្តថាខ្លួនបានប្រគល់ឯកសារជូនបានតែប៉ុន្មានដងប៉ុណ្ណោះ ដោយសារនៅក្នុងក្រសួងនោះមានផ្នែកសម្រាប់រង់ចាំទទួលឯកសារ ។ សាក្សីប្រគល់ឯកសារជូន នួន ជា តែនៅពេលណាដែលអ្នករង់ចាំទទួលឯកសារមិននៅទីនោះតែប៉ុណ្ណោះ ។ សាក្សីបញ្ជាក់បន្ថែមថា នួន ជា បានទទួលការកិច្ចជំនួស យុន យ៉ាត ក្នុងក្រសួងឃោសនាការនៅពេលចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ គឺនៅមុនការចូលមកដល់នៃទាហានវៀតណាម ។

### ៣) ការសួរដេញដោលសាក្សីដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី

អង្គជំនុំជម្រះបានប្រគល់វេទិកាសួរដេញដោលសាក្សី ខៀវ

អេន ជូនសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ។ ប៉ុន្តែ សហមេធាវីជាតិនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក ពេជ អង្គ បានឡើងជម្រាបជូនអង្គជំនុំជម្រះថា លោកនឹងផ្ទេរវេទិកាសួរដេញដោលសាក្សី ខៀវ អេន ជូនមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី គឺលោក ឡោ ជុនធី និងមេធាវី បេនី យេ ។ អំឡុងពេលនៃការសួរដេញដោលមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងពីររូបបានសួរផ្តោតសំខាន់លើការជម្លៀសប្រជាជនពីទីក្រុង និងទីប្រជុំជន, ការចូលរួមក្នុងវគ្គសិក្សារៀនសូត្រ និងកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងឃោសនាការ ព្រមទាំងការបាត់ខ្លួនបុគ្គលិកនៃក្រសួងនេះ ក្រោយពេលមានការចាប់ខ្លួន ហ៊ូ នឹម ។

## ៣.ក) មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឡោ ជុនធី បានចាប់ផ្តើមសំណួរដំបូងរបស់ខ្លួន ដោយផ្តោតលើការជម្លៀសប្រជាជនចេញពីទីក្រុង និងទីប្រជុំជននៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ឆ្លើយតបនឹងសំណួរនេះ សាក្សី ខៀវ អេន បានបញ្ជាក់ថា ខ្លួនមិនបានដឹងលម្អិតអំពីការជម្លៀសប្រជាជនទេ ដោយសារនៅពេលខ្មែរក្រហមទទួលបានជ័យជម្នះខ្លួនកំពុងឈរជើងនៅតាមបណ្តោយទន្លេនៃខេត្តកំពង់ឆ្នាំង ។

បន្ទាប់មកនៅចុងឆ្នាំ១៩៧៥ ឬដើមឆ្នាំ១៩៧៦ ទើបខ្លួនត្រូវបានបញ្ជូនមកធ្វើការនៅទីក្រុងភ្នំពេញ ប៉ុន្តែមិនចាំពេលវេលាជាក់លាក់ទេ ។ មេធាវីបានបន្តសួរទាក់ទងនឹងភារកិច្ចរបស់សាក្សីនៅទីក្រុងភ្នំពេញ ។ សាក្សីបានអះអាងថា នៅពេលមកដល់ទីក្រុងភ្នំពេញខ្លួនត្រូវបានបញ្ជូនមកធ្វើការនៅក្រសួងឃោសនាការខាងជួសជុលអគ្គិសនី ប៉ុន្តែក្រោយមកផ្លាស់ទៅផ្នែកទាញយកព័ត៌មាន ។ សាក្សីបន្តថា មុនពេលធ្វើការនៅទីនោះខ្លួនបានចូលរួមវគ្គសិក្សាមួយដែលមានការបង្រៀនពីអ្នកជំនាញការជនជាតិចិនរយៈពេល៦ខែ ។

បន្ទាប់មក មេធាវីបានសាកសួរអំពីការចូលកាន់តំណែងរបស់ យុន យ៉ាត ជារដ្ឋមន្ត្រីក្រសួងឃោសនាការជំនួស ហ៊ូ នឹម ថាតើមានផ្លាស់ប្តូរអ្វីខ្លះក្រោយការចូលកាន់តំណែង យុត យ៉ាត នាពេលនោះ? សាក្សីបានបញ្ជាក់ថា ក្រោយការបាត់ខ្លួន ហ៊ូ នឹម អ្នកដែលធ្វើការនៅទីនោះក៏បានបាត់ខ្លួនជាបន្តបន្ទាប់ដែរ ហើយនៅក្រោយការមកដល់របស់ យុន យ៉ាត គឺមានការបញ្ចូលមនុស្សជំនួសកន្លែងអ្នកដែលបានបាត់ខ្លួន ។ អ្នកដែលជំនួសកន្លែងទាំងអស់នោះ គឺជាប្រជាជនមកពីភូមិភាគនិរតី ។ សាក្សីគិតថាអ្នកដែលបាត់ខ្លួននៅពេលនោះ គឺដោយសារតែមានជាប់ពាក់ព័ន្ធនឹងអ្នកដែលត្រូវបានចោទប្រកាន់ថាក្បត់ ដែលចេញមកពីភូមិភាគបូព៌ា ។ សាក្សីបន្តថា ការណ៍ដែលខ្លួនមិនត្រូវបានចាប់ដោយសារខ្លួនគឺជាអ្នកដែលមកពីភូមិភាគបស្ចិម ។ ចំពោះមូលហេតុនៃការចូលគ្រប់គ្រងរបស់ នួន ជា ជំនួស យុន យ៉ាត នៅមុនពេលនៃការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ សាក្សីមិនបានដឹងពីមូលហេតុពិតប្រាកដឡើយ ។

មេធាវី ជុនធី បានបន្តសួរទាក់ទងនឹងកូនប្រុសរបស់ ហ៊ូ នឹម ថាតើសាក្សីធ្លាប់ស្គាល់កូនប្រុសរបស់ ហ៊ូ នឹម ដែរឬទេ? សាក្សីបានបញ្ជាក់ថា នៅពេលដំបូងខ្លួនមិនទាន់ស្គាល់នៅឡើយទេ ប៉ុន្តែក្រោយមកទើបដឹងថា សម ដែលមានតួនាទីជាប្រធានមន្ទីរនៅកន្លែងខ្លួនធ្វើការ គឺជាកូនរបស់ ហ៊ូ នឹម ។ ឆ្លើយតបនឹងសំណួររបស់មេធាវីទាក់ទងនឹងមន្ទីរ៨៧០ សាក្សីបានអះអាងថា ខ្លួនធ្លាប់បានឮអំពីទីតាំងនោះគឺជាកន្លែងមេដឹកនាំថ្នាក់មជ្ឈិមស្នាក់នៅ ប៉ុន្តែខ្លួនមិនដឹងថា មន្ទីរ៨៧០ នោះមានទីតាំងនៅទីណាទេ ។

## ៣.ខ) មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី

មេធាវីអន្តរជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី បេនី យេ ត្រូវបានអង្គជំនុំជម្រះផ្តល់វេទិកាជូនដើម្បីសួរដេញដោលសាក្សី ខៀវ អេន បន្ទាប់ពីសហភាគាដែលជាមេធាវីជាតិ ។ មេធាវី បេនី យេ បានចាប់ផ្តើមសំណួរទាក់ទងនឹងការចូលរួមនៅក្នុងចលនាបដិវត្តរបស់សាក្សី ដោយចោទសួរថា តើសាក្សីមានអាយុប៉ុន្មាននៅពេលចូលរួមក្នុងចលនាបដិវត្តន៍? សាក្សី ខៀវ អេន បញ្ជាក់ថា លោកចូលរួមធ្វើបដិវត្តន៍នៅអាយុ១៧ ឬ១៨ឆ្នាំ ។ បន្ទាប់មកមេធាវីរូបនេះបានបន្តសាកសួរទាក់ទងនឹងការបាត់ខ្លួនបុគ្គលិកនៃក្រសួងឃោសនាការ ថាតើការបាត់ខ្លួនបុគ្គលិកនៅទីនោះបានបន្តរហូតដល់ពេលណា? សាក្សីបានអះអាងថា ក្រោយពេល យុន យ៉ាត ចូលមកគ្រប់គ្រងនៅក្នុងក្រសួងនោះ ការបាត់ខ្លួនបុគ្គលិកក៏បានស្ងាត់មួយរយៈ ហើយក្រោយមកទើបលែងមានការបាត់ខ្លួនតែម្តង ។ សាក្សីបន្តទៀតថា ក្រោយពេល នួន ជា ទទួលបន្ទុក

ជំនួស យុន យ៉ាត នៅមន្ទីរក-៣៣ មិនមានការបាត់ខ្លួនបុគ្គលិកដែលធ្វើការនៅទីនោះទេ ប៉ុន្តែនៅខាងក្រៅក្រសួងរបស់លោក លោកបានឮពីមិត្តភិក្តថា គឺនៅតែបន្តមានការបាត់ខ្លួន ។

## ៤) ការសួរដេញដោលសាក្សីដោយចៅក្រម ហ្សង់ម៉ាក ឡាវែញ

លោកចៅក្រមសញ្ជាតិបារាំង ហ្សង់ម៉ាក ឡាវែញ ត្រូវបានប្រធានអង្គជំនុំជម្រះផ្តល់វេទិកាដើម្បីសួរដេញដោលសាក្សីទាក់ទងនឹងអង្គភាពដែលធ្វើការពាក់ព័ន្ធនឹងការទាញយកព័ត៌មានពីសារព័ត៌មានបរទេសនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ លោកចៅក្រមបានចោទសួរថា បើតាមបទពិសោធន៍របស់សាក្សី តើមានអង្គភាពណាខ្លះដែលធ្វើការទាញយកព័ត៌មានបរទេសដូចនៅក្រសួងឃោសនាការដែរឬទេ? លោកសាក្សីបានបញ្ជាក់ថា ក្រៅពីក្រសួងឃោសនាការដែលលោកធ្វើការ លោកមិនបានដឹងអំពីអង្គភាពផ្សេងៗទៀតនោះទេ ។ លោកចៅក្រម ឡាវែញ បានបន្តសួរទាក់ទងនឹងទំនាក់ទំនងរវាងក្រសួងឃោសនាការ និងក្រសួងការបរទេស ។ ឆ្លើយតបនឹងសំណួរនេះ សាក្សីបានអះអាងថា នៅមុនពេលនៃការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ក្រសួងការបរទេសបានបញ្ជូនបុគ្គលិកពីរ ឬបីនាក់ឲ្យមកធ្វើការនៅកន្លែងលោក ។ បន្ទាប់មកលោកចៅក្រមប្តូរប្រធានបទដោយចោទសួរទាក់ទងនឹង ហ៊ូ យន់ ថាតើសាក្សីធ្លាប់ឮឈ្មោះ ហ៊ូ យន់ ដែរឬទេនៅអំឡុងពេលបំពេញការងារនៅក្រសួងឃោសនាការ? សាក្សី បាន បញ្ជាក់ថា លោកពិតជាធ្លាប់បានឮឈ្មោះ ហ៊ូ យន់ ប៉ុន្តែលោកមិនធ្លាប់ឃើញមុខ និងមិនដឹងថាតើ ហ៊ូ យន់ មានតួនាទីជាអ្វីទេ ។ សាក្សីបន្តថា លោកធ្លាប់ឮឈ្មោះ ហ៊ូ យន់, ហ៊ូ នឹម, ខៀវ សំផន នៅមុនពេលលោកមកដល់ភ្នំពេញទៅទៀត ។


ក្រុមកុមារកំពុងធ្វើការនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

## ៥) ការសួរដេញដោលសាក្សីដោយមេធាវីការពារក្តីទាំងបីក្រុម

អង្គជំនុំជម្រះបានបន្តប្រគល់វេទិកាជូនក្រុមមេធាវីការពារក្តីទាំងបីក្រុមដើម្បីសួរដេញដោលសាក្សី ដោយចាប់ផ្តើមពីក្រុមមេធាវីការពារក្តី នួន ជា និងបន្តទៅក្រុមមេធាវី អៀង សារី និងខៀវ សំផន ។ ដោយសារការផ្តល់សក្ខីកម្មរបស់សាក្សី ខៀវ អេន បានដាក់បន្ទុកភាគច្រើនលើជនជាប់ចោទ នួន ជា មេធាវីការពារក្តី

អៀង សារី និង ខៀវ សំផន មិនបានធ្វើការចោទសួរសាក្សីរូបនេះទេ និងបានផ្ទេរពេលវេលាសាកសួររបស់ខ្លួនជូនក្រុមមេធាវីការពារ នួន ជា ដើម្បីជួយដោះបន្ទុកកូនក្ដីរបស់ខ្លួន ។ ក្រុមមេធាវីការពារក្ដី នួន ជា បានចំណាយពេលសួរដេញដោលនៅរសៀលថ្ងៃទី១ រហូតដល់ថ្ងៃទី២ ខែតុលា ឆ្នាំ២០១២ ។

### ៥.ក) ក្រុមមេធាវីការពារក្ដី នួន ជា



អៀង សារី និង អៀង ធីរិទ្ធ រួមទាំងអតីតមន្ត្រីជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យក្នុងពិធីមង្គលការ

ការសួរដេញដោលសាក្សីដោយក្រុមមេធាវីការពារក្ដី នួន ជា បានចាប់ផ្ដើមដោយមេធាវីជាតិ គឺលោក សុន អរុណ និង បន្ទាប់មកលោកមេធាវីអន្តរជាតិ ហ្សាស្ដើ ប៉ៅ ។ មេធាវីទាំងពីររូបបានចំណាយពេលវេលាស្ទើរតែពេញ១ថ្ងៃកន្លះក្នុងការសាកសួរសាក្សី ខៀវ អេន ។ ការសួរដេញដោលរបស់ក្រុមមេធាវីការពារក្ដី នួន ជា បានផ្ដោតជាសំខាន់ដើម្បីដោះបន្ទុក ចំពោះការលើកឡើងរបស់សាក្សី ខៀវ អេន ទាក់ទងនឹងការចូលគ្រប់គ្រងក្រសួងឃោសនាការជំនួស យុន យ៉ាត ដោយ នួន ជា និងផ្ដោតលើកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីដែលធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ។

### ៥.ក.១) មេធាវីជាតិ

មេធាវីជាតិការពារក្ដី នួន ជា គឺលោក សុន អរុណ បាន

ចាប់ផ្តើមសំណួររបស់ខ្លួនដោយចោទសួរទាក់ទងនឹងកំណត់ហេតុនៃកិច្ចសម្ភាសន៍រវាងសាក្សី និងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត។ លោកមេធាវី អរុណ បានលើកយកចម្លើយរបស់សាក្សីដែលឆ្លើយប្រាប់អ្នកស៊ើបអង្កេតទាក់ទងនឹងការចូលគ្រប់គ្រងនៅក្រសួងឃោសនាការរបស់ យុន យ៉ាត ជំនួស ហ៊ូ នឹម ក្រោយពេលចាប់ខ្លួន និងការចូលមកគ្រប់គ្រងក្នុងក្រសួង


របស់ សួង ស៊ីគឿន ក្នុងឆ្នាំ១៩៨៨

នោះរបស់ នួន ជា ជំនួស យុន យ៉ាត ដើម្បីឲ្យសាក្សីធ្វើការបញ្ជាក់។ សាក្សីបានបញ្ជាក់ថា បន្ទាប់ពីការចាកចេញរបស់ យុន យ៉ាត មិនមានឯកសារណាមួយដែលបញ្ជាក់ថា នួន ជា បានចូលមកកាន់តំណែងជារដ្ឋមន្ត្រីក្រសួងឃោសនាការទេ។

ដូចគ្នានឹងការសាកសួរចំពោះសាក្សីមុនៗដែរ មេធាវី សុន អរុណ បានបន្តការសាកសួរសាក្សី ខៀវ អេន ទាក់ទងនឹងទស្សនាវដ្តីទង់បដិវត្ត និងទស្សនាវដ្តីយុវជន និងយុវនារីបដិវដ្ត ថាតើសាក្សីធ្លាប់បានអានទស្សនាវដ្តីទាំងនោះដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ សាក្សីបានបញ្ជាក់ថា ខ្លួនធ្លាប់បានអានឯកសារទាំងនោះ ប៉ុន្តែមិនដែលអានចប់ទេ ដោយសារលោកគិតតែអំពីការងារផ្ទាល់ខ្លួនរបស់លោក។

មេធាវីបានប្តូរសំណួរ ដោយត្រឡប់មកសួរទាក់ទងនឹងទំនាក់ទំនងរវាងសាក្សី និង នួន ជា ថាតើសាក្សីធ្លាប់ធ្វើការនៅក្រោមការគ្រប់គ្រងរបស់ នួន ជា រយៈពេលប៉ុន្មានឆ្នាំនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ? សាក្សីបានអះអាងថា លោកមិនបានចាំអំពីពេលវេលាជាក់លាក់ទេ ប៉ុន្តែបើតាមការចងចាំគឺនៅចុងឆ្នាំ១៩៧៨ រហូតដល់ឆ្នាំ១៩៧៩ នៅមុនពេលដែលវៀតណាមចូលមកដល់។ បន្ទាប់មកមេធាវីបានបន្តសួរទៀតថាតើសាក្សីធ្លាប់បានជួប នួន ជា ញឹកញាប់ដែរឬទេ ក្នុងឋានៈ នួន ជា ជាអ្នកគ្រប់គ្រងនៅក្រសួងដែលសាក្សីធ្វើការ? សាក្សីបានបញ្ជាក់ថា ខ្លួនស្គាល់ នួន ជា ប៉ុន្តែមិនមានភាពជិតស្និតទេ ព្រោះខ្លួនជួប នួន ជា តែនៅពេលដែលយកឯកសារប្រគល់ជូន នួន ជា នៅពេលដែលអ្នកទទួលឯកសារមិនមានវត្តមាននៅកន្លែងធ្វើការតែ ប៉ុណ្ណោះ។ នៅក្នុងអំឡុងពេលធ្វើការជាមួយ នួន ជា សាក្សីបានកត់សម្គាល់ថា នួន ជា គឺជាមនុស្សម៉ឺងម៉ាត់ និងជាមនុស្សប្រាកដប្រជា និងបានណែនាំឲ្យបុគ្គលិកនៅទីនោះខស្វាហ៍ព្យាយាមធ្វើការ រាប់ចាប់តាំងពីការដេកពួន និងហាមឃាត់មិនឲ្យដក់បារី។ សាក្សីបានបញ្ជាក់បន្ថែមថា ចំពោះសកម្មភាពផ្សេងទៀតរបស់ នួន ជា លោកមិនបានដឹងលម្អិតទេ។

### ៥.ក.២) មេធាវីអន្តរជាតិ

មេធាវីអន្តរជាតិការពារក្តី នួន ជា គឺលោក ហ្សាស្តេ ប៉ោ បានបន្តសួរដេញដោលសាក្សី ដោយ សំណួរដំបូងរបស់មេធាវីគឺទាក់ទងនឹងការផ្តល់ចម្លើយរបស់សាក្សី ជូនអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតថា តើអ្នកស៊ើបអង្កេតមាននិយាយអំពីគោលបំណងក្នុងការសាកសួរនេះដែរឬទេ? និង

ដឹងទេថា ហេតុអ្វីបានជាអ្នកស៊ើបអង្កេតទាំងនោះស្នើឲ្យសាក្សីចូលផ្តល់សក្ខីកម្មនៅសវនាការ? សាក្សីមិនបានឆ្លើយតបនឹងសំណួរដំបូងរបស់មេធាវីទេ ប៉ុន្តែសាក្សីបានបញ្ជាក់ចំពោះសំណួរទីពីរថា នៅពេលដំបូងខ្លួនមិនមានបំណងចូលផ្តល់សក្ខីកម្មក្នុងសវនាការទេ ប៉ុន្តែក្រោយមកដោយសារលោកគិតថាតុលាការត្រូវការខ្លួនទើបលោកបានផ្លាស់ប្តូរគំនិត ដោយវិលត្រឡប់ចូលរួមក្នុងសវនាការដោយពុំមានការបង្ខិតបង្ខំពីសំណាក់អ្នកស៊ើបអង្កេតទេ ។ សាក្សីបន្តថា នៅអំឡុងពេលនៃការផ្តល់សក្ខីកម្មអ្នកស៊ើបអង្កេតបានសួរសាក្សីអំពីប្រវត្តិសាវតាររបស់លោកចាប់តាំងពីការធ្វើការនៅក្នុងសម័យខ្មែរក្រហម ។

មេធាវី ហ្សាស្តេ បានបន្តសួរសាក្សីទៀតថា តើសាក្សីធ្លាប់ស្គាល់ឈ្មោះ គីម វុន ហៅ ឆោម ដែរឬទេ? សាក្សីបានបញ្ជាក់ថា ខ្លួនពិតជាស្គាល់ឈ្មោះ គីម វុន ហៅ ឆោម ព្រោះបច្ចុប្បន្នខ្លួន និងលោក គីម វុន កំពុងបំពេញការងារនៅខេត្តប៉ៃលិនទាំងអស់គ្នា ប៉ុន្តែស្ថិតនៅកន្លែងផ្សេងគ្នា ។ សាក្សី ខៀវ អេន បានពន្យល់ទៀតថា នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្លួន និងលោក គីម វុន ធ្លាប់ធ្វើការជាមួយគ្នានៅមន្ទីរក-៣៣ ។ បច្ចុប្បន្នលោកមិនមានទំនាក់ទំនងជិតស្និតជាមួយគ្នាទៀតទេ គឺគ្រាន់តែជួបគ្នាម្តងម្កាលក្នុងនាមជាមិត្តភក្តិចាស់តែប៉ុណ្ណោះ ។ ឆ្លើយតបនឹងសំណួររបស់មេធាវី ហ្សាស្តេ ដែលចោទសួរថា តើសាក្សីបានដឹងទេថា លោក គីម វុន ត្រូវបានកោះហៅមកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ? សាក្សីបានអះអាងថា ខ្លួនបានដឹងលោក គីម វុន ត្រូវបានអង្គជំនុំជម្រះកោះហៅដើម្បីផ្តល់សក្ខីកម្មក្នុងសវនាការ ប៉ុន្តែលោកមិនបានជួបគ្នានៅមុនពេលលោកចូលមកផ្តល់សក្ខីកម្មទេ ។ សាក្សីគិតថា ប្រសិនបើអ្នកដែលធ្លាប់ធ្វើការជាមួយលោកនៅមន្ទីរក-៣៣ នៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានកោះហៅចូលផ្តល់សក្ខីកម្មក្នុងតុលាការ លោកខ្លួនឯងផ្ទាល់ក៏ប្រហែលជានឹងត្រូវកោះហៅឲ្យចូលផ្តល់សក្ខីកម្មក្នុងសវនាការដែរ ។

សូមបញ្ជាក់ថា ក្រោយពេលសាក្សីឆ្លើយតបចំពោះសំណួរនេះ លោកប្រធានអង្គជំនុំជម្រះបានកត់សម្គាល់អំពីការសាកសួររបស់មេធាវី ហ្សាស្តេ ប៉ោ ដោយអង្គជំនុំជម្រះផ្តល់ហេតុផលថា ការសួរដេញដោលរបស់មេធាវីហ្សាស្តេ មិនមានភាពជាប់ទាក់ទងនឹងអង្គហេតុ ។ លោកប្រធានអង្គជំនុំជម្រះបានសង្កត់ធ្ងន់ថា ការសួរដេញដោលរបស់មេធាវីការពារក្តីជនជាប់ចោទ នួន ជា គឺគ្រាន់តែធ្វើឡើងក្នុងបំណងមោឃភាពនីតិវិធីនៅក្នុងដំណាក់កាលចៅក្រមស៊ើបអង្កេតតែប៉ុណ្ណោះ ។ បន្ទាប់មកលោកចៅក្រមបានបង្គាប់ឲ្យមេធាវីសាកសួរសំណួរណាដែលមានជាប់ទាក់ទងនឹងអង្គសេចក្តី ។ ឆ្លើយតបនឹងការកត់សម្គាល់របស់អង្គជំនុំជម្រះ មេធាវី ហ្សាស្តេ បានអះអាងថា ខ្លួនមិនមានបំណងក្នុងការធ្វើមោឃភាពនីតិវិធី ឬកិច្ចដំណើរការស៊ើបអង្កេតការិយាល័យសហចៅក្រមស៊ើបអង្កេតទេ ។ សំណួររបស់ខ្លួន គឺគ្រាន់តែចង់បង្ហាញអំពីទំនាក់ទំនងរវាងសាក្សី និងលោក គីម វុន ដែលធ្លាប់បានធ្វើការជាមួយគ្នានៅមន្ទីរក-៣៣ ថាតើអ្នកទាំងពីរបានទាក់ទងគ្នានៅមុនពេលចូលមកផ្តល់សក្ខីកម្មនៅក្នុងសវនាការដែរឬយ៉ាងណា ។ ទោះបីជាមានការឆ្លើយបកស្រាយពីមេធាវី ហ្សាស្តេ អង្គជំនុំជម្រះបានបង្គាប់ឲ្យលោកមេធាវីផ្លាស់ប្តូរសំណួររបស់ខ្លួនក្នុងការសាកសួរសាក្សី ។

ទាក់ទងនឹងការងារនៅក្រសួងឃោសនាការ មេធាវីបានសួរថា តើហេតុអ្វីបានជាសាក្សីមិនយល់អំពីការខ្លឹមសារនៃឯកសារដែលសាក្សីបានទាញយកពីសារព័ត៌មានបរទេស? សាក្សីបានពន្យល់តបនឹងសំណួរនេះថា ឯកសារព័ត៌មានដែលខ្លួនបានទាញយក គឺជាឯកសារជាភាសាអង់គ្លេស និងភាសាបារាំង ហើយលោកមិនចេះភាសាទាំងនោះទេ ។ ដូច្នេះ លោកមិនយល់អំពីខ្លឹមសារនៃឯកសារទាំងអស់នោះឡើយ ។ បន្ទាប់មកមេធាវីបានបន្តសួរទៀតថា តើសាក្សីធ្លាប់ដឹងអំពីការងាររបស់ថ្នាក់ដឹកនាំដូចជា ហ៊ូ នឹម និង យុន យ៉ាត ដែរឬទេ? សាក្សីបាន បញ្ជាក់ថា លោកមិនចង់ដឹងអំពីការងាររបស់ថ្នាក់ដឹកនាំទេ ។

ទាក់ទងនឹងការចូលរួមក្នុងកិច្ចប្រជុំជាមួយ នួន ជា មេធាវី ហ្សាស្តេ បានសួរសាក្សីថា តើសាក្សីប្រាកដទេថា លោកធ្លាប់ចូលរួមក្នុងកិច្ចប្រជុំដែលដឹកនាំដោយ នួនជា? ឆ្លើយតបសំណួរនេះសាក្សីបានអះអាងថា ខ្លួនពិតជាធ្លាប់ចូលរួមក្នុងកិច្ចប្រជុំជាមួយ នួន ជា ប៉ុន្តែជាកិច្ចប្រជុំដែលមានលក្ខណៈមិនផ្លូវការ និងមិនសូវសំខាន់ ។

ចំពោះសំណួរទាក់ទងនឹងគណៈអចិន្ត្រៃយ៍ សាក្សីបានអះអាងថា ខ្លួនមិនដឹងថាអ្វីជាគណៈអចិន្ត្រៃយ៍ទេនាពេលនោះ ប៉ុន្តែ

លោកធ្លាប់បានឮ និងដឹងថា ប៉ុល ពត ជាបុគ្គលទីមួយ ។ ពាក់ព័ន្ធនឹងតួនាទីរបស់ យុន យ៉ាត ក្រៅពីក្រសួងឃោសនាការ សាក្សីបានបញ្ជាក់ថា ខ្លួនមិនបានដឹងអ្វីទាំងអស់ ប៉ុន្តែលោកគ្រាន់តែកត់សម្គាល់ថា នៅពេលដែល យុន យ៉ាត ចូលមកគ្រប់គ្រងក្រសួងឃោសនាការជំនួស ហ៊ូ នឹម ក្រសួងនេះត្រូវបានកែប្រែទៅជាក្រសួងឃោសនាការ និងអប់រំ ។

នៅទីនោះទៀតហើយ ។ មេធាវីបានសួរបន្តថា តើអាចទៅរួចដែរឬទេនៅពេលដែល យុន យ៉ាត ទៅក្រសួងឃោសនាការហើយសាក្សីមិនបានឃើញដោយសារលោកកំពុងធ្វើការ? សាក្សីហាក់បីដូចជាមិនបានឆ្លើយតបចំនឹងសំណួររបស់មេធាវីការពារក្តីទេ ដោយសាក្សីលើកឡើងតែអំពីទំនាក់ទំនងរវាងថ្នាក់លើរបស់ខ្លួនដែលបានជួបគ្នាជាមួយនឹង យុន យ៉ាត ។



យុន យ៉ាត ចាប់ដៃស្វាគមន៍ព្រះអង្គម្ចាស់ប្រទេសឡាវ សុផាណាវង្ស (ប្រភពរូបថត៖មជ្ឈមណ្ឌលឯកសារកម្ពុជា)

**គួរកត់សម្គាល់ថា** នៅមុនពេល យុន យ៉ាត ចូលមកគ្រប់គ្រងជំនួស ហ៊ូ នឹម, យុន យ៉ាត មានតួនាទីជារដ្ឋមន្ត្រីក្រសួងអប់រំរួចស្រេចទៅហើយ ។ សាក្សីបន្តទៀតថា ក្រសួងឃោសនាការដែលខ្លួនធ្វើការ គឺមានទីតាំងនៅជិតសាលា លីសេ ដេកាត រីឯក្រសួងអប់រំ គឺមានទីតាំងនៅជិតបុរីកីឡា ។

មេធាវី ហ្សាស្តេ បានបន្តសួរសាក្សីទាក់ទងនឹង វត្តមានរបស់ យុត យ៉ាត នៅក្រសួងឃោសនាការ ថាតើសាក្សីធ្លាប់ឃើញ យុន យ៉ាត ទៀតទេ ក្រោយពេលដែល នួន ជា ចូលមកគ្រប់គ្រងក្រសួងឃោសនាការជំនួស យុន យ៉ាត? សាក្សីបានឆ្លើយតបនឹងសំណួរនេះថា បន្ទាប់ពីមានការផ្លាស់ប្តូរពី យុន យ៉ាត មក នួន ជា លោកចាប់អារម្មណ៍ឃើញថា យុន យ៉ាត លែងបន្តមានវត្តមាន

ទាក់ទងនឹងការតែងតាំង យុន យ៉ាត ធ្វើជារដ្ឋមន្ត្រីក្រសួងឃោសនាការជំនួសតំណែងរបស់ ហ៊ូ នឹម សាក្សីបានបញ្ជាក់ថា ខ្លួនមិនធ្លាប់បានឃើញឯកសារណាមួយដែលធ្វើការតែងតាំង យុន យ៉ាត ឲ្យធ្វើជារដ្ឋមន្ត្រីទេ ប៉ុន្តែលោកគ្រាន់តែដឹងថា យុន យ៉ាត បានចូលមកគ្រប់គ្រងជំនួស ហ៊ូ នឹម តែប៉ុណ្ណោះ ។

បន្ទាប់មកមេធាវីបានបន្តសួរទាក់ទងនឹងតួនាទីរបស់ យុន យ៉ាត នៅក្រោយឆ្នាំ១៩៧៩ ប៉ុន្តែសំណួរនេះត្រូវបានអង្គជំនុំជម្រះសម្រេចមិនអនុញ្ញាតឲ្យសាក្សីឆ្លើយតបដោយផ្តល់ហេតុផលថា សំណួរនេះមិនស្ថិតនៅក្នុងវិសាលភាពនៃអង្គហេតុ ដែលផ្តោតសំខាន់លើអ្វីដែលបានកើតឡើងនៅអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យចន្លោះពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។ មេធាវី

ហ្សាស្ដ្រី បានឆ្លើយតបនឹងការសម្រេចរបស់អង្គជំនុំជម្រះថា ការណ៍ដែលលោកសួរសំណួរនេះ គឺដោយសារតែនៅក្រោយឆ្នាំ ១៩៧៩ យុន យ៉ាត នៅតែបន្តស្ថិតក្នុងតំណែងជារដ្ឋមន្ត្រីក្រសួងឃោសនាការដដែល ។ អំឡុងពេលដែល អៀង សារី មិនអាចចូលរួមដោយផ្ទាល់ ដែលអាចធ្វើឲ្យរារាំងដល់ដំណើរការនីតិវិធីក្នុងការសួរដេញដោលសាក្សីដែលទាក់ទងនឹងជនជាប់ចោទ អៀង សារី ឬ អាចត្រូវពន្យាពេលកិច្ចដំណើរការនីតិវិធីក្នុងការសួរដេញដោល ។



មេដឹកនាំខ្មែរក្រហមជូនដំណើរគណៈប្រតិភូបរទេសនៅអាកាសយានដ្ឋានពោធិ៍ចិនតុង (រូបភាពមជ្ឈមណ្ឌលឯកសារកម្ពុជា)

**គួរកត់សម្គាល់ថា** មេធាវីសួរសំណួរនេះ គឺដើម្បី បញ្ជាក់ថា កូនក្ដីរបស់ខ្លួនជនជាប់ចោទ នួន ជា មិនបានកាន់ដំណែងជារដ្ឋមន្ត្រីក្រសួងឃោសនាការជំនួស យុន យ៉ាត ដូចជាការសន្និដ្ឋានរបស់សាក្សី ខៀវ អេន ទេ ។

សវនាការសួរដេញដោលសាក្សី ខៀវ អេន បានបញ្ចប់នៅរសៀលថ្ងៃទី២ ខែតុលា ឆ្នាំ២០១២ ។ បន្ទាប់មក នៅរសៀលថ្ងៃដដែល អង្គជំនុំជម្រះបានបន្តសវនការដាច់ដោយឡែកមួយផ្សេងទៀតដើម្បីជជែកអំពីវិធីសាស្ត្រក្នុងការដំណើរការនីតិវិធីនៅខណៈពេលជនជាប់ចោទ អៀង សារី កំពុងជួបប្រទះនឹងបញ្ហាសុខភាពធ្ងន់ធ្ងរមិនអាចចូលរួមសវនាការដោយផ្ទាល់បាន ។ នៅក្នុងសវនាការនោះ អង្គជំនុំជម្រះ តាមរយៈលោកស្រីចៅក្រម ស៊ីលវៀ ខាតវ្រ៉ាយត៍ បានស្នើឲ្យក្រុមមេធាវីការពារក្ដីបញ្ចេញយោបល់ចំពោះវិធីសាស្ត្រ ក្នុងការដំណើរការនីតិវិធីសវនាការក្នុង

ឆ្លើយតបនឹងសំណើរបស់លោកស្រីចៅក្រម ខាតវ្រ៉ាយត៍ មេធាវីអន្តរជាតិការពារក្ដី អៀង សារី គឺលោក ម៉ៃឃើល កាណាវ៉ាស បានបញ្ជាក់ថា លោកបានរៀបចំបញ្ជីឈ្មោះសាក្សីដែលជនជាប់ចោទ អៀង សារី មានចេតនាបោះបង់សិទ្ធិក្នុងការចូលរួមក្នុងសវនាការស្ដីពីការផ្ដល់សក្ខីកម្មរបស់សាក្សីទាំងអស់នោះរួចហើយ ។ សាក្សីទាំងនោះ គឺមានចំនួន១៥នាក់ ។ ប៉ុន្តែមេធាវីក៏បានបញ្ជាក់ជូនអង្គជំនុំជម្រះដែរថា អៀង សារី នឹងរក្សាសិទ្ធិក្នុងការសួរដេញដោលសាក្សីរូបណាដែលសក្ខីកម្មរបស់អ្នកទាំងនោះមានឆ្លើយដាក់បន្ទុកលើខ្លួន នៅក្នុងអំឡុងពេលនៃការបោះបង់សិទ្ធិក្នុងការចូលរួមសវនាការនេះ ។ មេធាវីបានបន្ថែមថា លោកគិតថាមិនគួរមានការពន្យាកិច្ចដំណើរការនីតិវិធីទៀតទេ ។

**ពិនិត្យ និងផ្ទៀងផ្ទាត់ដោយ វ៉ាន់ថាន់ ពោធារ៉ា**

## ពន្យល់ពាក្យសំខាន់ៗ

ក-១៨ : ជាមជ្ឈមណ្ឌលគមនាគមន៍ដែលមានទីតាំងស្ថិតនៅអតីតស្ថានទូតសហរដ្ឋអាមេរិក ត្រង់កែងមហាវិថីនរោត្តម និងសុធារស, ក្នុងទីក្រុងភ្នំពេញ ។

ប-៣០, ៣១, ៣២ : ជំរំអប់រំកែប្រែសម្រាប់បញ្ញវន្ត អ្នកការទូត និងនិស្សិត ដែលធ្វើមាតុភូមិនិវត្តន៍ ។ មានទីតាំងស្ថិតនៅបឹងត្របែក ក្នុងទីក្រុងភ្នំពេញ ដែលត្រូវបានប្តូរឈ្មោះដោយភ្ជាប់លេខកូដអក្សរ“ប” បន្ទាប់ពីបានផ្ទេរការគ្រប់គ្រងពីមន្ទីរ៨៧០ មកឲ្យក្រសួងការបរទេស ដែលពីមុនត្រូវបានស្គាល់ថាជាមន្ទីរក-១៥, ក-១៦ និង ក-១៧ ។

វិទ្យុផ្សាយសំឡេងកំពេញ : ការផ្សាយសំឡេងតាមវិទ្យុដោយក្រសួងឃោសនាការអំពីព័ត៌មានពាក់ព័ន្ធនឹងរបបទៅកាន់ពិភពលោក ។


## មជ្ឈមណ្ឌលឯកសារកម្ពុជា

ប្រអប់សំបុត្រលេខ១១១០, ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥

ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

អ៊ីម៉ែល : dccam@online.com.kh

គេហទំព័រ : www.dccam.org

ឬ www.cambodiatribunal.org



គម្រោងនេះទទួលជំនួយហិរញ្ញវត្ថុពីមូលនិធិ *John D. and Catherine T. MacArthur Foundation and British Embassy-Cambodia* ។


| ល.រ | ឈ្មោះដើម | ឈ្មោះបដិវត្ត | លេខសម្ងាត់ | ប្រភពឯកសារ |
|---|---|---|---|---|
| ១ | សាឡុត ស | ប៉ុល ពត, បងប៉ុល, បងទី១, | ៨៧០, ៨៧ | D427, E1/56.1 |
| ២ | នួន ជា | នួន ជា, បងនួន, បងទី២ | (អត់ដឹង) | D427 |
| ៣ | គីម ត្រាង | អៀង សារី, វ៉ាន់ | (អត់ដឹង) | D427, E1/21.1 |
| ៤ | ខៀវ សំផន | ហែម, ខាង, ណន | (អត់ដឹង) | D427 |
| ៥ | សុន សេន | ខៀវ, ឃឹម | ៨៩, ៦២ | E1/54.1 |



**ឆាយ ឈុនលី**

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**លឹម ជ័យវ័ត្ត**

បរិញ្ញាបត្រច្បាប់ និងបរិញ្ញាបត្រសេដ្ឋកិច្ច ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងជាជ័យលាភីថ្នាក់ជាតិក្នុងការប្រកួតសវនាការប្រឌិតឆ្នាំ២០១០ ។



**ឌី សុជាតា**

បរិញ្ញាបត្រច្បាប់ សិក្សាជាភាសាអង់គ្លេស ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។



**ចាន់ ប្រាថ្នា**

បរិញ្ញាបត្រច្បាប់ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

















































មជ្ឈមណ្ឌលឯកសារកម្ពុជា រក្សាសិទ្ធិខែតុលា ឆ្នាំ២០១២